NATION
MODEL
BITTER
RATIFY
WEAK

COMPROMISE
CONFEDERATION
CENTRALISM
GENERAL CONVENTION
NATIONAL GOVERNMENT
CONSTITUTIONAL
BILL OF RIGHTS
POLITICAL SYSTEM

JUDICIAL
INTERPRET
LEGISLATIVE
COMMERCE
STATES
FRAMER
VIRGINIA
EXPERIENCE

A G E N E R A L C O N V E N T I O N C V
E R C O M P R O M I S E B I T T E R O I
X W T B A L A N C E J U D I C I A L N R
E E L I C E N T R A L I S M B U A A S G
C A C E C O N F E D E R A T I O N R T I
U K D C B L F E D E R A L I S M Y G I N
T D O C U M E N T R A T I F Y L B U T I
I N A T I O N S I N T E R P R E T M U A
V P O L I T I C A L S Y S T E M N E T A
E L E G I S L A T I V E S E A T S T O C
B I L L O F R I G H T S T A T E S N I C
N A T I O N A L G O V E R N M E N T N E
C O M M E R C E C H E A S A P E A K A P
D E L E G A T E R O G E R M O D E L L T
R E P R E S E N T A T I O N I D E A L L
F R A M E R E X P E R I E N C E O M N B
F E D E R A L I S T R A T I F Y B O A Y

២. ការប្រៀបផ្ទឹម៖

សូមប្រៀបផ្ទឹមពាក្យដែលនៅខាងឆ្វេង ក្រោមបន្ទាត់អក្សរ A ទៅនឹងអត្ថន័យ ឬសេចក្ដីពន្យល់ ដែលនៅខាងស្ដាំ ក្រោមបន្ទាត់អក្សរ B ដោយដាក់ចម្លើយជាលេខនៅពីខាងមុខផង ។

A

__________ក. អង្គនីតិបញ្ញត្តិនៃសភាទាំងពីរ

__________ខ. ច្បាប់បង្កើតសហភាព

__________គ. គណៈប្រតិភូ

__________ឃ. ផ្នែកតុលាការ

__________ង. អ្នកនិយមភាពកណ្ដាល

__________ច. និតិប្រតិបត្តិ

__________ឆ. សហព័ន្ធ

__________ជ. ការសំរបសំរួល

__________ឈ. អោយសច្ចានុមតិ

__________ញ. ច្បាប់សិទ្ធិមនុស្ស

B

១. ការសុខចិត្តទទួលឬយល់ព្រម ។

២. សេចក្ដីកែប្រែច្បាប់ដប់ដំបូងនៅក្នុងរដ្ឋធម្មនុញ្ញ ដែលបានធានារ៉ាប់រងដល់សិទ្ធិរបស់មនុស្ស ។

៣. ជាអង្គគណៈសំរាប់ធ្វើច្បាប់ដែលរួមបង្កើតឡើងដោយសារសភាទាំងពីរ ។

៤. ជាសេចក្ដីព្រមព្រៀងនៃឆ្នាំ ១៧៨១ ដែលរដ្ឋទាំង ១៣ ដំបូងរួមគ្នាបង្កើតជាសហភាព ។

៥. ជារបៀប និង ច្បាប់សំរាប់គ្រប់គ្រងរបស់រដ្ឋាភិបាលសហព័ន្ធ ។

៦. ជាផ្នែកមួយរបស់រដ្ឋាភិបាលដែលសំរាប់បកស្រាយ និង អនុវត្តនូវច្បាប់ក្នុងការកាត់សេចក្ដី ។

៧. ជាផ្នែកមួយរបស់រដ្ឋាភិបាលដែលសំរាប់ដាក់ច្បាប់អោយអនុវត្តតាម ។

៨. ជាមនុស្សដែលមានច្បាប់សំរាប់ឈរឈ្មោះជាដំណាងអ្នកណាមួយ ។

៩. ការប្រគល់នូវច្បាប់ និង អំណាចអោយដល់អ្នកដឹកនាំនៃផ្នែកអង្គការលើ ឬ ក៏ផ្នែកនយោបាយណាមួយ ។

១០. ការព្រមព្រៀងឈប់ទាស់ទែងគ្នាដោយផ្នែកទាំងសងខាងសុខចិត្តបោះបង់ចោលនូវការទាមទាររបស់ខ្លួនបន្តិចម្នាក់ៗ ។

៣- ពិត ឬ មិនពិតៈ

សូមមើលនូវឃ្លានិមួយៗ ដោយសរសេរដាក់ជាអក្សរ T នៅពីមុខឃ្លាណា ដែលយល់ថា ពិតត្រឹមត្រូវ និង អក្សរ F នៅពីមុខឃ្លាណាដែលយល់ថា មិនពិត ។

__________ ១- បន្ទាប់ពីសង្គ្រាមបដិវត្តន៍មក រដ្ឋទាំងអស់បានយល់ឃើញថា ជាការសំខាន់ណាស់ ដែលគេត្រូវតែបង្រួបបង្រួមរដ្ឋទាំង ១៣ អោយទៅជាប្រទេសតែមួយវិញ ។

__________ ២- ប្រទេសដ៏ថ្មីនេះ គ្មានបានជួបប្រទះនឹងបញ្ហាអ្វីទាំងអស់ ។

__________ ៣- រដ្ឋាភិបាលកណ្ដាលមិនអាចនឹងប្រមូលនូវពន្ធអាករពីរដ្ឋឯទៀតៗ ដើម្បីសំរាប់យកទៅសងបំណុលរបស់ប្រទេសបានទេ ។

__________ ៤- ពួកអ្នកតំណាងទាំងនោះមិនបានសរសេរបង្កើតនូវរដ្ឋធម្មនុញ្ញថ្មីទេ ។

__________ ៥- ផ្នែកទាំងបីរបស់រដ្ឋាភិបាលមាន : និតិបញ្ញត្តិ - និតិប្រតិបត្តិ និង ផ្នែកខាងតុលាការ ។

__________ ៦- រដ្ឋធម្មនុញ្ញមិនបានផ្ដត់ផ្ដង់ជាវិធី ដើម្បីសំរាប់អោយផ្នែកនិមួយៗអាចធ្វើការពិនិត្យមើលគ្នាទៅវិញទៅមក និងធ្វើអោយមានភាពស្មើគ្នាទេ ។

__________ ៧- ការមិនចុះសំរុងគ្នាដ៏ធំមួយ គឺទាក់ទងទៅនឹងរបៀបអ្នកតំណាងរាស្ត្រនៅក្នុងរដ្ឋសភា ។

__________ ៨- រដ្ឋតូចៗមិនបានប្រឆាំងនឹងគំរោងការណ៍របស់រដ្ឋ Virginia ទេ។

__________ ៩- នៅផ្នែកខាងលើ ឬ ព្រឹទ្ធសភា រដ្ឋនិមួយៗនឹងអាចមានចំនួនអ្នកតំណាងរាស្ត្រស្មើគ្នាបាន ។

__________ ១០- ពួកដែលបានលំអៀងទៅលើរដ្ឋធម្មនុញ្ញ មានឈ្មោះហៅថា ពួកអ្នកប្រឆាំងនឹងលទ្ធិរដ្ឋនិយម ។

៤. ការបំពេញក្នុងកន្លែងទំនេរ

សូមបំពេញនូវឃ្លានីមួយៗ ដោយជ្រើសរើសយកពាក្យអោយបានត្រឹមត្រូវ សំរាប់ដាក់បំពេញក្នុងកន្លែងទំនេរ ។ ពាក្យទាំងនោះមាន ៖ បកស្រាយ - សច្ចានុមតិ - ច្បាប់សិទ្ធិមនុស្ស - ដាក់កំរិត - ច្បាប់បង្កើតសហភាព - អង្គនិតិបញ្ញត្តិនៃសភាទាំងពីរ - សហរដ្ឋនិយម - អ្នកដំណាង - ប្រតិបត្តិ - ពួកសហរដ្ឋ ។

១. មានរដ្ឋខ្លះបានសុំអោយ ________ ដាក់បញ្ចូលថែមទៅក្នុងរដ្ឋធម្មនុញ្ញទៀត ហើយដែលត្រូវបានអង្គប្រជុំលើកទីមួយរបស់រដ្ឋសភាចាត់ចែងដាក់បំពេញអោយ នៅពេលក្រោយមក ។

២. លោក Alexander Hamilton បានដឹកនាំការពុះពារ ដើម្បីនឹងបជ់ជ្ញាន ______ ពី New York ។

៣. ពួកដែលលំអៀងទៅលើរដ្ឋធម្មនុញ្ញមានឈ្មោះហៅថា ពួក ________

៤. រដ្ឋសភាដែលរួមបង្កើតឡើងដោយផ្នែកសភាទាំងពីរ មានឈ្មោះហៅថា ____________

៥. Virginia ចង់តែងតាំង ________ ក្នុងរដ្ឋសភាដោយពឹងផ្អែកទៅលើចំនួនប្រជាជនរបស់រដ្ឋ ។

៦. ផ្នែកតុលាការ ជាអ្នកកាត់សេចក្តី និង _____ តាមច្បាប់ ។

៧. ការការពារការលើកដំបូងបង្អស់ ដើម្បីសំរាប់ទប់ទល់កុំអោយរដ្ឋាភិបាលកណ្តាល មានអំណាចខ្លាំងហួសហេតុពេក ជាគំនិតរបស់ __________ ដោយធ្វើការបែងចែកអំណាចរវាងរដ្ឋាភិបាលកណ្តាល និង រដ្ឋាភិបាលប្រចាំរដ្ឋទូទៅ ។

៨. ពួកគេចង់អោយរដ្ឋាភិបាលកណ្តាលមានអំណាចក្នុងការ __________ ដល់ជំនួញរវាងរដ្ឋ ដើម្បីចៀសវាងកុំអោយមានការឈ្លោះប្រកែកគ្នាបាន ។

៩. នៅក្រោម __________ គឺរដ្ឋនីមួយៗ ត្រូវមានរដ្ឋាភិបាលរបស់ខ្លួនឯងផ្ទាល់ ហើយរដ្ឋាភិបាលកណ្តាលជារដ្ឋាភិបាលរបស់ប្រទេសទាំងមូល ។

១០. រដ្ឋាភិបាលកណ្តាល ដែលបានកើតឡើងដោយសារច្បាប់បង្កើតសហភាពនោះ មានភាពទន់ខ្សោយណាស់ ពីព្រោះគ្មានប្រធានាធិបតីសំរាប់ _______ តាមច្បាប់ ។

Packet 7: THE NATION TAKES SHAPES

NEW WORDS & USAGES ពាក្យថ្មី និង ការប្រើប្រាស់

Constitution: រដ្ឋធម្មនុញ្ញ

The U.S. Constitution is the supreme law of the land.

federal supremacy: ច្បាប់សហរដ្ឋដែលមានភាពខ្លាំង និងខ្ពស់ជាងច្បាប់របស់រដ្ឋឯទៀតៗ

Federal supremacy means that a state can't make a law that conflicts with a national law.

state rights: ច្បាប់របស់រដ្ឋ

State rights means that the national government may not act in a way that conflicts with the power of the states.

Congressman: សមាជិករបស់សភា - តំណាងរាស្ត្រ

Senator: ព្រឹទ្ធសភា

The members of Congress are called Congressmen, Congresswomen, and Senators.

ambassador: ឯកអគ្គរដ្ឋទូត

The president chooses ambassadors with the approval of the Senate.

Supreme Court: តុលាការជាន់ខ្ពស់

The Supreme Court is the highest court in the country.

amendment: ច្បាប់ដែលត្រូវបានកែប្រែហើយ

The first ten amendments were called the Bill of Rights.

free speech: សេរីភាពខាងការនិយាយ

free press: សេរីភាពខាងការសែត ឬ សារព័ត៌មាន

free religion: សេរីភាពខាងសាសនា

free assembly: សេរីភាពខាងការប្រជុំ

free from unreasonable searches: ការរួចផុតពីការឆែកឆេរដោយ
ឥតមូលហេតុសមផល

public trial: ការកាត់សេចក្តីដោយចំហត្រឹមត្រូវ

The Bill of Rights gave the citizens many important rights such as the rights of free speech and free press, free religion, free assembly, freedom from unreasonable searches, and the right to have a public trial with a jury.

external problems: បញ្ហាខាងក្រៅ

The new nation faced many external problems.

neutral policy: នយោបាយអព្យាក្រឹត

The United States wanted to pursue a neutral policy and stay out of international conflicts.

West Indies: តំបន់ Indies ផ្នែកខាងលិច

France opened many ports in the West Indies.

impressment: ការចាប់យកទៅទាំងបង្ខំដើម្បីធ្វើជាទាហានជើងទឹក

Through a policy of impressment, the British seized American ships and forced their sailors into the British Navy.

frontiersman: អ្នកដែលរស់នៅតាមតំបន់ដែលមិនទាន់មានមនុស្សទៅដល់

The treaty with Spain pleased the farmers and frontiersmen because it gave them the right to use the Mississippi River to carry their farm products to New Orleans.

READING

7.1. THE NEW GOVERNMENT AND ITS THREE BRANCHES

7.1.1. The **Constitution** was nothing more than a plan for government. The actual government was considered formed only when the Constitution was put into practice in the 1790's. There are two very important ideas concerning the federal system described in the Constitution. One is called "**federal supremacy**". Federal supremacy means that a state cannot make a law that conflicts with a national law or the United States Constitution. The other important idea included in the federal system is called "**states' rights**". State rights mean that the national government may not act in a way that conflicts with the power of the states listed in the Constitution. These two important ideas require that the states and national government respect each other's power.

7.1.2. People who talk about the government of the United States frequently use the term federal government. In the federal system of government, there are two levels of government serving the same people.

7.1.3. The national government has the power to make laws for the whole country. After the laws are passed by the Congress, they are sent to the executive branch to be enforced. The Congress is also given the powers to make laws in order to collect taxes, control trade between the states and with other countries, declare war, and establish courts below the Supreme Court. The members in Congress are called **Congressmen, Congresswomen,** and **Senators.** Congressmen or Congresswomen are elected to the House of Representatives for a two-year term. Two senators are elected from each state for a six-year term. Today there are 436 representatives in the House of Representatives and 100 Senators in the Senate. The House of Representatives makes laws and the Senate approves the laws. The Senate also has the power to approve the treaties that the U.S. makes with other countries and approve the people whom the President chooses for special jobs, such as **ambassadors,** or high officials in the federal government.

7.1.4. The second branch in the federal government is the executive branch. This branch was created to enforce the laws. In the executive branch, power is in the hands of the President. He can veto or stop a law. The President serves a term of four years. The Vice-President and the cabinet help him run the government.

7.1.5. The third branch in the federal government is the judicial branch. The judicial branch includes the Supreme Court and many lower level courts. The main job of the court system is to explain the laws of the United States. The **Supreme Court** is the highest court in the federal system, and it can inform the Congress or the states, if they make laws in violation of the Constitution.

7.2. THE BILL OF RIGHTS

7.2.1. When the Constitution was ratified, many people in the states liked what the Constitution said, but many others thought the Constitution did not do enough to protect the people's rights. To make the citizens believe in the Constitution, the new Congress wrote ten amendments to the Constitution. The first ten amendments were called the "Bill of Rights". They gave people living in the United States very important rights, such as the right of free speech and free press, free religion, free assembly, freedom from unreasonable searches, and the right to have public trial with a jury.

7.2.2. It is important to remember that these rights are meant to help the people. A person many not use these rights if they go against the rights of other people. It is the job of the courts to decide if someone is using one of these rights to hurt other people 's rights.

7.3. THE NEW NATION FACED NEW EXTERNAL PROBLEMS

7.3.1. In the 1790's, the United States had European neighbors on the North American continent. The British Empire was in the North and Northwest areas. The Spanish Empire was in the South and the West. The new American government had its own policy that it was not to become involved in international problems. It was called the "neutral policy". This policy guided the United States in its external relations for almost 20 years.

7.3.2. After the Revolutionary War, there were bad feelings between Great Britain and the United States. They became worse in 1793 when France opened their ports in the **West Indies** to trade with neutral countries. American merchants quickly increased trading with the West Indies. Soon, they were doing a booming business. At that time, war was still going on between Britain and France; therefore, the British government ordered its navy to seize all ships carrying goods to or from France or French colonies. Hundreds of American ships and their cargoes were captured by the British. In many cases, American sailors were forced into the British navy. This practice was called **impressment**. The United States government tried to solve this problem by negotiation. John Jay was sent to England to settle the differences between the two countries. Jay signed a treaty with Britain. Under this treaty, Britain agreed to remove its troops from the Northwest region and Americans were allowed to trade with the British West Indies. In return, the United States was to pay the Revolutionary War debts not yet collected by Britain.

7.3.3. The Jay Treaty also led to a settlement of disagreements between Spain and the United States. Spain believed that the United States might cause trouble for the Spanish Empire in America, now that its conflict with England was over. So, late in 1795, Spain signed a treaty with the United States. This treaty settled the boundaries between the

U.S. and West Florida. It also gave Americans shipping rights on the Mississippi River and the right to use the port of New Orleans. The treaty pleased the farmers and the frontiersmen because they could use the Mississippi River to carry their farm products to the sea ports. Finally, after signing these treaties with Britain and Spain, the American people could live in peace and prepare for their future.

EXERCISES

I. Word search puzzle:

Directions: Find and circle the words in the word puzzle below. The words will be found vertically, horizontally, and diagonally. When you find a word in the puzzle, write it down and define it.

CONGRESSMEN
CONGRESSWOMEN
SENATOR
TRADE
SUPREME COURT
FRONTIERSMAN
POWERS
VIOLATE

AMENDMENT
STATE RIGHTS
AMBASSADOR
FREE SPEECH
NEUTRAL POLICY
NAVY
BOOM
FREE PRESS

WEST INDIES
IMPRESSMENT
MISSISSIPPI RIVER
DECLARE WAR
MERCHANT
PUBLIC TRIAL
SUPREMACY
FREE ASSEMBLY

C O N G R E S S W O M E N S E N A T O R
O T R A D E S U P R E M E C O U R T N M
N F P F X W U A M E N D M E N T O P A E
G R U R O R P F R E E S P E E C H C V R
R E B O N P R A M B A S S A D O R W Y C
E E L N F R E E A S S E M B L Y M E X H
S P I T X X M W E S T I N D I E S R O A
S R C I S T A T E R I G H T R S T S W N
M E T E E N C F R E E R E L I G I O N T
E S R R M C Y I M P R E S S M E N T O O
N S I M N E U T R A L P O L I C Y O N O
T O A A M I S S I S S I P P I R I V E R
D O L N S T A T E R I G H T S B O O M P
D E C L A R E W A R V I O L A T E O X O

II. Matching: Match each word in column A with the explanation or definition in column B. Write the number of each answer in the space provided.

A	B
____ a. boundary	1. a formal agreement between two or more states.
____ b. frontiersman	2. the highest federal court in the U.S. consisting of nine justices and having jurisdiction over all other courts in the nation.

____ c. jury	3. a policy of favoring neither one side nor the other in a dispute, conflict, or war.
____ d. cabinet	4. a body of persons sworn to judge and give a verdict on a given matter.
____ e. impressment	5. one who lived in the western edge of the settled territory.
____ f. neutrality	6. the system of fundamental laws and principles that prescribes the nature, functions, and limits of a government.
____ g. Constitution	7. a body of persons appointed by a chief of state or a prime minister to head the executive departments of the government.
____ h. Supreme Court	8. something that indicates a border or limit.
____ i. amendment	9. a change, addition, or correction in a constitution.
____ j. Treaty	10. a British practice exercised before the war of 1812, of taking men from American ships, forcing them to serve in the British Navy.

III. True or False:

Read each statement. Put a T next to each statement if it is true. Put an F in that space if it is false.

____ 1. Federal supremacy means that a state cannot make a law that conflicts with a national law or the United States Constitution.

____ 2. The national government has the power to make laws for the whole country.

____ 3. The members in Congress are called Congressmen, Congresswomen, and Senators.

____ 4. The President of the United States serves a term of six years.

____ 5. The Supreme Court is the highest court in the state.

____ 6. After the Revolutionary War, there had been good feelings between Great Britain and the United States.

____ 7. The British government ordered its navy to seize all ships carrying goods to or from France.

____ 8. American sailors were forced into the French navy. This practice was called impressment.

____ 9. John Jay was sent to England to settle the differences between the two countries.

____10. In 1795, Spain signed a treaty with the U.S. This treaty settled the boundaries between the U.S. and West Florida.

IV. Fill in the blanks:

Complete each statement by writing the correct word or group of words in the blanks: trading, Bill of Rights, Supreme Court, international, supremacy, federal government, executive branch, captured, treaty, amendments.

1. Federal __________ means that a state cannot make laws that conflict with a national law.
2. People who talk about the government of the United States frequently use the term ______________ .
3. After the laws are passed by the Congress, they are sent to the __________ to be enforced.
4. The judicial branch in the federal government is the ____________ and many low level courts.
5. The new Congress wrote ten ____________ to the Constitution.
6. The first ten amendments were called the ___________ .
7. The new American government had their own policy that was not to get involved in ____________ problems.
8. American merchants quickly increased __________ with the West Indies.
9. Hundreds of American ships and a lot of cargoes were ___________ by the British.
10. The ___________ with Spain pleased the farmers and frontiersmen because they could use the Mississippi River to carry farm products to the sea ports.

ការអាន

៧-១ រដ្ឋាភិបាលថ្មី និង ផ្នែកទាំងបីរបស់ខ្លួន

៧-១-១ រដ្ឋធម្មនុញ្ញគ្មានអ្វីក្រៅតែពីគំរោងការដើម្បីសំរាប់បង្កើតរដ្ឋាភិបាលប៉ុណ្ណោះទេឡើយ ។ រដ្ឋាភិបាលពិតប្រាកដ ដែលគេបង្កើតឡើង គឺនៅពេលដែលរដ្ឋធម្មនុញ្ញបានត្រូវគេចាប់ដាក់អោយប្រតិបត្តិឡើងនៅរយៈឆ្នាំ ១៧៨០ដែរ ។ មានគំនិតដ៏សំខាន់ៗពីរដែលបានស្តីអំពីរឿងរបៀបគ្រប់គ្រងប្រទេស នៅក្នុងរដ្ឋធម្មនុញ្ញនោះ ។ មួយដែលមានឈ្មោះថា "ភាពខ្លាំងជាងគេរបស់សហរដ្ឋ" គឺមានន័យថា រដ្ឋនិមួយក្នុងសហរដ្ឋមិនអាចបង្កើតច្បាប់ណា ដែលមានការប្រឆាំងគ្នាជាមួយច្បាប់របស់រដ្ឋធម្មនុញ្ញ នៃ ស-រ-អា ទេឡើយ ។ គំនិតដ៏សំខាន់មួយទៀត ដែលរួមបញ្ចូលទៅនឹងរបៀបគ្រប់គ្រងរបស់សហរដ្ឋ មានឈ្មោះហៅថា "ច្បាប់របស់រដ្ឋ" ។ ច្បាប់រដ្ឋនេះមានន័យថា រដ្ឋាភិបាលរបស់សហរដ្ឋ ឬ រដ្ឋាភិបាលកណ្តាលមិនអាចប្រព្រឹត្តអំពើណាមួយ ដែលធ្វើអោយមានការប្រឆាំងជាមួយនឹងច្បាប់របស់រដ្ឋឯទៀតៗ ដូចបានចែងនៅក្នុងរដ្ឋធម្មនុញ្ញរួចមកហើយ។ គំនិតដ៏សំខាន់ទាំងពីរនេះបានតំរូវអោយរដ្ឋាភិបាលកណ្តាល និង រដ្ឋឯទៀតៗ ដែលនៅក្នុងសហរដ្ឋ មានការគោរពសិទ្ធិ និង អំណាចរបស់គ្នាទៅវិញទៅមក ។

៧-១-២ ប្រជាពលរដ្ឋដែលបាននិយាយអំពីរដ្ឋាភិបាលរបស់ ស-រ-អា តែងតែយកពាក្យរដ្ឋាភិបាលកណ្តាលមកប្រើជារឿយៗ ។ នៅក្នុងរបៀបគ្រប់គ្រងចាត់ចែងរបស់រដ្ឋាភិបាលកណ្តាលពីរថ្នាក់ ដែលធ្វើការបំរើប្រជាពលរដ្ឋតែមួយ ។

៧-១-៣ រដ្ឋាភិបាលកណ្តាលមានអំណាច និង ធ្វើច្បាប់សំរាប់ប្រទេសទាំងមូល ។ បន្ទាប់ពីច្បាប់ទាំងនេះទទួលការអនុម័តពីរដ្ឋសភារួចហើយ គេត្រូវបញ្ជូនអោយទៅផ្នែកខាងនីតិប្រតិបត្តិ - ប្រធានាធិបតី - ដើម្បីសំរាប់ដាក់អោយប្រតិបត្តិតាម ។ រដ្ឋសភាក៏ត្រូវបានទទួលអំណាចបន្ថែមទៀត ក្នុងការរៀបចំបង្កើតច្បាប់សំរាប់ដកហូតពន្ធអាករ ត្រួតត្រាទៅលើជំនួញរវាងរដ្ឋ និង រវាងប្រទេសក្រៅ ធ្វើការប្រកាសសង្គ្រាម និង បង្កើតតុលាការដែលនៅក្រោមតុលាការជាន់ខ្ពស់ ។ សមាជិកប្រុស ឬ ស្រី របស់រដ្ឋសភា មានឈ្មោះហៅថា ពួកសភា ឬ តំណាងរាស្ត្រ (Congressmen, Congresswomen) និងសមាជិកព្រឹទ្ធសភា (Senators) ។ ពួកសភាត្រូវបានគេជ្រើសតាំងអោយនៅក្នុងសភាតំណាងរាស្ត្រ (House of Representatives) តាមរយៈ - មានពីរឆ្នាំក្នុងរយៈ - ឯចំណែកព្រឹទ្ធសភាវិញ គឺមានពីររូបពីរដ្ឋនិមួយៗ ហើយដែលរយៈរបស់ខ្លួនមានចំនួន ៦ ឆ្នាំ ។ ក្នុងពេលសព្វថ្ងៃនេះ មានពួកតំណាងរាស្ត្រចំនួន

៤៣២ នាក់ នៅក្នុងសភាជំណាងរាស្ត្រ និង មានសមាជិកព្រឹទ្ធសភាចំនួន ១០០ នាក់ នៅក្នុងព្រឹទ្ធសភា ។ សភាជំណាងរាស្ត្រ ជាអ្នកតែងច្បាប់ ហើយព្រឹទ្ធសភា ជាអ្នកអោយសច្ចានុមតិ យល់ព្រមចំពោះច្បាប់ទាំងនោះ ។ ព្រឹទ្ធសភា ព្រមទាំងមានអំណាច ក្នុងការសំរេចយល់ព្រមចំពោះសន្ធិសញ្ញា ដែល ស-រ-អា បានធ្វើឡើងជាមួយនឹងប្រទេសឯទៀតៗ និង សំរាប់អោយសច្ចានុមតិដល់មនុស្ស ដែលលោកប្រធានាធិបតី បានជ្រើសរើសអោយកាន់កាប់កិច្ចការពិសេសណាមួយ ដូចជា ឯកអគ្គរដ្ឋទូត និង មន្ត្រីរដ្ឋការជាន់ខ្ពស់ផង ។

៨-១-៤ ផ្នែកទីពីររបស់រដ្ឋាភិបាល គឺ ផ្នែកខាងនីតិប្រតិបត្តិ ។ ផ្នែកនេះបង្កើតឡើងសំរាប់ដាក់អោយប្រតិបត្តិ នូវច្បាប់ទាំងប៉ុន្មាន ដែលរដ្ឋសភាបានតែងរួចមកហើយ ។ នៅក្នុងផ្នែកនីតិប្រតិបត្តិនេះ អំណាចទាំងប៉ុន្មានត្រូវនៅក្នុងកណ្តាប់ដៃរបស់ប្រធានាធិបតីទាំងអស់ ។ ប្រធានាធិបតីអាចធ្វើការបដិសេធ និង បញ្ឈប់នូវច្បាប់ ដែលលោកមិនពេញចិត្ត ។ ប្រធានាធិបតីកាន់ដំណែងរបស់ខ្លួនតាមរយៈ ដែលមានបួនឆ្នាំក្នុងមួយរយៈ ហើយលោក : មានអនុប្រធានាធិបតី និង គណៈរដ្ឋមន្ត្រីសំរាប់ជួយកាន់កាប់កិច្ចការនៅក្នុងរដ្ឋាភិបាល ។

៨-១-៥ ផ្នែកទីបីរបស់រដ្ឋាភិបាល គឺ ផ្នែកខាងតុលាការ ។ ផ្នែកនេះមានតុលាការជាន់ខ្ពស់ និង តុលាការបន្ទាប់បន្សំឯទៀតជាច្រើន ។ មុខងារដ៏សំខាន់របស់ផ្នែកខាងតុលាការនេះ គឺ ដើម្បីសំរាប់ពន្យល់បកស្រាយពីច្បាប់របស់ ស-រ អា ។ តុលាការជាន់ខ្ពស់ គឺជាតុលាការថ្នាក់ខ្ពស់បំផុតនៅក្នុងរបៀបគ្រប់គ្រងប្រទេស ហើយដែលមានអំណាចប្រាប់ទៅដល់រដ្ឋសភា ឬ ក៏រដ្ឋណាមួយ ដែលបានបង្កើតច្បាប់ខុសបំពានទៅនឹងរដ្ឋធម្មនុញ្ញប្រទេស ។

៨-២- ច្បាប់សិទ្ធិមនុស្ស

៨-២-១ នៅពេលដែលរដ្ឋធម្មនុញ្ញបានទទួលសច្ចានុមតិបង្កើតឡើង មនុស្សជាច្រើនមានការពេញចិត្តយ៉ាងខ្លាំងចំពោះច្បាប់ទាំងប៉ុន្មាន ដែលនៅក្នុងរដ្ឋធម្មនុញ្ញនោះ ។

ក៏ប៉ុន្តែមានមនុស្សជាច្រើននាក់ទៀត ដែលយល់ឃើញថា រដ្ឋធម្មនុញ្ញនេះមិនបានជួយការពារសិទ្ធិមនុស្សអោយបានគ្រប់គ្រាន់ទេឡើយ ។ ដើម្បីនឹងចង់ធ្វើអោយប្រជាពលរដ្ឋមានជំនឿទាំងស្រុងទៅលើរដ្ឋធម្មនុញ្ញ រដ្ឋសភាថ្មីក៏បានចាប់ធ្វើសេចក្តីកែប្រែនូវច្បាប់ ១០ សំរាប់រដ្ឋធម្មនុញ្ញ ។ ការកែប្រែនូវច្បាប់ ១០ ដំបូងនេះមានឈ្មោះហៅថា " ច្បាប់សិទ្ធិមនុស្ស " ។ ច្បាប់នេះបានប្រគល់អោយដល់ប្រជាជនដែលរស់នៅក្នុង ស-រ-អា នូវសិទ្ធិសេរីភាពយ៉ាងសំខាន់ៗ ដូចជា សេរីភាពខាងការនិយាយ សេរីភាពខាងការសរសេរកាសែត ឬ សារពតមាន សេរីភាពខាងការប្រជុំគ្នា ការរួចផុតពីការឆែកឆេរ ដោយពុំសមហេតុសមផល និង សិទ្ធិសេរីភាពខាងការកាត់សេចក្តីអោយបានសមរម្យ ដោយពួកគណៈវិនិច្ឆ័យ ។

៨-២-២ នេះជាការសំខាន់ណាស់ដែលគេត្រូវចងចាំថា ច្បាប់ទាំងនេះបានបង្កើត

ឡើងក្នុងគោលបំណងនឹងចង់ជួយដល់ប្រជាពលរដ្ឋទាំងអស់ ។ បើមនុស្សណាបានប្រព្រឹត្តល្មើសឈ្លានពានទៅលើសិទ្ធិសេរីភាពរបស់អ្នកដទៃ មនុស្សនោះក៏មិនអាចយកសិទ្ធិសេរីភាពទាំងនោះ មកប្រើសំរាប់ខ្លួនឯងដែរ ។ តុលាការមានករណីយកិច្ចនឹងធ្វើការសំរេច បើសិនជាមានមនុស្សណាបានយកសិទ្ធិសេរីភាពនេះទៅប្រព្រឹត្តល្មើសលើសិទ្ធិសេរីភាពរបស់មនុស្សដទៃទៀត ។

៧.៣ ប្រទេសថ្មីត្រូវជួបប្រទះនឹងបញ្ហាផ្នែកក្រៅថ្មីទៀត

៧.៣.១ នៅជំនាន់រយៈឆ្នាំ ១៧៩០ ស.រ.អ មានអ្នករស់នៅជិតខាងពីផ្នែកអ៊ឺរ៉ុប ដែលស្ថិតនៅលើទ្វីបអាមេរិកខាងជើងដែរ ។ ចក្រភពអង់គ្លេស ស្ថិតនៅផ្នែកខាងជើង និង ផ្នែកខាងជើងឆៀងខាងលិច ។ ចក្រភពអេស្ប៉ាញស្ថិតនៅផ្នែកខាងត្បូង និងខាងលិច ។ រដ្ឋាភិបាលថ្មីរបស់អាមេរិកាំង មានច្បាប់របស់ខ្លួនមួយ ដែលថាមិនត្រូវលូកដៃចូលក្នុងបញ្ហាអន្តរជាតិឡើយ ។ នយោបាយនេះមានឈ្មោះហៅថា "នយោបាយអព្យាក្រឹត" ។ នយោបាយនេះបានដឹកនាំ ស.រ.អ បានយ៉ាងសុខស្រួលអស់ជិតរយៈពេល ២០ ឆ្នាំ ក្នុងការទាក់ទងជាមួយប្រទេសក្រៅ ។

៧.៣.២ បន្ទាប់ពីសង្គ្រាមបដិវត្តន៍មក ស.រ.អ និង អង់គ្លេស ក៏ចាប់មានគំនិតមិនសូវស្រួលនឹងគ្នា ។ ស្ថានការណ៍នេះរិតតែមានភាពធ្ងន់ធ្ងរឡើងនៅឆ្នាំ ១៧៩៣ គឺនៅពេលដែលប្រទេសបារាំង បានចាប់ផ្ដើមបើកកំពង់ផែខ្លួនជាច្រើននៅផ្នែកខាង West Indies ដើម្បីសំរាប់ធ្វើជំនួញជាមួយប្រទេសអព្យាក្រឹត ។ នៅពេលនោះ ពួកអ្នកជំនួញអាមេរិកាំងក៏បានចាប់ផ្ដើមជំនួញរបស់ខ្លួន ជាមួយនឹង West Indies ដែរ ។ អស់រយៈពេលយ៉ាងខ្លីក្រោយមក ជំនួញរបស់គេក៏បានរីកដុះដាលយ៉ាងខ្លាំង ។ នៅពេលនោះសង្គ្រាមរវាងអង់គ្លេស និង បារាំង មិនទាន់បានចប់នៅឡើយ ហេតុដូច្នេះហើយបានជារដ្ឋាភិបាលអង់គ្លេសបញ្ជាអោយកងនាវាចររបស់ខ្លួនចាប់ឃុំទុកនូវកប៉ាល់ណា ដែលដឹកនាំគ្រឿងសម្ភារៈទៅនឹងមកពីប្រទេសបារាំង និង ប្រទេសចំណុះបារាំង ។ នៅពេលនោះកប៉ាល់អាមេរិកាំងជាច្រើនរយ ព្រមទាំងគ្រឿងរបស់របរផងបានត្រូវអង់គ្លេសចាប់ទុកដែរ ហើយដែលមានកម្មករនាវាជាច្រើននាក់បានត្រូវអង់គ្លេសចាប់យកអោយចូលទៅធ្វើការក្នុងកងនាវាចរអង់គ្លេសទៀតផង ។ អំពើនេះមានឈ្មោះហៅថា ការចាប់ចងយកមនុស្សអោយទៅធ្វើការទាំងបង្ខំ ។ រដ្ឋាភិបាល ស.រ.អ ចង់ធ្វើការដោះស្រាយរឿងនេះដោយការចរចាគ្នា ។ គេបានបញ្ជូនលោក John Jay អោយទៅប្រទេសអង់គ្លេស ដើម្បីនឹងដោះស្រាយពីរឿងនេះ ។ លោក Jay បានចុះសន្ធិសញ្ញាជាមួយអង់គ្លេស ដែលបានចែងថា អង់គ្លេសសុខចិត្តដកទ័ពរបស់ខ្លួនចេញពីផ្នែកខាងជើងឆៀងខាងលិចនៃទ្វីបអាមេរិកខាងជើង ហើយគេបានអនុញ្ញាតអោយអាមេរិកាំងធ្វើជំនួញជាមួយផ្នែកខាង

West Indies របស់អង់គ្លេសទៀតផង ។ ដើម្បីនឹងតបស្នងទៅវិញ ស-រ-អា ត្រូវចេញសងសំណូវបំណុលទាំងប៉ុន្មាន កាលពីជំនាន់សង្គ្រាមបដិវត្តន៍អោយទៅអង់គ្លេសវិញទាំងអស់ ។

៧-៣-២ សន្ធិសញ្ញាលោក Jay នេះព្រមទាំងបានណែនាំធ្វើអោយមានការព្រមព្រៀងឈប់ឈ្លោះប្រកែកគ្នារវាង ស-រ-អា និង អេស្ប៉ាញទៀតផង ។ អេស្ប៉ាញមានជំនឿថា ប្រហែលជា ស-រ-អា នេះហើយដែលជាអ្នកបង្កបង្កើតអោយមានជារឿងហេតុដល់ខ្លួននៅទ្វីបអាមេរិក ។ ក៏ប៉ុន្តែបន្ទាប់ពីទាស់ទែងគ្នារវាង ស-រ-អា និង អង់គ្លេសបានបញ្ចប់មក នៅចុងឆ្នាំ ១៧៩៥ អេស្ប៉ាញក៏ចុះសន្ធិសញ្ញាជាមួយ ស-រ-អា ដែរ ។ សន្ធិសញ្ញានេះបានដោះស្រាយអោយបានរួចស្រឡះពីបញ្ហាព្រំដែនរវាង ស-រ-អា និង តំបន់ Florida ផ្នែកខាងលិច ហើយព្រមទាំងបានបើកសិទ្ធិអោយនាវាដឹកនាំអាមេរិកាំងបើកបរតាមទន្លេ Mississippi និង ប្រើប្រាស់ផែកំពង់នៅ New Orleans ទៀតផង ។ ពួកកសិករ និង ពួកដែលរស់នៅតាមកន្លែងឆ្ងាយៗ មានការពេញចិត្តជាខ្លាំងចំពោះសន្ធិសញ្ញានេះ ពីព្រោះគេអាចប្រើប្រាស់ទន្លេ Mississippi ដើម្បីសំរាប់ដឹកនាំជូនគ្រឿងផលិតផលកសិកម្មរបស់គេទៅកាន់ផែសមុទ្រធំៗ បានងាយស្រួល ។ បន្ទាប់ពីបានចុះសន្ធិសញ្ញាជាមួយអង់គ្លេស និង អេស្ប៉ាញមក ប្រជាពលរដ្ឋអាមេរិកាំងអាចរស់នៅបានសុខសន្តិភាព និង អាចរៀបចំខ្លួនទៅក្នុងពេលអនាគតផង ។

ការហាត់

១- របៀបរកពាក្យ

សេចក្ដីណែនាំ : សូមរក និង គូសរង្វង់មូលជុំវិញនូវពាក្យទាំង ២៤ នៅក្នុងរបៀបរកពាក្យខាងក្រោម ។ ពាក្យទាំងអស់នេះអាចរកឃើញតាមរបៀបបញ្ឈរ ផ្ដេក និងបញ្ច្រាង ៗ នៅពេលដែលរកឃើញនូវពាក្យនិមួយៗ សូមសរសេរដាក់នៅលើក្រដាសព្រមទាំងអោយអត្ថន័យនៃពាក្យនោះផង ។

CONGRESSMEN
CONGRESSWOMEN
SENATOR
TRADE
SUPREME COURT
FRONTIERSMAN
POWERS
VIOLATE

AMENDMENT
STATE RIGHTS
AMBASSADOR
FREE SPEECH
NEUTRAL POLICY
NAVY
BOOM
FREE PRESS

WEST INDIES
IMPRESSMENT
MISSISSIPPI RIVER
DECLARE WAR
MERCHANT
PUBLIC TRIAL
SUPREMACY
FREE ASSEMBLY

C O N G R E S S W O M E N S E N A T O R
O T R A D E S U P R E M E C O U R T N M
N F P F X W U A M E N D M E N T O P A E
G R U R O R P F R E E S P E E C H C V R
R E B O N P R A M B A S S A D O R W Y C
E E L N F R E E A S S E M B L Y M E X H
S P I T X X M W E S T I N D I E S R O A
S R C I S T A T E R I G H T R S T S W N
M E T E E N C F R E E R E L I G I O N T
E S R R M C Y I M P R E S S M E N T O O
N S I M N E U T R A L P O L I C Y O N O
T O A A M I S S I S S I P P I R I V E R
D O L N S T A T E R I G H T S B O O M P
D E C L A R E W A R V I O L A T E O X O

146

២. របៀបប្រៀបផ្ទឹម

សូមប្រៀបធៀបពាក្យ ដែលនៅខាងឆ្វេង ក្រោមបន្ទាត់អក្សរ A ទៅនឹងអត្ថន័យ ឬ សេចក្ដីពន្យល់ដែលនៅខាងស្ដាំ ក្រោមបន្ទាត់អក្សរ B ដោយសរសេរចម្លើយជាលេខ នៅក្នុងកន្លែងទំនេរពីខាងមុខផង ។

	A	B
____________	ក. ព្រំប្រទល់	១. ជាកិច្ចព្រមព្រៀងជាផ្លូវការរវាងប្រទេសពីរ ឬលើសពីពីរ
____________	ខ. អ្នករស់នៅតាមកន្លែងដាច់ឆ្ងាយដែលមិនទាន់មានមនុស្សទៅដល់	២. ជាតុលាការជាន់ខ្ពស់បំផុតនៅក្នុង ស.រ.អា ដែលមានចៅក្រម ៩ នាក់ហើយ ដែលអាចត្រួតត្រាទៅលើតុលាការទាំងប៉ុន្មានក្នុងប្រទេសផង ។
____________	គ. គណៈវិនិច្ឆ័យ	៣. ជានយោបាយមិនលំអៀងទៅខាងបក្សណាមួយ ក្នុងពេលដែលមានការឈ្លោះប្រកែក ឬ ក៏ច្បាំងគ្នា ។
____________	ឃ. គណៈរដ្ឋមន្ត្រី	៤. ជាមនុស្សមួយក្រុម ដែលតុលាការជ្រើសរើសឡើងសំរាប់អោយធ្វើសេចក្ដីសំរេចក្នុងការកាត់សេចក្ដីអ្វីមួយ ។
____________	ង. ការចាប់អោយធ្វើការអ្វីមួយដោយបង្ខំ	៥. ជាអ្នករស់នៅតាមផ្នែកខាងលិចដែលជាតំបន់ទើបតែផ្សះផ្សាស្អារួចហើយ ។
____________	ច. អព្យាក្រឹត	៦. ជាគ្រឹះ ឬ មូលដ្ឋាននៃច្បាប់ដែលយកមកធ្វើជាគោលការណ៍សំរាប់ដាក់ជាបញ្ញត្តិកំណត់នូវរបៀបធ្វើការក្នុងរដ្ឋាភិបាល ។
____________	ឆ. រដ្ឋធម្មនុញ្ញ	៧. ជាមនុស្សមួយក្រុម ដែលបានជ្រើសតាំងឡើងដោយប្រមុខរដ្ឋ ឬ រដ្ឋមន្ត្រីទីមួយ ដើម្បីសំរាប់អោយដឹកនាំនូវក្រសួងធំៗក្នុងរដ្ឋាភិបាល

__________ ជ. តុលាការជាន់ខ្ពស់	៨. ជាអ្វីៗដែលសំរាប់គូសបំណាច់ថាជាព្រំដែនរបស់ខ្លួន ។
__________ ឈ. សេចក្ដីកែប្រែច្បាប់	៩. ការប្ដូរ បូកបន្ថែម ឬ ក៏កែកអោយបានត្រឹមត្រូវនូវរដ្ឋធម្មនុញ្ញ ។
__________ ញ. សិទ្ធិសញ្ញា	១០. ជារបៀបអនុវត្តដោយពួកអង់គ្លេសនៅមុនសង្គ្រាមនៃឆ្នាំ ១៨១២ គឺចាប់បង្ខំយកមនុស្សពីកប៉ាល់អាមេរិកាំងអោយចូលទៅធ្វើការក្នុងនាវាចរអង់គ្លេស ។

៣. ពិត ឬ មិនពិត

សូមមើលឃ្លានិមួយៗ ហើយសរសេរដាក់ជាអក្សរ T នៅពីមុខឃ្លាណា ដែលយល់ថាពិតត្រឹមត្រូវ និង អក្សរ F នៅពីមុខឃ្លាណាដែលមិនពិត ។

__________ ១. ភាពខ្លាំងជាងគេរបស់សហរដ្ឋ បានសំដៅថា រដ្ឋនិមួយៗមិនអាចនឹងធ្វើច្បាប់ណាដែលនាំអោយមានការប្រឆាំងប្រទាំងនឹងច្បាប់របស់សហរដ្ឋ ឬ ក៏រដ្ឋធម្មនុញ្ញ របស់ ស-រ-អា ទៀត ។

__________ ២. រដ្ឋាភិបាលកណ្ដាលមានអំណាច និង បង្កើតច្បាប់អោយប្រទេសទាំងមូលបាន ។

__________ ៣. សមាជិករបស់រដ្ឋសភាមានឈ្មោះហៅថា ពួកតំណាងរាស្ត្រ និង ពួកព្រឹទ្ធសភា ។

__________ ៤. តំណែងរបស់ប្រធានាធិបតីនៃ ស-រ-អា មានចំនួន ៦ ឆ្នាំ ក្នុងមួយរយៈ ។

__________ ៥. តុលាការជាន់ខ្ពស់ ជាតុលាការថ្នាក់ខ្ពស់នៅក្នុង ស-រ-អា ។

__________ ៦. បន្ទាប់ពីសង្គ្រាមបដិវត្តន៍មក ស-រ-អា និង អង់គ្លេស ក៏ចាប់មានជិតស្និតស្រុះស្រួលជាមួយគ្នាទៀត ។

__________ ៧. រដ្ឋាភិបាលអង់គ្លេសបានបញ្ជាលអោយកងនាវាចររបស់ខ្លួនចាប់ទុកនូវកប៉ាល់ដឹកនាំទំនិញទាំងប៉ុន្មាន ដែលធ្វើដំណើរចេញចូលទៅប្រទេសបារាំង ។

__________ ៨. កម្មករនាវាអាមេរិកាំងបានត្រូវគេចាប់បញ្ជូនអោយទៅធ្វើការក្នុងកងនាវាចរបារាំង ។ របៀបអនុវត្តនេះមានឈ្មោះហៅថាការចាប់មនុស្សយកទៅទាំងបង្ខំដើម្បីសំរាប់អោយធ្វើការអ្វីមួយ ។

__________ ៩. លោក John Jay បានត្រូវរដ្ឋាភិបាលអាមេរិកាំងបញ្ជូនអោយទៅប្រទេសអង់គ្លេស ដើម្បីសំរាប់អោយជជែកដោះស្រាយពីបញ្ហារវាងប្រទេសទាំងពីរ ។

__________ ១០. នៅឆ្នាំ ១៧៩៥ អេស្ប៉ាញបានចុះសន្ធិសញ្ញាជាមួយ ស.រ.អា ។ សន្ធិសញ្ញានេះបានជួយដោះស្រាយអោយបានរួចស្រេចនូវរឿងព្រំប្រទល់រវាង ស.រ.អា និង តំបន់ Florida ផ្នែកខាងលិច ។

១០. ការបំពេញក្នុងកន្លែងទំនេរៈ

សូមបំពេញនូវឃ្លានីមួយៗ ដោយជ្រើសរើសយកពាក្យ ឬ ក្រុមនៃពាក្យ ដែលឃើញថាសមត្រឹមត្រូវ ដើម្បីដាក់បំពេញក្នុងកន្លែងទំនេរ ។ ពាក្យទាំងនោះមាន ៖ ដំណួញ - ច្បាប់សិទ្ធិមនុស្ស - តុលាការជាន់ខ្ពស់ - អន្តរជាតិ - ភាពខ្លាំងជាងគេ - រដ្ឋាភិបាលកណ្តាល - និតិប្រតិបត្តិ - ចាប់ទុក - សន្ធិសញ្ញា - និង - សេចក្តីកែប្រែច្បាប់ ។

១. __________ របស់សហរដ្ឋ មានន័យថា រដ្ឋនីមួយៗមិនអាចបង្កើតច្បាប់ណាដែលធ្វើអោយមានការប្រឆាំងប្រទាំងជាមួយនឹងច្បាប់ប្រទេសទៀយ ។

២. ប្រជាពលរដ្ឋដែលបាននិយាយអំពីរដ្ឋាភិបាលរបស់ ស.រ.អា តែងតែយកពាក្យ __________ មកប្រើជារឿយៗ ។

៣. បន្ទាប់ពីច្បាប់ទាំងនោះបានទទួលការអនុម័តលើរដ្ឋសភារួចហើយ គេក៏ត្រូវបញ្ជូនអោយទៅខាងផ្នែក __________ ដើម្បីសំរាប់អោយដាក់អនុវត្តតាម ។

៤. ផ្នែកខាងតុលាការនៃរដ្ឋាភិបាលកណ្តាល គឺមាន __________ និង តុលាការបន្ទាប់បន្សំជាច្រើនថែមទៀត ។

៥. រដ្ឋសភាថ្មីបានធ្វើ __________ ដាក់សំរាប់រដ្ឋធម្មនុញ្ញ ។

៦. សេចក្តីកែប្រែច្បាប់ ១០ ដំបូងនេះឈ្មោះហៅថា __________

៧. រដ្ឋាភិបាលថ្មីរបស់ ស.រ.អា មាននយោបាយរបស់ខ្លួនមួយ គឺមិនលូកដៃចូលរឿង __________ ។

៨. ពាណិជ្ជករអាមេរិកាំងបានបង្កើន __________ ខ្លួនយ៉ាងរហ័សជាមួយខាងផ្នែក West Indies

៩. កប៉ាល់អាមេរិកាំងរាប់រយ ព្រមទាំងគ្រឿងសម្ភារៈរបស់ខ្លួនបានត្រូវ
កងនាវាចរអង់គ្លេស _________ ។

១០. ___________ជាមួយអេស្បាញ បានធ្វើអោយ កសិករ និង
ពួកដែលរស់នៅតាមកន្លែងឆ្ងាយៗ មានការពេញចិត្តជាខ្លាំង ពីព្រោះ
ពួកគេអាចប្រើប្រាស់ទន្លេ Mississippi
ដើម្បីសំរាប់ដឹកនាំផលិតផលកសិកម្មនោះទៅកាន់ផែសមុទ្របានយ៉ាង
ស្រួល ។

Packet 8: THE FIRST UNITED STATES GOVERNMENT

NEW WORDS & USAGES: ពាក្យថ្មីៗ និង ការប្រើប្រាស់

individual: មនុស្សម្នាក់ៗ

The Bill of Rights protects the rights of individuals as well as those of the states.

electoral college: សភាឆ្នោតប្រជារាស្ត្រ

The electoral college chose George Washington as the first President of the United States.

judiciary act: សេចក្តីសំរេចខាងផ្នែកតុលាការ

Congress passed the first judiciary act in 1789 to set up the Supreme Court.

associate justice: ពួកចៅក្រមឯទៀតដែលធ្វើការជាមួយចៅក្រមជាន់ខ្ពស់

chief justice: ចៅក្រមជាន់ខ្ពស់ - ថ្នាក់បំផុត

There are eight associate justices and one chief justice in the U.S. Supreme Court.

precedent: អ្វីៗដែលមានខ ឬ ធ្វើឯដើម្បីសំរាប់ជាគំរូដល់ពួកក្រោយ

President Washington set up many precedents during his first term.

cabinet: គណៈរដ្ឋមន្ត្រី

The heads of all the government departments formed a cabinet.

provision: ខ ឬ ការផ្តល់ដែលមានចែង

The Constitution did not make any provision for a cabinet.

measure: វិធានការណ៍

Most Americans were against Hamilton's measures.

READING

8.1. THE FIRST PRESIDENT: GEORGE WASHINGTON

8.1.1. The Constitution needed to be ratified by nine states in order to go into effect. As a result of the debates over ratification, ten amendments were added to the Constitution to protect both the rights of **individuals** and those of the states. Under this new Constitution, one of the first things to be done was the election of a president. The Constitution said that the voters were to choose members of the **electoral college** who then would select the president. The electoral college chose George Washington as the first President of the United States.

8.1.2. President Washington took office in April 1789, in the temporary capital, New York City. By that time, a Congress, made up of a Senate and a House, had also been elected. In 1789, the Congress passed the first **judiciary act** that provided for a Supreme Court of six judges and a system of lower federal courts. President Washington named five **associate justices** of the Supreme Court and appointed John Jay as **chief justice**. The new Senate approved the President's nomination. The country now had a legislative, an executive, and a judicial branch. The new government was ready to work.

8.2. THE PRESIDENT AND THE CONSTITUTION

8.2.1. President Washington served as President for two terms or eight years. During those eight years, he established many precedents for future presidents. As the head of the executive branch, he knew that he could not do his job alone; he set up different governmental departments and appointed people to head these departments. Together, these people were called the cabinet. To his first cabinet, Washington named Thomas Jefferson as Secretary of State, Henry Knox as Secretary of War, and Alexander Hamilton became as the Secretary of the Treasury. These cabinet members also served as advisors to the President. The Constitution did not make any provision for a cabinet, but President Washington set the precedent, and his actions became a political custom to be followed by future presidents.

8.2.2. The new nation and the new government faced many problems. One of the most serious problems related to money and finance. When President Washington took office, the United States had a debt of millions of dollars and the United States treasury was almost empty. There was no system of taxation to bring in the money to pay these debts and to cover government expenses. The Secretary of the Treasury, Alexander Hamilton, wanted to take strong actions to save the new government from debt and ruin. He proposed a program which included the following points:

1. The new government agreed to pay all debts.

2. The federal government took over the debts of the states. Many of these debts were the results of expenses that states had during the Revolution.
3. The government was to raise funds through taxes. Hamilton also wanted to levy a tax on liquor produced within the country and raise the tariffs on imported goods. These tariffs were also meant to encourage American manufacturing.
4. The government chartered a national bank. The Bank of the United States would provide credit to the new federal government. It would also help to provide a strong currency for the country.

Hamilton's program was met with strong opposition. Northern states with heavy unpaid debts favored the program but Southern states did not like it because they had already arranged to pay their debts. The Southerners did not want to be taxed to pay northern debts.

8.2.3. There was also disagreement over the establishment of Bank of the United States. Thomas Jefferson and his followers argued that the Constitution did not mention this kind of power. Hamilton said that the power went along with the financial powers the Constitution gave to Congress. People began to take sides on this and other issues. This dispute led to something new in this young nation ---the formation of political parties.

8.3. THE FORMATION OF POLITICAL PARTIES

8.3.1. The program of the new government had helped bring good times to the United States but many Americans were against Hamilton's program. Hamilton's measures had caused divisions in the nation. They had divided the North from the South and the rich from the poor people. Many people had loaned money to Congress during the Revolution and had received notes stating that the government promised to pay back the money. But as the time went on, people began to doubt that the government would ever pay these notes in full. Therefore, many people sold their notes for less than they were worth. The buyers of the notes were often rich people who had knowledge of Hamilton's program. The losers were soldiers, farmers, and shopkeepers. They were very angry with Hamilton's measures, and they grouped together to oppose it.

8.3.2. The group supporting Hamilton was called the Federalists. They wanted the Constitution to be the supreme law of the land and they also wanted a strong central government. The Federalists also favored a loose interpretation of the Constitution that would give much power to the federal government. The Federalists were the wealthier Americans, such as landowners, merchants, lawyers, and bankers. They lived in New England and in the Middle states. They believed that the upper class should run the government, and they hoped to keep political power out of the hands of the common people. The Federalists were opposed by the Republican Party.

8.3.3. The two political parties had their first chance to test their strength in the presidential election in 1796. John Adams was chosen as the Federalist candidate for President and Thomas Pinckney was to run as Vice-President. Thomas Jefferson and Aaron Burr were the Republicans' choices. The electoral college vote in the 1796 election showed a weakness in the Constitution. The Constitution did not allow for two parties, each choosing separate candidates for president and vice-president. The Constitution stated that each member of the electoral college would vote for two candidates. Members did not indicate a choice of president or vice-president. The person who received the most votes would be president, and the person who received the next highest number of votes would be vice-president. Under this system, Adams, a Federalist, was elected president. However, Jefferson, a Republican, was elected Vice-President. The Federalists also won most of the seats in Congress; therefore, the Federalists were in power. From that time, political parties and their activities deeply influenced the life of Americans.

EXERCISES

I. Word search puzzle:

Directions: Find and circle the words in the word puzzle below. The words will be found vertically, horizontally, and diagonally. When you find a word in the puzzle, write it and then define it.

APRIL
LIQUOR
DEBT
CITY
WAR
TAX
RAISE

INDIVIDUAL
ELECTORAL COLLEGE
JUDICIARY ACT
ASSOCIATE JUSTICE
CHIEF JUSTICE
RATIFICATION
NOMINATION
CONSTITUTION

FUTURE
CABINET
SUPREME
MEASURE
JUDICIAL
APPOINT
PROBLEMS
PRODUCE

PRECEDENT
WASHINGTON
PROVISION
EXECUTIVE
LEGISLATIVE
DEPARTMENT
FUTURE

I	E	L	E	C	T	O	R	A	L	C	O	L	L	E	G	E	N	D
N	J	C	H	I	E	F	J	U	S	T	I	C	E	X	W	P	O	E
D	U	C	A	B	I	N	E	T	M	E	A	S	U	R	E	R	M	R
I	D	A	P	R	I	L	P	R	O	V	I	S	I	O	N	E	I	A
V	I	R	A	T	I	F	I	C	A	T	I	O	N	O	X	C	N	R
I	C	O	N	S	T	I	T	U	T	I	O	N	W	A	R	E	A	T
D	I	A	P	P	O	I	N	T	S	U	P	R	E	M	E	D	T	M
U	A	S	S	O	C	I	A	T	E	J	U	S	T	I	C	E	I	E
A	R	W	A	S	H	I	N	G	T	O	N	C	I	T	Y	N	O	N
L	Y	E	X	E	C	U	T	I	V	E	R	U	T	U	F	T	N	T
Y	A	V	O	L	E	G	I	S	L	A	T	I	V	E	T	A	X	O
E	C	B	I	C	H	O	J	U	D	I	C	I	A	L	D	E	B	T
U	T	A	P	P	O	I	N	T	P	R	O	B	L	E	M	S	O	X
L	I	Q	U	O	R	P	R	O	D	U	C	E	R	A	I	S	E	D

II. Matching: Match each word in column A with the

explanation or definition in column B. Write the number of each answer in the space provided.

A	B
____ a. tariff	1. a person who seeks or is nominated for an office, prize, or honor.
____ b. candidate	2. a body of electors chosen to elect the President and Vice-President of the United States.
____ c. Chief Justice	3. an alcoholic beverage made by distillation rather than by fermentation.
____ d. individual	4. tax or duty imposed by a government on imported or exported goods.
____ e. precedent	5. a place where treasure is kept stored.
____ f. treasury	6. an act or instance that may be used as an example in dealing with subsequent similar cases.
____ g. electoral college	7. relating to a single human being, by or for one person.
____ h. liquor	8. the presiding judge of a high court having several judges, especially the U.S. Supreme Court.

III. True or False:

Read each statement. Put a T next to each statement if it is true. Put an F in that space if it is false.

____ 1. Under this new Constitution, one of the first things to be done was the election of a president.

____ 2. The electoral college chose George Washington as the first President of the United States.

____ 3. The Constitution had a provision for a cabinet.

____ 4. One of the most serious problems of the new government related to money and finance.

____ 5. There was no system of taxation to bring in the money to pay the national debts.

____ 6. Hamilton's program was met with strong opposition.

____ 7. There was also disagreement over the establishment of the Bank of the United States.

____ 8. Hamilton's measures had caused divisions in the nation.

____ 9. The Federalists were wealthier Americans.

____10. The political parties and their activities deeply influenced the life of Americans.

IV. Fill in the blanks:

Complete each statement by writing the correct word or group of words in the blanks: interpretation, temporary, advisors, Treasury, electoral college, political parties, precedents, associate judge, executive branch, terms.

1. The Constitution said that the voters were to choose

members of the _________ who then would elect the president.

2. President Washington took office in April, 1789 in the __________ capital, New York City.
3. President Washington served as President for two ________, or eight years.
4. The two _________ had their first chance to test their strength in the presidential election of 1796.
5. The Federalists favored a loose ____________ of the Constitution that gave much power to the federal government.
6. President Washington set up many ____________ during his first term.
7. President Washington named five ___________ of the Supreme Court.
8. The U.S. ___________ was almost empty when President Washington took office.
9. The cabinet members also served as ___________ to the President.
10. As the head of the ___________ , President Washington knew that he could not do his job alone.

ការអាន

៨.១ ប្រធានាធិបតីលើកទីមួយ : លោក George Washington

៨.១.១ រដ្ឋធម្មនុញ្ញត្រូវទទួលសច្ចានុមតិយល់ព្រមពីរដ្ឋ ៩ សិន ដើម្បីមុននឹងអាចចាប់ដាក់អោយអនុវត្តបាន ។ លទ្ធផលដែលបានមកពីការជជែកពិភាក្សាពីរឿងអោយសច្ចានុមតិនេះ គឺគេត្រូវដាក់បន្ថែមសេចក្តីកែប្រែបញ្ជាប់ ១០ ទៀតទៅក្នុងរដ្ឋធម្មនុញ្ញ ដើម្បីសំរាប់ការពារសិទ្ធិសេរីភាពរបស់មនុស្សម្នាក់ៗ ព្រមទាំងសិទ្ធិរបស់រដ្ឋទៀតផង ។ នៅក្រោមរដ្ឋធម្មនុញ្ញថ្មីនេះ រឿងដំបូងបំផុត ដែលគេត្រូវចាត់ចែងឡើង គឺការជ្រើសរើសរកប្រធានាធិបតី ។ រដ្ឋធម្មនុញ្ញបានចែងថា អ្នកបោះឆ្នោត ត្រូវរើសរកសមាជិកនៃសភាឆ្នោតប្រជារាស្ត្រ ជាអ្នកតំណាងខ្លួន ដើម្បីអោយសភានោះធ្វើការជ្រើសរើសប្រធានាធិបតីបន្តទៅទៀត ។ សភាឆ្នោតប្រជារាស្ត្រក៏បានជ្រើសតាំងលោក George Washington អោយធ្វើជាប្រធានាធិបតីលើកទីមួយនៅក្នុង ស.រ.អា ។

៨.១.២ លោកប្រធានាធិបតី George Washington បានឡើងកាន់កាប់តំណែងនៅខែ មេសា ឆ្នាំ ១៧៨៩ នៅក្នុងរដ្ឋធានីបណ្តោះអាសន្នគឺ New York City - នៅពេលនោះ រដ្ឋសភា ដែលមានព្រឹទ្ធសភា និង សភាតំណាងរាស្ត្រ ជាផ្នែករបស់ខ្លួន ក៏បានជ្រើសតាំងឡើងដែរ ។ នៅឆ្នាំ ១៧៨៩ រដ្ឋសភា បានអនុម័តនូវសំរេច ខាងផ្នែកតុលាការលើកទីមួយ ដោយចាត់តាំងអោយមានចៅក្រមមួយនាក់ នៅខាងផ្នែកតុលាការជាន់ខ្ពស់ និង មានផ្នែកតុលាការបន្ទាប់បន្សំជាច្រើនទៀត ។ លោកប្រធានាធិបតី Washington បានចាត់តាំងចៅក្រម ៥ នាក់ទៀត ដើម្បីសំរាប់ធ្វើការជាមួយតុលាការជាន់ខ្ពស់ ហើយលោកក៏បានជ្រើសរើសយកលោក John Jay អោយធ្វើជាចៅក្រមជាន់ខ្ពស់ទៀតផង ។ រដ្ឋសភាថ្មី បានអនុម័តយល់ព្រមចំពោះការតែងតាំងទាំងប៉ុន្មាននេះរបស់លោកប្រធានាធិបតីដែរ ។ ដូច្នេះពេលនោះប្រទេសក៏ចាប់ផ្តើមមានខាងផ្នែកនីតិបញ្ញត្តិ នីតិប្រតិបត្តិ និង ផ្នែកខាងតុលាការឡើង ហើយរដ្ឋាភិបាលរដ្ឋាភិបាលថ្មីក៏បានប្រុងប្រៀបខ្លួន ហើយជាស្រេច ដើម្បីនឹងចាប់ផ្តើមកិច្ចការរបស់ខ្លួនដែរ ។

៨.២ លោកប្រធានាធិបតី និង រដ្ឋធម្មនុញ្ញ

៨.២.១ លោកប្រធានាធិបតី Washington បានកាន់កាប់ដំណែងអស់ពេលពីររយៈ - ៨ឆ្នាំ - ។ ក្នុងរយៈពេល ៨ ឆ្នាំនោះ លោកបានចាត់ចែងបង្កើត

អោយមានជារបៀបជាច្រើន ដើម្បីសំរាប់អោយជាគំរូដល់ប្រធានាធិបតីឯទៀតៗនៅក្នុងពេលអនាគត ។ ក្នុងនាមលោកជាមេប្រមុខខាងផ្នែកនីតិប្រតិបត្តិ លោកបានជ្រាបច្បាស់ថា លោកមិនអាចនឹងប្រកបកិច្ចការនេះតែម្នាក់ឯងបានទេ ។ ដូច្នេះលោកក៏បានបង្កើតអោយមានជាក្រសួងរដ្ឋាភិបាលផ្សេងៗគ្នាឡើង ហើយព្រមទាំងបានជ្រើសតាំងដាក់មនុស្សអោយដឹកនាំក្រសួងទាំងនោះផង ។ មនុស្សទាំងអស់នេះរួមគ្នាមក គេហៅថាគណៈរដ្ឋមន្ត្រី ។ លោក George Washington បានតែងតាំងលោក Thomas Jefferson អោយធ្វើជារដ្ឋលេខាធិការទីមួយ លោក Henry Knox ជាលេខាធិការខាងក្រសួងសឹកសង្គ្រាម និង លោក Alexander Hamilton ជាលេខាធិការខាងក្រសួងហិរញ្ញវត្ថុ ។ សមាជិកនៃគណៈរដ្ឋមន្ត្រីនេះ ក៏ជាក្រុមប្រឹក្សារបស់ប្រធានាធិបតីដែរ ។ រដ្ឋធម្មនុញ្ញមិនបានចែង ឬ ផ្តល់ជាខដល់គណៈរដ្ឋមន្ត្រីឡើយ ក៏ប៉ុន្តែលោកប្រធានាធិបតី Washington បានចាត់ចែងជារបៀប ដើម្បីសំរាប់ជាគំរូ និង ឧទាហរណ៍ដល់ពួកជំនាន់ក្រោយ ។ វិធានការណ៍របស់លោកនេះ បានក្លាយទៅជាទំនៀមទម្លាប់ខាងនយោបាយ ដែលសំរាប់អោយប្រធានាធិបតីទាំងឡាយ ក្នុងពេលអនាគតយកមកប្រព្រឹត្តិតាមគ្រប់គ្នា ។

៨-២-២ ប្រទេសថ្មី ព្រមទាំងរដ្ឋាភិបាលថ្មីបានជួបប្រទះនឹងបញ្ហាជាច្រើន ។ បញ្ហាមួយដែលធ្ងន់ជាងគេ គឺបញ្ហាដែលទាក់ទងទៅនឹងរឿងលុយកាក់ និង ហិរញ្ញវត្ថុ ។ នៅពេលដែលលោក Washington ឡើងកាន់កាប់អំណាច ស-រ-អា នៅជាប់ជំពាក់បំណុលរាប់រយលានដុល្លារ ហើយលុយកាក់នៅក្នុងរតនាគារ មានចំនួនស្តួចស្តើងណាស់ ។ ជំនាន់នោះ ប្រទេសមិនទាន់មានរបៀបដកហូតពន្ធអាករ ដើម្បីសំរាប់យកលុយទៅសងបំណុលគេ និង ដើម្បីសំរាប់ធ្វើការចំណាយនៅក្នុងរដ្ឋាភិបាលនៅឡើយ ។ លោកលេខាធិការខាងក្រសួងហិរញ្ញវត្ថុ Alexander Hamilton ចង់ចាត់វិធានការណ៍អោយបានតឹងរ៉ឹង ដើម្បីសំរាប់ជួយដល់រដ្ឋាភិបាលថ្មីនេះ អោយរួចពីការជំពាក់លុយគេ និង ពីភាពហិនហោចនេះផង ។ លោកបានស្នើសុំអោយមានជាកម្មវិធីដូចតទៅ :

១- រដ្ឋាភិបាលថ្មីនឹងសុខចិត្តសងបំណុលដែលនៅជំពាក់គេទាំងអស់ ។

២- រដ្ឋាភិបាលកណ្តាលនឹងសុខចិត្តសងបំណុលជំនួសរដ្ឋឯទៀតៗ ។ បំណុលភាគច្រើនជាលទ្ធផលនៃការចាយវាយរបស់រដ្ឋទាំងនោះ កាលពីជំនាន់សង្គ្រាមបដិវត្តន៍ ។

៣- រដ្ឋាភិបាលនឹងចាប់ផ្តើមរកលុយកាក់ចូល ដោយការហូតពន្ធអាករ ។ លោក Hamilton ព្រមទាំងចង់ហូតពន្ធអាករពីស្រា ដែលធ្វើនៅក្នុងប្រទេស ព្រមទាំងចង់បង្កើនពន្ធថែមទៀតដល់គ្រឿងរបស់របរដែលដឹកនាំមកពីបរទេស ។ គោលបំណងនៃពន្ធអាករនេះ គឺដើម្បីចង់លើកទឹកចិត្តដល់

គ្រឿងផលិតផលរបស់អាមេរិកាំងក្នុងស្រុក ។

៥- រដ្ឋាភិបាលនឹងគាំទ្រការបង្កើតធនាគារ ហើយធនាគាររបស់ ស-រ-អា នេះ នឹងផ្គត់ផ្គង់អោយតម្លៃទឹកលុយក្នុងប្រទេសមានភាពរឹងប៉ុងឡើងវិញ ។

កម្មវិធីរបស់លោក Hamilton នេះបានជួបប្រទះនឹងការប្រឆាំងយ៉ាងខ្លាំង ។ រដ្ឋផ្នែកខាងជើង ដែលនៅជាប់ជំពាក់បំណុលគេយ៉ាងសន្ធឹកនោះ សុខចិត្តយល់ព្រមតាមកម្មវិធីនេះ ក៏ប៉ុន្តែរដ្ឋផ្នែកខាងត្បូងមិនសុខចិត្តតាមទេ ពីព្រោះពួកគេបានធ្វើការសំរួល ក្នុងរឿងសងបំណុលរួចមកហើយ ។ ពួកខាងត្បូងមិនចង់អោយរដ្ឋាភិបាលដកហូតពន្ធអាករពីរដ្ឋខ្លួន ដើម្បីសំរាប់យកទៅដោះបំណុលអោយពួករដ្ឋខាងជើងទៀត ។

៨-២-៣ ក្រៅពីនេះនៅមានការខ្វែងយោបល់គ្នា ពីរឿងបង្កើតធនាគាររបស់ ស-រ-អា ថែមទៀត ។ លោក Thomas Jefferson និងពួកអ្នកស្រុះស្រួលតាមលោកបានជជែកប្រកែកឡើងថា រដ្ឋធម្មនុញ្ញមិនបាននិយាយពីរឿងអំណាចរបៀបនេះសោះ ។ លោកព្រមទាំងបានបន្ថែមទៀតថា អំណាចនេះត្រូវទៅតាមអំណាចខាងរឿងលុយកាក់ ដែលរដ្ឋធម្មនុញ្ញបានប្រគល់អោយដល់រដ្ឋសភា ។ នៅពេលនោះ ប្រជាពលរដ្ឋក៏បានលំអៀងការគាំទ្រទៅលើរឿងនេះ និង រឿងទៀតៗផង ។ ការទាស់ទែងគ្នានេះថែមទាំងបានបណ្តាលអោយកើតមានជារឿងថ្មីមួយទៀតដល់ប្រទេស គឺការកកើតឡើងនូវក្រុម ឬ គណៈបក្សនយោបាយ ។

៨-៣ ការបង្កបង្កើតនូវគណៈបក្សនយោបាយ

៨-៣-១ កម្មវិធីរបស់រដ្ឋាភិបាលថ្មីនេះ បានជួយបង្កើតអោយមានភាពសប្បាយរុងរឿងដល់ប្រទេស ក៏ប៉ុន្តែប្រជារាស្ត្រអាមេរិកាំងជាច្រើននៅតែមានការប្រឆាំងនឹងកម្មវិធីលោក Hamilton ដដែល ។ វិធានការណ៍របស់លោកនេះ បានធ្វើអោយមានការបែងចែកនៅក្នុងប្រទេស ដោយធ្វើអោយផ្នែកខាងជើងបែកចេញពីផ្នែកខាងត្បូង និងបែងចែកពួកអ្នកមាន និង ពួកអ្នកក្រ ។ កាលពីជំនាន់បដិវត្តន៍ មានមនុស្សជាច្រើនបានអោយរដ្ឋសភាខ្ចីលុយខ្លួន ហើយដែលបានទទួលប័ណ្ណសន្យាពីរដ្ឋាភិបាលថា គេនឹងសងលុយមកវិញ ។ ប៉ុន្តែដល់ពេលក្រោយមក ពួកទាំងនោះ ក៏ចាប់មានការសង្ស័យថា រដ្ឋាភិបាលប្រហែលជានឹងមិនសងលុយនោះមកវិញទេ ដូច្នេះគេក៏ចាប់លក់ប័ណ្ណរបស់ខ្លួនចេញ ដោយសុខចិត្តទទួលយកតំលៃទាបផង ។ ពួកដែលទិញប័ណ្ណនោះគឺ ច្រើនតែជាពួកអ្នកមានដែលមានជំនេះដឹងយល់ពីកម្មវិធីរបស់លោក Hamilton ទាំងអស់ ។ ពួកអ្នកចាញ់បង់ខាត គឺច្រើនតែទាហាន កសិករ និង ម្ចាស់ហាងតូចតាច ។ ពួកនេះមានការខឹងសម្បារយ៉ាងខ្លាំងចំពោះវិធានការណ៍របស់លោក Hamilton នេះ ហើយពួកគេ

ព្រមទាំងបានរួបរួមគ្នា ធ្វើការប្រឆាំងទៀតផង ។

៨.៣.២ ក្រុមដែលគាំទ្រលោក Hamilton មានឈ្មោះហៅថា ពួកសហរដ្ឋ ។ ពួកនេះចង់យករដ្ឋធម្មនុញ្ញមកធ្វើជាច្បាប់ជាន់ខ្ពស់សំរាប់ប្រទេសទាំងមូល ហើយពួកគេចង់បង្កើតអោយមានរដ្ឋាភិបាលកណ្តាលដែលមានភាពរឹងប៉ឹងមាំមួនផង ។ ពួកសហរដ្ឋថែមទាំងបានលំអៀងទៅលើភាពបត់បែននៃការបកស្រាយច្បាប់ក្នុងរដ្ឋធម្មនុញ្ញទៀតផង ពីព្រោះវិធានការនេះអាចធ្វើអោយរដ្ឋាភិបាលកណ្តាលពិតតែមានអំណាចខ្លាំងថែមទៀត ។ ពួកសហរដ្ឋនេះច្រើនតែជាពួកអ្នកមានធំៗ ដូចជាពួកម្ចាស់ដី ពាណិជ្ជករ មេធាវី និង ពួកធនាគារិក ហើយច្រើនតែរស់នៅតាមផ្នែក New England និងរដ្ឋផ្នែកកណ្តាល ។ ពួកគេមានជំនឿថា ពួកវណ្ណៈជាន់ខ្ពស់ត្រូវការកាន់កាប់គ្រប់គ្រងកិច្ចការនៅក្នុងរដ្ឋាភិបាល ហើយថែមទាំងមានសេចក្តីសង្ឃឹមថា នឹងយកអំណាចក្នុងនយោបាយមកដាក់អោយឆ្ងាយពីកណ្តាប់ដៃពួករាស្ត្រសាមញ្ញទៀតផង ។ បក្សសហរដ្ឋនេះត្រូវបានប្រឆាំងទៀងពីខាងគណៈបក្សសាធារណរដ្ឋ ។

៨.៣.៤ គណៈបក្សនយោបាយទាំងពីរនេះ មានឱកាសនឹងបញ្ចេញសាកល្បងមើលនូវកំលាំងរបស់ខ្លួនជាលើកដំបូង នៅក្នុងពេលបោះឆ្នោតរើសប្រធានាធិបតីនៃឆ្នាំ ១៧៩៦ ។ ពេលនោះ លោក John Adams បានត្រូវគេជ្រើសរើសតាំងអោយឈរឈ្មោះដំណាងគណៈបក្សសហរដ្ឋ ដែលមានលោក Thomas Pinckney ឈរឈ្មោះជាអនុប្រធានាធិបតីផង ។ ចំណែកខាងគណៈបក្សសាធារណរដ្ឋវិញ មានលោក Thomas Jefferson និង លោក Aaron Burr ឈរឈ្មោះជាបេក្ខជន ។ សភាឆ្នោតប្រជារាស្ត្រដែលធ្វើការបោះឆ្នោតរើសប្រធានាធិបតីនៃឆ្នាំ ១៧៩៦ បានបង្ហាញអោយឃើញនូវភាពទន់ខ្សោយរបស់រដ្ឋធម្មនុញ្ញ ។ ពីព្រោះរដ្ឋធម្មនុញ្ញមិនបានអនុញ្ញាតិអោយមានគណៈបក្សពីរដែលគណៈបក្សនិមួយៗជ្រើសរើសយកបេក្ខជនពីរខុសគ្នា សំរាប់អោយឈរឈ្មោះធ្វើប្រធានាធិបតី និង អនុប្រធានាធិបតីទេឡើយ ។ រដ្ឋធម្មនុញ្ញ បានចែងថា សមាជិករបស់សភាឆ្នោតប្រជារាស្ត្រម្នាក់ៗ មានអំណាចនឹងបោះឆ្នោតអោយបេក្ខជនពីររូប ប៉ុន្តែសមាជិកនោះមិនបានបង្ហាញពីការជ្រើសរើសរបស់ខ្លួនថា តើអ្នកណាជាប្រធានាធិបតី និង អ្នកណាទៀតជាអនុប្រធានាធិបតីទេឡើយ ។ ដូច្នេះអ្នកណាដែលបានទទួលសំលេងឆ្នោតច្រើនជាងគេ អ្នកនោះនឹងបានជាប់ធ្វើជាប្រធានាធិបតី ចំណែកឯអ្នកណា ដែលបានទទួលសំលេងឆ្នោតច្រើនបន្ទាប់នឹងត្រូវឡើងធ្វើអនុប្រធានាធិបតី ។ នៅក្រោមវិធានការនេះ លោក Adams ខាងគណៈបក្សសហរដ្ឋត្រូវបានជាប់ឆ្នោតធ្វើប្រធានាធិបតី ចំណែកលោក Jefferson វិញ ដែលជាបេក្ខជនខាងគណៈបក្សសាធារណរដ្ឋត្រូវជាប់ជាអនុប្រធានាធិបតី ។ គណៈបក្សសហរដ្ឋព្រមទាំងបានឈ្នះកន្លែងជាច្រើននៅក្នុងរដ្ឋសភាទៀតផង ដូច្នេះពេលនោះ ពួកសហរដ្ឋគឺ

ត្រូវបានគេឡើងកាន់កាប់អំណាចក្នុងប្រទេស ។ ចាប់ពីពេលនោះមក គណៈបក្សនយោបាយ ព្រមទាំងសកម្មភាពរបស់ខ្លួនរឹតតែមានឥទ្ធិពលខ្លាំងឡើងៗ ចំពោះជីវិតរស់នៅរបស់អាមេរិកាំងទាំងអស់ ។

ការហាត់

១- របៀបរកពាក្យ

សេចក្ដីណែនាំ : សូមរក និង គូសរង្វង់ជុំវិញនូវពាក្យទាំង ៣០ ដែលនៅក្នុងរបៀបរកពាក្យខាងក្រោម ។ ពាក្យទាំងអស់នេះអាចរកឃើញតាមរបៀប បញ្ឈរ ផ្ដេក និង បញ្ច្រាង ។ ពេលដែលរកឃើញនូវពាក្យនិមួយៗ សូមសរសេរដាក់នៅលើក្រដាស ព្រមទាំងអោយអត្ថន័យនៃពាក្យនោះផង ។

APRIL
LIQUOR
DEBT
CITY
WAR
TAX
RAISE

INDIVIDUAL
ELECTORAL COLLEGE
JUDICIARY ACT
ASSOCIATE JUSTICE
CHIEF JUSTICE
RATIFICATION
NOMINATION
CONSTITUTION

FUTURE
CABINET
SUPREME
MEASURE
JUDICIAL
APPOINT
PROBLEMS
PRODUCE

PRECEDENT
WASHINGTON
PROVISION
EXECUTIVE
LEGISLATIVE
DEPARTMENT
FUTURE

I	E	L	E	C	T	O	R	A	L	C	O	L	L	E	G	E	N	D
N	J	C	H	I	E	F	J	U	S	T	I	C	E	X	W	P	O	E
D	U	C	A	B	I	N	E	T	M	E	A	S	U	R	E	R	M	R
I	D	A	P	R	I	L	P	R	O	V	I	S	I	O	N	E	I	A
V	I	R	A	T	I	F	I	C	A	T	I	O	N	O	X	C	N	R
I	C	O	N	S	T	I	T	U	T	I	O	N	W	A	R	E	A	T
D	I	A	P	P	O	I	N	T	S	U	P	R	E	M	E	D	T	M
U	A	S	S	O	C	I	A	T	E	J	U	S	T	I	C	E	I	E
A	R	W	A	S	H	I	N	G	T	O	N	C	I	T	Y	N	O	N
L	Y	E	X	E	C	U	T	I	V	E	R	U	T	U	F	T	N	T
Y	A	V	O	L	E	G	I	S	L	A	T	I	V	E	T	A	X	O
E	C	B	I	C	H	O	J	U	D	I	C	I	A	L	D	E	B	T
U	T	A	P	P	O	I	N	T	P	R	O	B	L	E	M	S	O	X
L	I	Q	U	O	R	P	R	O	D	U	C	E	R	A	I	S	E	D

ខ- របៀបប្រៀបផ្ទឹម

សូមធ្វើការប្រៀបផ្ទឹមពាក្យ ដែលនៅខាងឆ្វេង ក្រោមបន្ទាត់អក្សរ A ទៅនឹង អត្ថន័យ ឬ សេចក្តីពន្យល់ ដែលនៅខាងស្តាំ ក្រោមបន្ទាត់អក្សរ B ដោយសរសេរ ចម្លើយជាលេខនៅក្នុងកន្លែងទំនេរពីខាងមុខផង ។

	A	B
15.5.3. Reconstruction under these acts began in 1867. The entire Confederate area was divided into five military districts. Federal troops were kept in the South until 1877 to protect the blacks and to enforce federal laws.

15.5.4. The Thirteenth and Fourteenth Amendments and the Reconstruction Acts gave the blacks political power in the South. Black voters were important to the Reconstruction Plans. Since most whites were not allowed to vote, black voters were the majority in many areas. For the first time, black people voted and held offices. Hundreds of ex-slaves were elected to the House of Representatives and Senate of the United States.

EXERCISES

I. Word search puzzle.

Directions: Find and circle the words in the word puzzle below. The words will be found vertically, horizontally, and diagonally. When you find a word in the puzzle, write it and then define it.

P	T	U	R	N	I	N	G	P	O	I	N	T	H	O	N	O	R
R	E	A	F	F	I	R	M	B	L	O	C	K	A	D	E	B	C
O	R	E	C	O	N	S	T	R	U	C	T	I	O	N	H	I	O
C	O	N	C	L	U	S	I	O	N	R	A	T	I	F	Y	C	N
L	P	U	R	S	U	I	T	W	O	C	N	S	L	A	V	E	C
A	D	D	R	E	S	S	L	A	A	O	A	T	H	P	R	U	L
M	B	A	T	T	L	E	O	R	I	N	C	S	A	P	I	N	U
A	F	O	R	C	E	S	Y	T	E	T	O	H	M	O	C	I	S
T	I	N	V	A	D	E	A	E	L	R	N	E	E	M	H	O	I
I	G	O	A	L	O	P	L	Y	I	O	F	R	N	A	M	N	O
O	D	A	R	E	I	Y	T	M	G	L	E	M	D	T	O	A	N
N	E	A	H	C	A	B	Y	R	I	T	D	A	M	O	N	R	L
M	W	C	N	E	L	T	T	A	B	N	E	N	E	X	D	M	G
K	I	A	P	A	R	T	C	B	L	A	R	O	N	A	B	I	N
B	M	A	R	Y	L	A	N	D	E	R	A	O	T	Y	O	E	U
E	G	E	T	T	Y	S	B	U	R	G	T	B	B	E	A	S	H
S	H	E	R	I	D	A	N	V	A	N	E	L	A	N	N	H	I

WAR
LEE
OATH
GOAL
DARE
SLAVE
ARMY

FORCES
PART
BATTLE
HONOR
INVADE
RATIFY
GRANT

ADDRESS
REAFFIRM
ELIGIBLE
CONTROL
SHERIDAN
PURSUIT
RICHMOND

CONCLUSION
AMENDMENT
LOYALTY
BLOCKADE
MARYLAND
CONFEDERATE
SHERMAN

EMANCIPATION
RECONSTRUCTION
PROCLAMATION
GETTYSBURG
TURNING POINT
APPOMATOX
UNION ARMIES

II. Scrambled Words.

Direction: Complete the sentences by unscrambling the letters to spell out the appropriated words.

1. **offernjes sivda** was president of the Confederacy.
2. **collnin** was president of the United States during the Civil War and issued the Emancipation Proclamation freeing the slaves.
3. **oretrb ele** was the commander of Confederate forces.
4. **beturystgg** was the place where President Lincoln gave a speech calling for the preservation of the Union.
5. **anhesmer** was a Union general who led the long march to the sea through the South.
6. **onemitanciap** was issued by President Lincoln and it freed all the slaves in the Confederate States.
7. **xppmaatoo uestchorou** was the place in Virginia where General Lee surrendered to General Grant, ending the Civil War.

III. Multiple Choice

Select the letter preceding the word or expression that best completes each statement or answer each question.

_____ 1. The immediate cause of the Civil War was the (a) attack on Fort Sumter (b) the assassination of President Lincoln (c) the Thirteenth Amendment (d) the Gettysburg Battle.

______ 2. The major purpose of the blockade during the Civil War was to prevent (a) English volunteers from going to the South (b) exporting of cotton to Europe (c) the Russian fleet from visiting the South.

______ 3. The Emancipation Proclamation was (a) a law passed by Congress (b) an amendment to the Constitution (c) a Presidential Order (d) a joint resolution of Congress.

______ 4. The purpose of General Sherman's famous march to the sea was to (a) trap General Lee (b) come to Grant's aid (c) split the Confederacy (d) capture valuable cotton land for the North.

______ 5. An important result of the Civil War was it (a) ended the states' rights issue (b) strengthened our tie with Great Britain (c) helped to make industry rather than agriculture the basis of our economy (d) established equality for the Negro in the South.

ការអាន

១៥.១ ការប្រកាសអោយបានរួចខ្លួនជាអ្នកជា

១៥.១.១ នៅចន្លោះខែមេសា ឆ្នាំ ១៨៦១ និង មេសា ១៨៦៥ សហរដ្ឋអាមេរិកបាន ត្រូវខូចខាតខ្ទិចខ្ទី និង ត្រូវបានបែងចែកជាពីរផង ។ បក្សសម្ព័ន្ធបានធ្វើការប្រយុទ្ធ ដើម្បីនឹង ចង់រក្សាទុកនូវទាសភាព ហើយនិង ចង់បានឯករាជ្យរបស់ខ្លួនពីផ្នែកខាងជើងផង ។ ដំបូងឡើង សហភាពខំប្រឹងតស៊ូ ដើម្បីគ្រាន់តែចង់អោយប្រទេសបានរួបរួមគ្នាឡើងវិញប៉ុណ្ណោះ ។ តែក្រោយ មក ពួកផ្នែកខាងជើង ថែមទាំងបានខ្នះខ្នែងតស៊ូ ដើម្បីអោយពួកទាសភាពមានសេរីភាពឡើង វិញផង ។ លោកប្រធានាធិបតី Lincoln មានបំណងចង់ប្តូរនយោបាយសង្គ្រាមនៅពេលនោះ ព្រោះលោកចង់អោយសង្គ្រាមបានចប់យ៉ាងឆាប់ ដើម្បីនឹងអាចជួយស្រោចស្រង់ជីវិតមនុស្ស ទាំងសងខាង ។ ការប្រកាសអោយបានរួចខ្លួនជាអ្នកជា ជាកត្តាមួយយ៉ាងសំខាន់ ក្នុងចំណោម កត្តាឯទៀតជាច្រើន ដែលបានធ្វើអោយពួកផ្នែកខាងជើងមានជ័យជំនះ ។

១៥.១.២ នៅថ្ងៃទីមួយ ខែមករាឆ្នាំ ១៨៦៣ លោកប្រធានាធិបតី Lincoln បានចុះហត្ថលេខា ដើម្បីប្រកាសអោយបានរួចខ្លួនជាអ្នកជា ។ នេះគឺជាសេចក្តីបញ្ជា ដែលបានប្រកាសអោយពួកទាសភាពទាំងប៉ុន្មាន ដែលនៅក្នុងបក្សសម្ព័ន្ធ បានរួចខ្លួនជាអ្នកជា - ប៉ុន្តែមិនបាន ជួយដល់ពួកទាសភាពឯទៀត ដែលនៅក្នុងរដ្ឋ៥ទៀត ដែលមានព្រំប្រទល់ជាប់គ្នាឡើយគឺ៖

Delaware , Maryland , Kentucky , Missouri និង West Virginia ។ បន្ទាប់ពីបានរួចខ្លួនមក ពួកទាសភាពពីមុនជាច្រើនបាននាំគ្នាចូលធ្វើ ទាហានខាងសហភាព ដើម្បីនឹងប្រយុទ្ធតទល់ជាមួយបក្សសម្ព័ន្ធ ។

១៥.២ ការថ្លែងសុន្ទរកថានៅ Gettysburg

ពេលដែលសង្គ្រាមចាប់ផ្តើមឡើងភ្លាម បក្សសម្ព័ន្ធហាក់ដូចជាត្រូវបានឈ្នះ ពីព្រោះពីរ ឆ្នាំដំបូង កងទ័ពរបស់ពួកគេបានមានជោគជ័យសឹងតែនៅគ្រប់ទីសមរភូមិទាំងអស់ ។ ប៉ុន្តែនៅឆ្នាំ ១៨៦២ ទ័ពសហភាពមានជ័យជំនះ ដោយបានបញ្ឈប់នូវការវាយប្រហារលុកទៅមុខនៃទ័ពសម្ព័ន្ធ នៅ Antietam នៃរដ្ឋ Maryland ហើយព្រមទាំងបានសម្លាប់ទាហានខាងត្បូងជាច្រើន នាក់ផង ។ ឆ្នាំ១៨៦៣ ជាឆ្នាំ ដែលសង្គ្រាមបានផ្លាស់ប្តូរយ៉ាងខ្លាំង ។ កងទ័ពថ្មើរជើងរបស់ ឧត្តមសេនីRobert E. Leeនៃបក្សសម្ព័ន្ធ បានត្រូវសហភាពវាយបញ្ឈប់នៅ Gettysburg នៃរដ្ឋ Pennsylvania ។ ក្នុងការប្រយុទ្ធគ្នាអស់រយៈពេលបីថ្ងៃ កងទ័ពទាំងសងខាងបានត្រូវ បាត់បង់ជីវិតទាហានចំនួនជាង ៥ ម៉ឺននាក់ ។ នេះជាការប្រយុទ្ធយ៉ាងសាហាវឃោរឃៅបំផុត នៃសង្គ្រាមក្នុងស្រុក ។ បន្ទាប់ពីនោះ កងទ័ពសម្ព័ន្ធក៏បានដកថយទៅ Virginia វិញ ។

១៥-២-២ នៅថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ១៨៦៣ រយៈពេលជាងបួនខែ បន្ទាប់ពីការប្រយុទ្ធគ្នាយ៉ាងសាហាវនៅ Gettysburg នោះមក ប្រជារាស្ត្រក៏បានជួបជុំគ្នានៅកន្លែងទីលានប្រយុទ្ធនោះ ដើម្បីនឹងគោរពដល់វិញ្ញាណក្ខន្ធទាហានទាំងប៉ុន្មាន ដែលបានបាត់បង់ជីវិតទៅ ព្រមទាំងបានចាត់ទុកកន្លែងនោះជាទីលានរបស់ជាតិផង ។ ពេលនោះលោកប្រធានាធិបតី Lincoln ក៏បានធ្វើសុន្ទរកថាយ៉ាងខ្លីមួយ ដែលគេចាត់ទុកថាជាសុន្ទរកថាដ៏សំខាន់លើសលុប ។ នៅចុងបញ្ចប់ លោកក៏បានធ្វើការអះអាងថា "ក្រោមការដឹកនាំរបស់ព្រះ ប្រទេសនេះនឹងមានកំណើតសេរីភាពជាថ្មីម្តងទៀត ដែលមានរដ្ឋាភិបាលជារបស់ប្រជារាស្ត្រ ដោយសារប្រជារាស្ត្រ សំរាប់ប្រជារាស្ត្រ នឹងមិនរលត់រលាយបាត់ពីផែនដីនេះឡើយ ។ គោលបំណងរបស់លោក Lincoln គឺដើម្បីស្រោចស្រង់សហភាព និង ដោះលែងប្រជាពលរដ្ឋអោយមានសេរីភាពឡើងវិញ ។

១៥-៣' ជ័យជំនះ និង បរាជ័យ

១៥-៣-១ រហូតទាល់តែមកដល់ការប្រយុទ្ធនៅ Gettysburg នោះ គឺហាក់ដូចជាគ្រានៃមេទ័ពខាងសហភាព ដែលអាចយកជ័យជំនះពីលោកឧត្តមសេនីយ Lee បានទៀតៗ តាមការពិត ជ័យជំនះរបស់លោកជាច្រើន អាចធ្វើអោយគេឃើញថា ហេតុអ្វីបានជាលោកហ៊ានចូលរាតត្បាតដល់ Pennsylvania ដែលជារដ្ឋរបស់សហភាព ។ លោក Lee បានខំប្រឹងប្រែងធ្វើអោយមានជ័យជំនះនៅផ្នែកខាងជើង ពីព្រោះដើម្បីនឹងបង្ខំទូវទាក់ទាញអោយរួចពីការ ដែលទ័ពសហភាពមានជ័យនៅ Vicksburg នៃរដ្ឋ Mississippi ។

១៥-៣-២ បន្ទាប់ពីកងទ័ពសម្ព័ន្ធ បានដកថយទៅផ្នែកខាងត្បូង ទ័ពសហភាពក៏បានចូលលុកលុយឈ្លានពានផ្នែកខាងត្បូង ដោយបានវាយលុកពីទិសខាងលិច និង តាមសមុទ្រ ។ ទ័ពសហភាពបានកាន់កាប់ទន្លេ Mississippi ចាប់ពី St.Louis រហូតដល់ New Orleans នៅខែកុម្ភៈ ឆ្នាំ ១៨៦២ លោកឧត្តមសេនីយ Grant នៃសហភាព បានមានជ័យពីរទៀត គឺវាយយកបានបន្ទាយ Henry ដែលនៅតាមទន្លេ Tennessee និងបន្ទាយ Donelson ដែលនៅតាមទន្លេ Cumberland ។ ឧត្តមសេនីយសហភាពម្នាក់ទៀតឈ្មោះលោក Sherman ក៏បានចាប់វាយលុកតាមផ្លូវយ៉ាងវែង ដោយកាត់តាម Georgia ទៅ Savanah ដែលនៅតាមឆ្នេរសមុទ្រ ។ ទ័ពលោកបានបំផ្លាញអ្វីៗទាំងអស់ ដែលនៅតាមផ្លូវ បន្ទាប់មកក៏បានវាយលុកឡើងទៅទិសខាងជើងវិញ ។ ក្នុងពេលជាមួយគ្នានោះ ទ័ពលោកឧត្តមសេនីយ Grant ក៏បានវាយឡើងទៅទិសខាងត្បូង តំរង់ទៅរក Richmond ទៀត ដូច្នេះពេលនោះ កងទ័ពសម្ព័ន្ធ ក៏ត្រូវនៅជាប់កណ្តាលចន្លោះកងទ័ពរបស់ឧត្តមសេនីយទាំងពីរនេះ ។ ថែមពីលើនេះ កងនាវាចរសហភាព ក៏បានបិទផ្លូវសមុទ្រមិនអោយចេញចូលទៀត ដែលធ្វើអោយមានបញ្ហាដឹកជញ្ជូនដល់ពួកខាងត្បូង ។

១៥.៣.៣ ភាពចុងផ្លូវនៃកងទ័ពសម្ព័ន្ធបានមកដល់នៅខែមេសា ឆ្នាំ ១៨៦៥ ។ បន្ទាប់ពីជាប់អន្ទាក់របស់ឧត្តមសេនីយ Grant អស់រយៈពេលប្រាំបួនខែមក ស្រុក Petersburg ដែលមានចម្ងាយ ២០ ម៉ាល៍ពី Richmond បានត្រូវធ្លាក់ក្នុងកណ្តាប់ដៃកងទ័ពសហភាព ។ លោក Lee ក៏បានដកទ័ពថយចេញពី Richmond ហើយពេលនោះ ពលទាហានខ្លះរបស់លោក Grant ក៏បានចូលទៅនៅ ។ ទ័ពរបស់ឧត្តមសេនីយពីរនាក់ គឺលោក Grant និងលោក Sheridan បានដេញតាមលោក Lee ពីទិសពីរផ្សេងគ្នា ។ ដោយផ្លូវសំរាប់រំដោះខ្លួនទាំងប៉ុន្មានត្រូវគេបិទជិត លោក Lee ក៏បានសុំចុះចាញ់នៅថ្ងៃទី ៩ មេសា ឆ្នាំ ១៨៦៥ នៅក្នុងផ្ទះស្រែមួយ នៃភូមិឈ្មោះ Appomatox Court House ។

១៥.៤ សេចក្តីកែតម្រូវច្បាប់ទី ១៣

១៥.៤.១ ពេលដែលសង្គ្រាមក្នុងស្រុកបានចប់សព្វគ្រប់មក ផ្នែកសហភាព ព្រមទាំងលោកប្រធានាធិបតី Lincoln ត្រូវមានកិច្ចការ ដែលនឹងត្រូវបំពេញជាច្រើន ។ ក្នុងចំណោមនោះគឺ ការរំដោះផ្នែកត្បូង ។

១៥.៤.២ នៅពេលដែលលោកប្រធានាធិបតី Lincoln បានប្រកាសពីការអោយបានរួចខ្លួនជាអ្នកជា គឺលោកគ្រាន់តែចង់រំដោះពួកទាសភាព ដែលនៅក្នុងរដ្ឋ ដែលបះបោរទាំងប៉ុន្មានតែនោះប៉ុណ្ណោះ ។ ប៉ុន្តែពេលដែលសង្គ្រាមក្នុងស្រុកបានចប់នៅឆ្នាំ ១៨៦៥ រដ្ឋសភាចង់ធ្វើការដោះស្រាយបញ្ហាទាសភាពនេះអោយបានចប់សព្វគ្រប់តែម្តងថែមទៀត ។ ក្នុងឆ្នាំដដែលនោះ រដ្ឋសភាក៏បានបង្កើតជាច្បាប់មួយសំរាប់រដ្ឋធម្មនុញ្ញ គឺត្រូវអោយដោះលែងពួកទាសភាពទាំងអស់ក្នុងសហអាមេរិក ព្រមទាំងដំបន់ថ្មីៗទៀតផង ។ នេះគឺសេចក្តីកែតម្រូវច្បាប់ទី ១៣ ដែលបានទទួលសច្ចានុមតិពីរដ្ឋសភាចំនួនបីភាគបួន ប្រាំបីខែបន្ទាប់ពីសង្គ្រាមបានចប់ ។

១៥.៥ ការចាប់កសាងឡើងវិញនៅផ្នែកខាងត្បូង និង ស្ថានភាពនៃមនុស្សស្បែកខ្មៅ

១៥.៥.១ សង្គ្រាមក្នុងស្រុកបានធ្វើអោយសេដ្ឋកិច្ចមានការផ្លាស់ប្តូរទាំងផ្នែកខាងត្បូង និងផ្នែកខាងជើង ។ នៅពេលដែលឧស្សាហកម្មនៃផ្នែកខាងជើងបានរីកចំរើនផុះដាលខ្លាំងឡើង ផ្នែកខាងត្បូងបានត្រូវវិនាសអន្តរាយហិនហោចដោយសារសង្គ្រាម ។ ស្រែចំការ ឧស្សាហកម្ម ការដឹកនាំ និង ទីក្រុងទាំងប៉ុន្មានបានត្រូវខូចខាតយ៉ាងធ្ងន់ ។ ទោះជានៅពេលដែលសង្គ្រាមក្នុងស្រុកកំពុងតែបានរាលដាលក៏ដោយ ក៏នៅតែមានការពិភាក្សាពីរឿងចាប់កសាងផ្នែកខាងត្បូងនេះឡើងវិញដែរ ។ លោកប្រធានាធិបតី Lincoln បានស្នើសុំអោយមានការបន្ធូរបន្ថយ ដើម្បីសំរាប់អោយរដ្ឋផ្នែកខាងត្បូងទាំងប៉ុន្មាន បានចូលរួបរួមជាមួយសហភាពឡើងវិញ ។ គំរោងការរបស់លោក បានផ្តល់ជាយោបល់ថា បើសិនជារដ្ឋណាដែលមានអ្នកបោះឆ្នោតចំនួន ១០ ភាគរយរបស់ខ្លួនបានចុះហត្ថលេខា ដើម្បីស្បថថាមានការស្មោះត្រង់ចំពោះសហភាព

រដ្ឋនោះនឹងត្រូវអនុញ្ញាតិអោយចូលរួបរួមឡើងវិញ ។ ពួកមូលវិវដ្តនិយមនៃគណៈបក្សសាធារណៈរដ្ឋ ដែលបានចាត់ទុកផ្នែកខាងត្បូងថា ជាផ្នែកដែលដណ្ដើមយកបានពីការឈ្នះសង្គ្រាម ចង់ប្រើអំណាច ដើម្បីនឹងរៀបចំផ្នែកនោះឡើងវិញ ដើម្បីជាទណ្ឌកម្មដល់ពួកខាងត្បូង ។ ពួកមូលវិវដ្តនិយមនេះ ក៏បានបង្កើតច្បាប់មួយនៅឆ្នាំ ១៨៦៤ ឈ្មោះច្បាប់ Wade-Davis - ច្បាប់នេះបានដាក់កំរិតអោយពួកអ្នកបោះឆ្នោតភាគច្រើនពីរដ្ឋនិមួយៗ ត្រូវចុះហត្ថលេខាស្បថសិន មុននឹងអនុញ្ញាតិអោយចូលរួបរួមឡើងវិញ ប៉ុន្តែលោក Lincoln បានបដិសេធចោលនូវច្បាប់នេះ ។

១៥-៥-២ នៅខែមេសា ឆ្នាំ ១៨៦៥ លោកប្រធានាធិបតី Lincoln ត្រូវបានគេលួចបាញ់សំឡាប់ ។ ប្រធានាធិបតីថ្មី គឺលោក Andrew Johnson ដែលដំបូងឡើងមានការសំអៀងទៅលើគំនិតពួកមូលវិវដ្តនិយម ប៉ុន្តែដល់ពេលក្រោយមក ក៏បានយល់ព្រមនឹងគំនិតលោក Lincoln ទៅវិញ ។ នៅចុងឆ្នាំ ១៨៦៥ លោកក៏បានប្រកាសថា រដ្ឋផ្នែកខាងត្បូងទាំងប៉ុន្មាននឹងអាចមានច្បាប់ចូលរួបរួមជាមួយសហភាពវិញ ។ ពេលនោះ ពួកមូលវិវដ្តនិយមខាងបក្សសាធារណៈរដ្ឋ ក៏បានប្រឆាំងតវ៉ាឡើង ។ នៅឆ្នាំ ១៨៦៦ ពួកមូលវិវដ្តនិយមនេះបានកើនកំលាំងខ្លាំងឡើងនៅក្នុងរដ្ឋសភា នៅពេលនោះ គេក៏បានបង្កើតអោយមានច្បាប់ជាច្រើន ក្នុងការកសាងឡើងវិញនូវផ្នែកខាងត្បូង ។ ច្បាប់ទាំងនោះ បានដាក់លក្ខខ័ណ្ឌពីរសំរាប់រដ្ឋផ្នែកខាងត្បូង បើសិនជាចង់ចូលមករួបរួមឡើងវិញ ។

ក. រដ្ឋខាងត្បូងនិមួយៗ ត្រូវធ្វើសន្និបាតអំពីរដ្ឋធម្មនុញ្ញ ការបោះឆ្នោតសំរាប់សន្និបាតនេះត្រូវបើកសិទ្ធិអោយពួកស្បែកខ្មៅចូលរួបរួមបាន ដូចជាពួកស្បែកសដែរ ។

ខ. រដ្ឋខាងត្បូងនិមួយៗ ត្រូវធ្វើសច្ចានុមតិអំពីសេចក្ដីកែតម្រូវនៃច្បាប់ទី ១៣ ។ គោលបំណងរបស់ច្បាប់នេះ គឺសំរាប់អោយសិទ្ធិសេរីភាពមានឈ្មោះជាពលរដ្ឋពេញលេញដល់ពួកស្បែកខ្មៅទាំងអស់ ។ បន្ថែមពីលើនេះ គឺត្រូវធ្វើទណ្ឌកម្មដល់ពួកសម្ព័ន្ធពីមុនខ្លះ ដោយខាយ៉ាំងមិនអោយពួកនេះមានសិទ្ធិបោះឆ្នោត ព្រមទាំងមិនអោយធ្វើការក្នុងរដ្ឋាភិបាលសហភាព ឬ រដ្ឋាភិបាលនៃរដ្ឋណាមួយឡើយ ។

១៥-៥-៣ ការកសាងឡើងវិញនៅក្រោមច្បាប់របស់ពួកមូលវិវដ្ត បានចាប់ផ្ដើមឡើងនៅឆ្នាំ ១៨៦៧ ។ ភូមិភាគរបស់ពួកសម្ព័ន្ធទាំងប៉ុន្មាន បានត្រូវគេចែកចេញជា ៥ មណ្ឌលសឹក ។ កងទ័ពរដ្ឋាភិបាលបានឋិតនៅផ្នែកខាងត្បូងនោះ រហូតដល់ឆ្នាំ ១៨៧៧ ដើម្បីសំរាប់ការពារដល់ពួកស្បែកខ្មៅ និង មើលការខុសត្រូវឯទៀតៗអោយស្របទៅតាមច្បាប់រដ្ឋាភិបាលសហភាព ។

១៥-៥-៤- សេចក្ដីកែតម្រូវច្បាប់ទី ១៣ ទី ១៤ និង ច្បាប់ឯទៀតៗសំរាប់ការ

១- ល្បែងរកពាក្យ

__សេចក្ដីណែនាំ__ ៖ សូមរក និង គូសរង្វង់មូលជុំវិញនូវពាក្យទាំង ៣៥ នៅក្នុងល្បែងរកពាក្យខាងក្រោម ។ ពាក្យទាំងអស់នេះអាចរកឃើញតាមរបៀបបញ្ឈរ ផ្ដេក និង បញ្ច្រាស។ ពេលដែលរកឃើញនូវពាក្យនិមួយៗ សូមសរសេរដាក់នៅលើក្រដាសព្រមទាំងឲ្យអត្ថន័យនៃពាក្យនោះផង ។

P	T	U	R	N	I	N	G	P	O	I	N	T	H	O	N	O	R
R	E	A	F	F	I	R	M	B	L	O	C	K	A	D	E	B	C
O	R	E	C	O	N	S	T	R	U	C	T	I	O	N	H	I	O
C	O	N	C	L	U	S	I	O	N	R	A	T	I	F	Y	C	N
L	P	U	R	S	U	I	T	W	O	C	N	S	L	A	V	E	C
A	D	D	R	E	S	S	L	A	A	O	A	T	H	P	R	U	L
M	B	A	T	T	L	E	O	R	I	N	C	S	A	P	I	N	U
A	F	O	R	C	E	S	Y	T	E	T	O	H	M	O	C	I	S
T	I	N	V	A	D	E	A	E	L	R	N	E	E	M	H	O	I
I	G	O	A	L	O	P	L	Y	I	O	F	R	N	A	M	N	O
O	D	A	R	E	I	Y	T	M	G	L	E	M	D	T	O	A	N
N	E	A	H	C	A	B	Y	R	I	T	D	A	M	O	N	R	L
M	W	C	N	E	L	T	T	A	B	N	E	N	E	X	D	M	G
K	I	A	P	A	R	T	C	B	L	A	R	O	N	A	B	I	N
B	M	A	R	Y	L	A	N	D	E	R	A	O	T	Y	O	E	U
E	G	E	T	T	Y	S	B	U	R	G	T	B	B	E	A	S	H
S	H	E	R	I	D	A	N	V	A	N	E	L	A	N	N	H	I

WAR
LEE
OATH
GOAL
DARE
SLAVE
ARMY
FORCES
PART
BATTLE
HONOR
INVADE
RATIFY
GRANT
ADDRESS
REAFFIRM
ELIGIBLE
CONTROL
SHERIDAN
PURSUIT
RICHMOND
CONCLUSION
AMENDMENT
LOYALTY
BLOCKADE
MARYLAND
CONFEDERATE
SHERMAN
EMANCIPATION
RECONSTRUCTION
PROCLAMATION
GETTYSBURG
TURNING POINT
APPOMATOX
UNION ARMIES

303

២- ពាក្យច្របល់គ្នា

សេចក្តីណែនាំ ៖ សូមធ្វើអោយឃ្លានិមួយៗបានត្រឹមត្រូវ តាមរបៀបដោយជ្រើសរើសយកអក្សរដែលនៅច្របូកច្របល់គ្នាមករៀបចំឡើងវិញ ។

១- offernjes sivdaជាប្រធានាធិបតីនៃបក្សសម្ព័ន្ធ

២- collnin ជាប្រធានាធិបតីនៃសហរដ្ឋអាមេរិកក្នុងពេលដែលមានសង្គ្រាមក្នុងស្រុក ហើយដែលបានធ្វើសេចក្តីប្រកាសអោយបានរួចខ្លួនជាអ្នកជានូវពួកទាសភាពទាំងអស់

៣- oretrb ele ជាមេបញ្ជាការនៃកងទ័ពបក្សសម្ព័ន្ធ

៤- beturystgg ជាកន្លែងដែលលោកប្រធានាធិបតី Lincoln បានធ្វើសុន្ទរកថា ក្នុងការអំពាវនាវអោយប្រជាពលរដ្ឋជួយថែរក្សានូវសហភាពអោយបានគង់វង់

៥- anhesmr ជាឧត្តមសេនីយខាងបក្សសហភាព ដែលបានធ្វើការវាយលុកយ៉ាងវែងមួយតម្រង់ទៅរកសមុទ្រ ដោយកាត់តាមផ្នែកខាងត្បូង

៦- onemitanciap ជាសេចក្តីប្រកាសរបស់លោកប្រធានាធិបតី Lincoln ដើម្បីនឹងអោយដោះលែងនូវពួកទាសភាព ដែលនៅក្នុងរដ្ឋសម្ព័ន្ធ

៧- xppmaatoo uestchiou ជាភូមិមួយនៅ Virginia ដែលលោកឧត្តមសេនីយ Lee បានសុំចុះចូលជាមួយលោកឧត្តមសេនីយ Grant ហើយដែលបានបញ្ចប់សង្គ្រាមក្នុងស្រុក

៣- ការជ្រើសរើស

សូមជ្រើសរើសយកអក្សរណាមួយនៅពីមុខឃ្លា ដែលយល់ថា ពិតត្រឹមត្រូវ ឬ ជាចម្លើយរបស់សំនួរ ។

________ ១- បុព្វហេតុសំខាន់ៗ ដែលធ្វើអោយមានសង្គ្រាមក្នុងស្រុក ៖

ក- ការវាយលុកនៅបន្ទាយ Sumter
ខ- ឃាតកម្មនៃលោក Lincoln
គ- សេចក្តីកែសំរួលច្បាប់ទី ១៣
ឃ- ការប្រយុទ្ធនៅ Gettysburg

________ ២- គោលបំណងធំក្នុងការបិទផ្លូវសមុទ្រកាលជំនាន់មានសង្គ្រាមក្នុងស្រុក គឺដើម្បីធ្វើការជៀសវាងកុំអោយមាន ៖

ក. អ្នកស្ម័គ្រចិត្តជាតិអង់គ្លេសចូលទៅផ្នែកខាងត្បូង
ខ. ការដឹកនាំកប៉ាលទៅផ្នែកអឺរ៉ុប
គ. កងនាវាចររុស្ស៊ីចូលទៅធ្វើទស្សនកិច្ចនៅផ្នែកខាងត្បូង

__________ ៣. សេចក្តីប្រកាសអោយបានរួចខ្លួនជាអ្នកជា   ជា :

ក. ច្បាប់ដែលបង្កើតឡើងដោយរដ្ឋសភា
ខ. សេចក្តីកែប្រែច្បាប់នៅក្នុងរដ្ឋធម្មនុញ្ញ
គ. បញ្ជាពីលោកប្រធានាធិបតី
ឃ. ការដោះស្រាយរួមរបស់រដ្ឋសភា

__________ ៤. គោលបំណងរបស់លោកឧត្តមសេនីយ Sherman ក្នុងការវាយលុកឆ្ពោះទៅរកសមុទ្រ គឺដើម្បី :

ក. ដាប់អង្គប់លោកឧត្តមសេនីយ Lee
ខ. ជាជំនួយដល់ឧត្តមសេនីយ Grant
គ. វាយបំបែកពីគ្នានូវពួកសម្ព័ន្ធ
ឃ. វាយដណ្តើមយកអោយបាននូវចំការកប្បាសទាំងប៉ុន្មានសំរាប់ពួកខាងជើង

__________ ៥. លទ្ធផលសំខាន់ដែលបានមកពីសង្គ្រាមក្នុងស្រុកគឺ :

ក. បញ្ឈប់កុំអោយមានរឿងសិទ្ធិសេរីភាពរបស់រដ្ឋ
ខ. ដើម្បីនឹងពង្រឹងការទាក់ទងជាមួយស្រុកអង់គ្លេស
គ. ជាជំនួយដល់ការជ្រើសរើសយកឧស្សាហកម្មទៅលើកសិកម្មមកធ្វើជាមូលដ្ឋាននៃសេដ្ឋកិច្ចរបស់ប្រទេស
ឃ. ដើម្បីចាត់តាំងអោយពួកស្បែកខ្មៅនៃផ្នែកខាងត្បូងមានសិទ្ធិសេរីភាពដូចគេឯងវិញ

Section IV: CONFLICT AND REUNION

Packet 16: The Election of 1876

NEW WORDS: ពាក្យថ្មីៗ

remove: យកចេញ ដកចេញ

Congress tried to remove Johnson from the Presidency.

unconstitutional: ដែលមិនត្រូវតាមរដ្ឋធម្មនុញ្ញ

Johnson thought the Tenure of Office Act was unconstitutional

approval: ការយល់ព្រម

Johnson did not get the approval of Congress when he removed Stanton from office.

charge: ចោទ

The House of Representatives tried to impeach Johnson with 11 charges.

guilty: ខុស ដែលធ្វើខុស

The Senate said Johnson was "not guilty".

impeach: ការចោទដេញដោលដើម្បីរកកំហុសមន្ត្រីនយោបាយណាមួយ

majority: ភាគច្រើន

Neither Tilden nor Hayes won the majority of electoral votes in 1876.

Scalawag: មនុស្សខូច

Many Scalawags were condidered to be traitors by the Southerners.

Carpetbagger: មនុស្សផ្នែកខាងជើងដែលបានចូលទៅផ្នែកត្បូងដើម្បីធ្វើការកេងប្រវ័ញ្ច

Southerners also thought the Carpetbaggers were intruders and the blacks were collaborators.

traitor: ជនក្បត់

intruder: អ្នករំលោភ ឈ្លានពាន

collaborator: អ្នករួមគំនិតចូលដៃ

corruption: អំពើពុករលួយ

There was a lot of corruption during the Reconstruction years.

supremacy: ភាពខ្លាំងជាងគេ បរមានុភាព

White supremacy was re-established when the federal troops were taken out of the South.

advantage: មានប្រៀបជាង

The white southerners took advantage of the withdrawal of federal troops to get back their former positions.

deadlock: ទល់ ដោះស្រាយមិនរួចដោយភាពតុល្យា

The vote ended in a deadlock. No one won.

internal: ផ្ទៃក្នុង

The many groups in the South caused internal problems for that section.

improvement: ការធ្វើអោយប្រសើរឡើង

withdrawal: ដកថយ

READING:

16.1. RECONSTRUCTION AND THE ELECTION OF 1876:

16.1.1. The Civil War ended in 1865. The years between 1865 and 1876 are known as the Reconstruction years. During this time American Presidents and the United States Congress attempted to rebuild and reunite the country which had been damaged and divided by the Civil War. However, there were many problems which occured during the Reconstruction years.

16.1.2. The first problem was the conflict between the Presidents and the United States Congress. After Abraham Lincoln was assassinated, Vice President Johnson became the President of the United States. He became President at a time when the Congress was determined to limit the power of the

President. In an effort to limit the President's power, Congress passed the **Tenure of Office Act**. This law said that the President could not remove a federal official without the approval of the Congress. Johnson thought that the law was unconstitutional and ignored it when he dismissed Edwin M. Stanton, the Secretary of War, without the consent of Congress. The Congress tried to "impeach" Johnson. They tried to stop him from being President. The effort failed, but Republicans no longer trusted Johnson. They did not want him to be the President again in 1868. The Republicans chose Ulysses S. Grant, the former Civil War General, to run for President in 1868. He won the election and was President for two terms. But Grant, like Johnson, was not able to control Congress.

16.1.3. Because neither Johnson nor Grant could control Congress' Reconstruction Plan, a second problem occured. Many different groups of people appeared in the South. Instead of helping the South become part of the nation again, these groups continued to anger the Southerners. Congress sent many soldiers to the South to try to restore order and to protect the newly-won rights of the blacks. The Southerners did not like having the soldiers on their land. Also, many Northerners came to the South to get rich. The Southerners called these intruders "**Carpetbaggers**". The newly-freed blacks now had a new life. Many of them took jobs that were once held by whites in the federal and state governments. This angered whites so much that many of them organized secret hate societies against the blacks. Two of the groups, the Ku Klux Klan and the Knights of the White Magnolia, killed or terrorized many blacks. They also terrorized white Southerners known as "Scalawags." Scalawags are ex-Confederates who cooperated with the Reconstruction government. All the different groups, the soldiers, the Carpetbaggers, the ex-slaves, the Scalawags, the Ku Klux Klan, and the Knights of the White Magnolia, helped keep Southern anger against the North alive. They did not help to reunite the two sections.

16.1.4. The third problem which occurred during Reconstruction years related to money. There were two types of money problems: corruption and depression. Boss Tweed in New York City and the "Whiskey Ring" in St. Louis were just two examples of corruption that could be found throughout the nation. The economy was not stable. Railroads were developing so fast that the country's credit was weakened. World demand for American farm products had grown smaller. In 1873 one of the country's biggest banks - Jay Cook and Company - failed. Hundreds of businesses had to close; many people lost their jobs. The panic of 1873 started a terrible depression which President Grant could not lessen or change.

16.2. THE ELECTION OF 1876: A COMPROMISE BETWEEN REPUBLICANS AND DEMOCRATS

16.2.1. The problems of the Reconstruction years -- the conflict between the President and Congress, the appearance of different groups in the South which further divided the nation and the problems of corruption and depression -- were all issues in the election of 1876 between the Republican, Rutherford Hayes, and the Democrat, Samuel Tilden. Although Tilden won the popular vote, neither candidate received the clear majority of electoral votes (185) needed to win the Presidency. Tilden had received 184 electoral votes and Hayes had received 165. A dispute centered around four Southern states which had sent in two different sets of 20 votes. Whoever won these 20 votes would have the required 185 and would become the winner. Both Republicans and Democrats said they had won these votes. The House of Representatives created a special Commission of 15 members to decide these votes. The Commission voted 8-7 that Hayes had won the votes. Rutherford Hayes became the new President. However, to avoid making the Southerners angry, the Commission forced Hayes to accept two conditions that would please the South:

1. Federal troops must be withdrawn from the South and
2. White Southerners were allowed to organize their own civil governments.

16.2.2. President Hayes began his job by removing the federal troops from Louisiana and South Carolina. After federal troops left, white southerners quickly got back their former positions. Soon the whites controlled all political and social activities in the South. By compromising with the Southern Democrats, Northern Republicans had given up their efforts to protect the rights of the blacks. After 10 years, the Reconstruction Plan had failed to change the social relationship between the whites and the blacks.

EXERCISES

I. Word Search Puzzle.

Direction: Find and circle the words in the word search puzzle below. The words will be found vertically, horizontally, and diagonally. When you find a word, write it down and then define it.

O R S T V Y S U P R E M E T O N S C

A S O N T P R E M O V E P S T O R O

B T U L R S T R A I T O R M N O Q R

C S I N O Q C R I N T E R N A L M R

D U N C O N S T I T U T I O N A L U

G P O H A T B E T R A Y N O J P P P

E E T A S R O E R U I N O O K P Q T

F M U R T O P P S D O O R M T R R I

G E U G C T N S O E O I O B O O K O

I M P E A C H E D R T I L I K U S N

H E R S R O P S O Y P R Q U T E T S

O C S R N O C O L L A B O R A T O R

S Y W I T H D R A W I N G N O T Q R

- GUILTY
- REMOVE
- TRAITOR
- CORRUPTION
- WITHDRAWING
- COLLABORATOR
- IMPEACH
- SUPREME
- UNCONSTITUTIONAL
- MAJORITY
- BOOK
- BETRAY
- INTRUDER
- CHARGES

II. Matching

Match the term in the left column with a description in the right column.

	A	B
____	a. remove	1. the act of approving.
____	b. impeach	2. the offering and accepting bribes.
____	c. scalawag	3. to move from a position occupied.
____	d. corruption	4. to charge with malfeasance in office before a proper tribunal.
____	e. approval	5. to bring back into existence or use.
____	f. intruder	6. to coerce by intimidation or fear.
____	g. majority	7. a sudden terror, often affecting many people at once.
____	h. panic	8. one who enters as an improper or unwanted element.
____	i. terrorize	9. number of votes for one side which exceed those for the other side.
____	h. restore	10. a southerner who worked with the Reconstruction government.

III. Time-line study

Put each event at the appropriate time on the time-line below

1. The Civil War started.
2. Ulyssess Grant was nominated as the Republican Presidential candidate.
3. The Emancipation Proclamation was declared by President Lincoln.
4. The end of the Civil War.
5. The last federal troops withdrew from the South.
6. The presidential election between Samuel Tilden and Rutherford Hayes.
7. The first economic depression occurred in the U.S.A.

8. The Congress adopted the Tenure of Office Act.



IV. Multiple Choice.

Select the number preceding the word or expression that best completes each statement.

1. Hayes' opponent in the Presidential election of 1876 was (a)General Sherman (b)Samuel Tilden (c)William Richardson.

2. During President Grant's administration a notorious and corrupt local political machine was (a) the Knights of the White Camelia (b) Tweed Ring (c) Ku Klux Klan.

3. In order to carry out their programs, the Radical Republicans tried to (a) reduce the power of the President (b) enlarge the size of the army (c) keep blacks from voting.

4. Carpetbaggers were generally (a) welcomed in the South (b) regarded by Southerners as intruders (c) opposed to the Reconstruction Plan of the Government.

5. President Johnson and Congress argued about (a) freeing the slaves (b) who had the power to plan and to carry out Reconstruction policies (c) the presidential election in 1868.

ការសាង

១៦-១ ការរៀបចំកសាងឡើងវិញ និង ការបោះឆ្នោតនៃឆ្នាំ ១៨៧៦

១៦-១-១ សង្គ្រាមក្នុងស្រុកបានចប់សព្វគ្រប់នៅឆ្នាំ ១៨៦៥ ។ ក្នុងចន្លោះឆ្នាំ១៨៦៥ និង ឆ្នាំ១៨៧៦ ជារយៈពេលដែលមានឈ្មោះហៅថា ឆ្នាំកសាងឡើងវិញ ។ នៅពេលនោះ ប្រធានាធិបតី ព្រមទាំងរដ្ឋសភាអាមេរិកាំង បានខំប្រឹងប្រែងដើម្បីនឹងធ្វើការកសាង និង បង្រួបបង្រួមស្រុកឡើងវិញ ពីព្រោះពេលនោះស្រុកត្រូវខូចខាតយ៉ាងធ្ងន់ ព្រមទាំងបានបែកចេញពីគ្នា ដោយសារសង្គ្រាមក្នុងស្រុកទៀតផង ។ ប៉ុន្តែកិច្ចការជំនាន់ការកសាងនោះបានត្រូវជួបឧបសគ្គជាច្រើន ។

១៦-១-២ បញ្ហាទីមួយគឺ បញ្ហាទាស់គំនិតគ្នារវាងប្រធានាធិបតី និងរដ្ឋសភាអាមេរិកាំង ។ បន្ទាប់ពីមានឃាតកម្មលើលោក Abraham Lincoln មក លោកអនុប្រធានាធិបតី Johnson ក៏បានឡើងកាន់កាប់ដំណែងជំនួស ។ ពេលដែលលោកឡើងកាន់អំណាចនេះ គឺជាពេលដែលរដ្ឋសភាចង់ធ្វើការកំរិតនូវអំណាចនៃប្រធានាធិបតីតែម្តង ។ ចំពោះការប្រឹងប្រែងនេះ រដ្ឋសភាក៏បានបង្កើតច្បាប់មួយឈ្មោះ ច្បាប់សំរាប់កាន់កាប់មុខដំណែង។ ច្បាប់នេះបានចែងថា ប្រធានាធិបតីត្រូវមានការយល់ព្រមពីរដ្ឋសភាសិន មុននឹងអាចដកដំណែងចេញពីបុគ្គលិករដ្ឋការណាមួយ ។ រដ្ឋសភាចង់ដេញដោលរកកំហុសលោក Johnson ដោយមិនចង់អោយលោកធ្វើប្រធានាធិបតី ។ ប៉ុន្តែអំពើនេះមិនមានជោគជ័យឡើយហើយ ពេលនោះបក្សសាធារណៈរដ្ឋ ក៏លែងមានការទុកចិត្តលើលោកទៀត ។ ពួកគេមិនចង់អោយលោក Johnson នេះជាប់ឆ្នោតធ្វើជាប្រធានាធិបតីលើកទីពីរទៀតនៅឆ្នាំ ១៨៦៨ ដូច្នេះពេលនោះគេក៏បានជ្រើសរើសយកលោក Ulysses S. Grant ដែលជាអតីតឧត្តមសេនីយ កាលជំនាន់សង្គ្រាមក្នុងស្រុកអោយឈរឈ្មោះដំណាងបក្សគេ ក្នុងការបោះឆ្នោតរើសប្រធានាធិបតីនៅឆ្នាំ ១៨៦៨នោះ ។ លោក Grant ក៏បានជាប់ឆ្នោតធ្វើប្រធានាធិបតីអស់ពីររយៈ ។ ក្នុងពេល ៨ ឆ្នាំនោះ លោក Grant ក៏ដូចលោក Johnson ដែរគឺមិនអាចធ្វើការត្រួតត្រាទៅលើរដ្ឋសភាបានឡើយ ។

១៦-១-៣ ដោយសារលោក Grant និងលោក Johnson នេះមិនអាចត្រួតត្រាទៅលើផែនការណ៍នៃការកសាងរបស់រដ្ឋសភាបាន ពេលនោះបញ្ហាទីពីរក៏កើតមានឡើងទៀត ។ នៅពេលនោះមានក្រុមមនុស្សប្លែកពួកគ្នាជាច្រើន បានកើតមានឡើងនៅផ្នែកខាងត្បូង ។ ពួកនេះមិនបានធ្វើការបង្រួបបង្រួមប្រទេសឡើងវិញទេ គឺរិតតែធ្វើអោយពួកខាងត្បូងខឹងសម្បារខ្លាំងថែមទៀត ។ រដ្ឋសភាបានបញ្ជូនទាហានជាច្រើនទៅ

ផ្នែកខាងត្បូង ដើម្បីនឹងជួយធ្វើអោយមានភាពត្រឹមត្រូវឡើងវិញ ព្រមទាំងសំរាប់ការពារដល់ពួកស្បែកខ្មៅ ដែលទើបនឹងបានសេរីភាពថ្មីៗផង ។ ពួកផ្នែកខាងត្បូងមិនសប្បាយចិត្តនឹងឃើញទាហាននៅលើទឹកដីខ្លួនឡើយ ថែមពីលើនេះ ពួកខាងជើងដែលចូលមកផ្នែកខាងត្បូង គឺដើម្បីសំរាប់តែចង់មានទ្រព្យប៉ុណ្ណោះ ។ ពួកខាងត្បូងហៅឈ្មោះ ពួកឈ្លានពាននេះថា "Carpetbaggers" ។ពួកស្បែកខ្មៅ ដែលបានទទួលសិទ្ធិសេរីភាពថ្មីៗ ក៏បានចាប់ផ្ដើមជីវភាពរស់នៅជាថ្មីម្ដងទៀត ។ ពួកនេះបានទទួលកិច្ចការជាច្រើននៅក្នុងរដ្ឋាភិបាលរដ្ឋ និង រដ្ឋាភិបាលរួម ដែលពីមុនមានសុទ្ធតែពួកស្បែកសកាន់កាប់ប៉ុណ្ណោះ ។ ព្រឹត្តិការណ៍នេះបានធ្វើអោយពួកស្បែកសផ្នែកខាងត្បូងខឹងនឹងអាក់អន់ចិត្តជាខ្លាំង ដែលបណ្ដាលអោយពួកខ្លះចាប់ផ្ដើមបង្កើតជាក្រុមសំងាត់ឡើង ដើម្បីសំរាប់ប្រឆាំងនឹងពួកស្បែកខ្មៅ ។ ក្រុមពីរគឺក្រុម Ku Klux Klan និងក្រុម Knights of the White Magnolia បានបង្កើតអោយមានការចលាចលក្នុងចំណោមពួកស្បែកខ្មៅ និង បានសម្លាប់ពួកនោះអស់ជាច្រើននាក់ផង ។ ក្រុមទាំងពីរនេះ ព្រមទាំងប្រព្រឹត្តអំពើឃោរឃៅរបស់ខ្លួនទៅលើពួកស្បែកសខ្លះនៃផ្នែកខាងត្បូង ដែលគេចាត់ទុកថាជាពួកមនុស្សខូច "Scalawags" ។ ពួកScalawags ជាពួកសម្ព័ន្ធពីដើម ហើយដែលបានធ្វើសហប្រតិបត្តិការជាមួយរដ្ឋាភិបាល ក្នុងការរៀបចំកសាងឡើងវិញ ។ បក្សពួកផ្សេងៗគ្នាទាំងអស់នេះហើយ គឺ ពួកទាហាន ពួក Carpetbaggers ពួកទាសភាពពីមុន ពួក Scalawags ពួក Ku Klux Klan និងពួក Knights of the White Magnolia រិតតែបានធ្វើអោយពួកផ្នែកខាងត្បូងមានការខឹងសម្បារជាមួយពួកផ្នែកខាងជើងខ្លាំងថែមទៀត ។ ពួកនោះមិនបានជួយប្រឹងប្រែងអោយផ្នែកទាំងពីរបានស្រុះស្រួលគ្នាវិញឡើយ ។

១៦-១-៤ បញ្ហាទីបីដែលកើតឡើងកាលជំនាន់នោះ គឺទាក់ទងទៅនឹងរឿងលុយកាក់ៗ រឿងលុយកាក់មានពីរយ៉ាងគឺ : អំពើពុករលួយ និង ស្ថានភាពនៃសេដ្ឋកិច្ច ដែលធ្លាក់ចុះដុនដាបជាខ្លាំង ។ ពួក Boss Tweed នៅ New York និងពួក Whiskey Ring នៅ St.Louis ជាឧទាហរណ៍នៃអំពើពុករលួយពីរ ដែលគេបានឃើញមាននៅគ្រប់ទីកន្លែងក្នុងប្រទេស ។ នៅពេលនោះ ដំណើរសេដ្ឋកិច្ចមិនទាន់មានភាពរឹងប៉ឹងនៅឡើយ ផ្លូវរទេះភ្លើងបានកើតឡើងយ៉ាងឆាប់រហ័ស ដែលបណ្ដាលអោយថវិការមានការតឹងតែងជាខ្លាំង ។ បន្ថែមពីលើនេះ ផលិតផលស្រែចំការរបស់អាមេរិកាំងនៅផ្សារបរទេសក៏បានចុះថយជាខ្លាំងដែរ ដោយគេមិនសូវត្រូវការ ។ នៅឆ្នាំ ១៨៧៣ ធនាគារមួយយ៉ាងធំនៅក្នុងក្រុមឈ្មោះ Jay Cook & Company បានត្រូវរលំបិទទ្វារ ពេលនោះជំនួញរាប់រយកន្លែងទៀតក៏បានបិទទ្វារដែរ ដែលបានធ្វើអោយមនុស្សជាច្រើននាក់អត់ការធ្វើ ។ ភាពរំជើបរំជួលនៅឆ្នាំ ១៨៧៣នោះ បានធ្វើអោយសេដ្ឋកិច្ចចុះដុនដាបយ៉ាងខ្លាំង ដែលលោកប្រធានាធិបតី Grant មិនអាចធ្វើអោយធូរស្រាល ឬក៏អាចផ្លាស់ប្ដូរស្ថានភាពបានឡើយ ។

១៦-២ ការបោះឆ្នោតនៃឆ្នាំ ១៨៧៦ ៖ ការសំរបសំរួលរវាងបក្សសាធារណរដ្ឋ និង បក្សប្រជាធិបតេយ្យ

១៦-២-១ បញ្ហានៃការកសាងឡើងវិញ ការទាស់គំនិតគ្នារវាងប្រធានាធិបតី និងរដ្ឋសភា ការកើតឡើងនៃបក្សពួកផ្សេងគ្នា នៅផ្នែកខាងត្បូង ដែលពិតជាបានធ្វើអោយប្រទេសកាន់តែបែកចេញពីគ្នាខ្លាំងឡើង អំពើពុករលួយ និង បញ្ហាចុះដុនដាបជាខ្លាំងនៃសេដ្ឋកិច្ច គឺជារឿងសំខាន់ៗ ដែលបានចោទឡើងនៅពេលបោះឆ្នោតរើសប្រធានាធិបតីនៃឆ្នាំ ១៨៧៦ រវាងលោក Rutherford Hayes នៃគណៈបក្សសាធារណរដ្ឋ និងលោក Samual Tilden នៃគណៈបក្សប្រជាធិបតេយ្យ ។ បេក្ខជនទាំងពីរនេះគ្មាននរណាមួយ ដែលបានទទួលសំលេងសភាឆ្នោតប្រជារាស្ត្រអោយឃើញថាពិតជាឈ្នះឡើយ (- គឺត្រូវទទួល ១៨៥ សម្លេង ដើម្បីនឹងអាចឈ្នះធ្វើប្រធានាធិបតីបាន -) ។ លោក Tilden បានទទួល ១៨៤ សម្លេង ហើយលោក Hayes បាន ១៦៥ ។ ពេលនោះការទាស់ទែងគ្នាក៏បានកើតមានឡើង ក្នុងរឿងដែលរដ្ឋផ្នែកខាងត្បូង ៤ បានផ្ញើរសេចក្តីបោះឆ្នោតចំនួន ២០ ដែលមានពីរពុម្ពខុសគ្នា ។ ដូច្នេះបើបេក្ខជនណាបានទទួលសម្លេង ២០ នេះបន្ថែមទៀត គេនឹងបានគ្រប់ចំនួន ១៨៥ តែម្តង ហើយគេក៏បានជាប់ឆ្នោតធ្វើជាប្រធានាធិបតីដែរ ។ បក្សសាធារណរដ្ឋ ក៏ដូចជាបក្សប្រជាធិបតេយ្យដែរ សុទ្ធតែបានប្រកាសថាខ្លួនឈ្នះ ដូច្នេះពេលនោះ សភាក៏បានបង្កើតអោយមានគណៈកម្មការពិសេសមួយ ដែលមានសមាជិក ១៥ នាក់សំរាប់អោយសំរេចពីការបោះឆ្នោតនោះ ។ គណៈកម្មការនេះបានសំរេចចិត្ត ៨ សម្លេងទល់នឹង ៧ សម្លេងអោយលោក Hayes បានជាប់ធ្វើជាប្រធានាធិបតី ប៉ុន្តែដើម្បីជៀសវាងកុំអោយពួកផ្នែកខាងត្បូងខឹង គណៈកម្មការនេះក៏បានបង្ខំអោយលោក Hayes ទទួលយល់ព្រមនឹងលក្ខ័ណ្ឌពីរ ដែលអាចធ្វើអោយពួកផ្នែកខាងត្បូងសប្បាយចិត្តបាន គឺ ៖

១- កងទ័ពសហភាពត្រូវដកចេញពីផ្នែកខាងត្បូង

២- ពួកស្បែកសនៃផ្នែកខាងត្បូង នឹងអនុញ្ញាតិអោយរៀបចំរដ្ឋាភិបាលក្នុងរដ្ឋនិមួយៗបាន ។

១៦-២-២ លោកប្រធានាធិបតី Hayes ចាប់ផ្តើមកាន់អំណាចដោយដកកងទ័ពសហភាពចេញពីរដ្ឋ Louisiana និងរដ្ឋ South Carolina ។ បន្ទាប់ពីកងទ័ពចេញផុតពីផ្នែកខាងត្បូងមក ពួកស្បែកសក៏បានវិលមកកាន់កាប់អំណាចខ្លួនពីមុនវិញ ។ អស់ពេលយ៉ាងខ្លីក្រោយមក ពួកស្បែកសក៏បានកាន់កាប់គ្រប់គ្រងនៅគ្រប់សកម្មភាពនៃនយោបាយ និង សង្គមទាំងអស់ ។ ដោយសារការសំរបសំរួលជាមួយពួកប្រជាធិបតេយ្យនៃផ្នែកខាងត្បូង ពួកសាធារណៈនៃផ្នែកខាងជើងក៏បានបោះបង់ចោលនូវការខិតខំរបស់ខ្លួន ក្នុងការការពារសិទ្ធិសេរីភាពពួកខ្មៅតែម្តង ។ អស់រយៈពេល ១០ឆ្នាំកន្លងមក វិធានការថ្មីនៃការកសាងឡើងវិញមិនបានមានជោគជ័យក្នុងការរៀបផ្លាស់ប្តូរនូវការទាក់ទងរវាងសង្គមពួកស និង សង្គមពួកខ្មៅឡើយ ។

ការហាត់

១- របៀបរកពាក្យ

សេចក្ដីណែនាំ : សូមរក និង គូសរង្វង់ជុំវិញនូវពាក្យទាំង ១៤ នៅក្នុងរបៀបរកពាក្យខាងក្រោម ។ ពាក្យទាំងនោះអាចរកឃើញតាមរបៀបបញ្ឈរ ផ្ដេក និងបញ្ច្រាស ។ ពេលដែលរកឃើញនូវពាក្យនីមួយៗ សូមគូសខ្សែដាក់នៅពីក្រោម ព្រមទាំងអោយអត្ថន័យនៃពាក្យនោះផង ។

O R S T V Y S U P R E M E T O N S C

A S O N T P R E M O V E P S T O R O

B T U L R S T R A I T O R M N O Q R

C S I N O Q C R I N T E R N A L M R

D U N C O N S T I T U T I O N A L U

G P O H A T B E T R A Y N O J P P P

E E T A S R O E R U I N O O K P Q T

F M U R T O P P S D O O R M T R R I

G E U G C T N S O E O I O B O O K O

I M P E A C H E D R T I L I K U S N

H E R S R O P S O Y P R Q U T E T S

O C S R N O C O L L A B O R A T O R

S Y W I T H D R A W I N G N O T Q R

GUILTY
REMOVE
TRAITOR
CORRUPTION
WITHDRAWING
COLLABORATOR
IMPEACH
SUPREME
UNCONSTITUTIONAL
MAJORITY
BOOK
BETRAY
INTRUDER
CHARGES
INTERNAL

២. ការប្រៀបផ្ទឹម : សូមប្រៀបផ្ទឹមពាក្យ ឬ ឃ្លា ដែលនៅខាងឆ្វេង ទៅនឹងអត្ថន័យដែលនៅខាងស្តាំ ។

១.	quilty	:	ក. ភាពដែលប្រសើរជាង ឬ ធំជាង
២.	impeach	:	ខ. ផ្ទៃក្នុង បញ្ហាក្នុងស្រុក
៣.	majority	:	គ. ទាល់ផ្លូវ ដោយមិនអាចដោះស្រាយបាន
៤.	Scalawag	:	ឃ. ធ្វើកំហុស
៥.	traitor	:	ង. ការស្លូក ឬ ទទួលសំណូក
៦.	corruption	:	ច. ប្តឹងចោទដើម្បីរកកំហុសនូវមន្ត្រីនយោបាយណាមួយ
៧.	supremacy	:	ឆ. ចំនួនឆ្នោតខាងផ្នែកណាមួយដែលមានចំនួនច្រើនជាងផ្នែកមួយទៀត
៨.	advantage	:	ជ. ជនផ្នែកខាងត្បូងដែលបានធ្វើសហប្រតិបត្តិការជាមួយរដ្ឋាភិបាលសហព័ន្ធ កសាងឡើងវិញ
៩.	deadlock	:	ឈ. មនុស្សណាមួយដែលមានចិត្តមិនស្មោះត្រង់ជាមួយមិត្តភក្តិ
១០.	internal	:	ញ. អាជ្ញាធរផ្នែកលើ ដែលមានអំណាចខ្លាំងបំផុត

៣. ការសិក្សាពីពេលវេលា

សូមដាក់ពេលវេលាអោយបានត្រឹមត្រូវ ទៅនឹងព្រឹត្តិការណ៍និមួយៗ ដែលបានរៀបរាប់ខាងក្រោមនេះ ។

១. សង្គ្រាមក្នុងស្រុកបានចាប់ផ្តើមឡើងនៅឆ្នាំ ______________

២. លោក Ulysses S. Grant បានត្រូវជ្រើសតាំងអោយធ្វើបេក្ខជនតំណាងបក្សសាធារណៈរដ្ឋ ក្នុងការបោះឆ្នោតរើសប្រធានាធិបតីនៅឆ្នាំ ------

៣. សេចក្តីប្រកាសអោយបានរួចខ្លួនជាអ្នកជា ដោយលោកប្រធានាធិបតី Lincoln បានធ្វើឡើងនៅឆ្នាំ ----------

៤. សង្គ្រាមក្នុងស្រុកបានបញ្ចប់សព្វគ្រប់នៅឆ្នាំ ----------

៥. កងទ័ពសហភាព បានដកចេញពីផ្នែកខាងត្បូងនៅឆ្នាំ ----------

៦. ការបោះឆ្នោតរើសប្រធានាធិបតីរវាងលោក Samuel Tilden និងលោក Rutherford Hayes បានធ្វើឡើងនៅឆ្នាំ------

៧. ជាលើកដំបូង ដែលសេដ្ឋកិច្ចសហរដ្ឋអាមេរិកបានចុះដុនដាបយ៉ាងខ្លាំង គឺនៅឆ្នាំ ----------

៨. រដ្ឋសភា ដែលបានបង្កើតច្បាប់សំរាប់ការកាន់កាប់ដីថែងនៅឆ្នាំ-------



៥. ការជ្រើសរើសយក : សូមជ្រើសរើសយកអក្សរណាមួយ ដែលនៅក្នុងចំណោមអក្សរទាំងបី ដែលយល់ថាត្រឹមត្រូវសំរាប់សំនួរនោះៗ

១. អ្នកឈរឈ្មោះប្រកួតនឹងលោក Hayes ក្នុងការបោះឆ្នោតរើសប្រធានាធិបតីនៃឆ្នាំ ១៨៧៦ គឺ :

ក. លោកឧត្ដមសេនីយ៍ Sherman
ខ. លោក Samuel Tilden
គ. លោក William Richardson

២. កាលជំនាន់រដ្ឋាភិបាលលោកប្រធានាធិបតី Grant បក្សពួកនយោបាយក្នុងស្រុកដែលបានល្បីឈ្មោះដោយសារអំពើពុករលួយ គឺ :

ក. ពួក the Knights of White Magnolia
ខ. ពួក Boss Tweed
គ. ពួក Ku Klux Klan

៣. ដើម្បីនឹងចង់ធ្វើកិច្ចការអោយស្របទៅតាមសេចក្ដីតម្រូវនៃកម្មវិធីរបស់ខ្លួន ពួកមូលវិវដ្ដនិយមនៃគណៈបក្សសាធារណៈរដ្ឋក៏បានគិតចំធ្វើអោយមាន :

ក. ការបន្ថយអំណាចរបស់ប្រធានាធិបតី
ខ. ការពង្រីកកំលាំងកងទ័ពអោយបានរិតតែខ្លាំងឡើងថែមទៀត
គ. ការជៀសវាងមិនអោយពួកស្បែកខ្មៅអាចបោះឆ្នោតបាន

៤- ពួក Carpetbeggers ច្រើនតែជាពួក :

- ក- ដែលគេទទួលស្គាល់តាមនឹងនៅផ្នែកខាងត្បូង
- ខ- ដែលមនុស្សផ្នែកខាងត្បូងច្បាស់ថា ចាត់ទុកថា ជាអ្នកចូលលុកលុយទាំងពាក្យពេព្រុកតេ
- គ- ដែលបានប្រឆាំងនឹងគំរោងការរៀបចំការកសាងរបស់រដ្ឋាភិបាល

៥- លោកប្រធានាធិបតី Johnson និង សភា បានទាស់ទែងគ្នាពីរឿង :

- ក- ដោះលែងពួកទាសភាព
- ខ- តើនរណាដែលមានអំណាចក្នុងការចាត់ការនូវគំរោងការរៀបចំការកសាងឡើងវិញ
- គ- បោះឆ្នោតរើសប្រធានាធិបតីនៃឆ្នាំ ១៨៦៨

Section V
The Transformation Of A Nation

Section V: THE TRANSFORMATION OF A NATION

Packet 17. THE AGE OF INDUSTRIALIZATION

NEW WORDS ពាក្យថ្មីៗ

industrialization: ឧស្សាហូបនីយកម្ម

Before the Civil War industrialization had taken place in the North.

mining: ការជីករកត្បូងរ៉ែ

The industries of mining and cattle raising developed in the West.

cattle raising: ការចិញ្ចឹមគោ

gold rush: សម័យដែលមនុស្សផ្លាស់រកជីកមាសនៅផ្នែកខាងលិច

During the gold rush, many miners moved to California.

ghost town: ភូមិគ្មានមនុស្សនៅ ព្រោះគេបោះបង់ចោល

When the miners moved to a new area, the towns they left behind were ghost town.

nutrition: ចំណីអាហារចាំបាច់សំរាប់ចិញ្ចឹមជីវិត

Beef was a source of nutritions for Southern Armies during the Civil War.

rancher: អ្នករកស៊ីចិញ្ចឹមសត្វ គោ សេះ ។ល។

Rangers moved their cattle to the railroad terminals in the mid-west.

railroad terminal: ស្ថានីយរថភ្លើង

long drive: ការធ្វើដំណើរជាមួយហ្វូងគោឆ្ពោះទៅរកស្ថានីយរថភ្លើងដោយអស់ពេលយ៉ាងយូរ

Walking the cattle from Texas to market was called the long drive.

barbed wire: ខ្សែលួសបន្លា

New inventions, such as barbed wire, irrigation and crop rotation helped farmers become richer.

irrigation: ចំណប់ទឹក

croprotation: ការដាំដំណាំបង្វិលឆ្លាស់គ្នា

bonanza farmer: អ្នកធ្វើស្រែដែលមានទ្រព្យដោយបំរើលើកខ្លួនឯង

The farmers who became wealthy were called bananza farmers.

sharecrop farmer: អ្នកស្រែឈ្នួលដែលខ្វះលុយពីម្ចាស់ដីដើម្បីទិញពូជ ឬ ឧបករណ៍ ហើយដែល ត្រូវសងទៅម្ចាស់ដីគេវិញនូវផលិតផលមួយចំណែកបន្ទាប់ពីពេលច្រូតកាត់រួច
Farmers who could not afford to buy seed of tools became share-crop or crop-lien farmers.

crop-lien farmer: អ្នកស្រែឈ្នួលដែលបានខ្ចីលុយពីម្ចាស់ដីឬអ្នកជំនួញដើម្បីទិញពូជ ឬ គ្រឿងឧបករណ៍ ធ្វើស្រែ ហើយដែលត្រូវសងទៅគេវិញនូវផលិតផលខ្លួនស្ទើរតែទាំងអស់

transcontinental lines: ក្រុមហ៊ុនរថភ្លើងដែលធ្វើដំណើរកាត់ប្រទេសពីចុងម្ខាងទៅចុងម្ខាង
The railroad companies built four transcontinental lines across the United States.

vertical organization: ជាវិធានការណ៍នៃក្រុមហ៊ុនណាមួយសំរាប់ធ្វើការត្រួតត្រា ការងារបង្កើតកិច្ចប្រតិបត្តិការដោយខ្លួនឯង
Andrew Carnegie used the vertical organization method of development to increase the size of his industry.

meat packing: ការខ្ចប់សាច់ដាក់ប្រអប់

The ment packing industry grew in the Chicago, Illinois area.

union: សហជីព អង្គការសហភាពនៃកម្មករ

The labor unions were organized by workers in an effort to get better working conditions.

trust: ពាណិជ្ជកម្ម ឬ ក្រុមពាណិជ្ជកម្មណាដែលកាន់កាប់ការគ្រប់គ្រងនៃឧស្សាហកម្ម ឬ ផលិតផល ជាច្រើនណាមួយ ដែលគេហៅថាកិរិតកម្មផ្តាច់
Wealthy industrialist such as Rockefeller and Carnegie used trusts to create a monopoly in the oil and steel industries.

monopoly: ការផ្តាច់មុខ

lockout: ក្រុមហ៊ុនណាមួយដែលមិនព្រមជួលអ្នកធ្វើការ ក្នុងពេលបំណងនឹងរំលំសហជីព

blacklist: បញ្ជីឈ្មោះមនុស្សណាដែលជាសមាជិកនៃសហជីព ដើម្បីស្រួលរកឲ្យ
ម្ចាស់ការ ចុះបញ្ជីឈ្មោះមនុស្សនោះ មិនឲ្យធ្វើការ ។

The labor bosses tried to stop workers' strikes in three ways. the lockout, the blacklist, and the yellow dog contract.

the yellow dog contract: សេចក្តីព្រមព្រៀងរវាង អ្នកធ្វើការនឹងម្ចាស់ការ ដែលកម្មករនោះយល់ព្រមថា នឹងមិនចូលរួមជាមួយសហជីពទេ ។

violence: ភាពសាហាវ ឃោរឃៅ

There was often violence between striking workers and the management.

concern: កង្វល់ ធ្វើអោយខ្វល់

The Meat Inspection Act was created after consumers indicated concern over the quality of meat being sold at the markets.

consumer: អ្នកប្រើប្រាស់របស់របរ

READING:

17.1. NEW ECONOMIC DEVELOPMENTS:

17.1.1. The years between 1875 and 1900 were a time of great growth for American industry. The New England and Northern States, already industrial areas, continued to attract new factories and businesses. In addition, industry began to develop in the primarily rural areas of the South and the West.

17.1.2. The mining, cattle raising and farming industries which had dominated the West for almost a hundred years began to develop rapidly. Because of the California gold rush in 1849, many miners had moved to the West. The rich miners formed mining companies,which bought equipments, hired workers and helped established many small towns. When the mining companies and the miners moved West, businessmen followed them in pursuit of trade. Many new roads and railroads were built in the Far West to transport raw materials and goods to both the miners and the businessmen.

17.1.3. The cattle raising industry began to develop during the Civil War when beef from Texas was used to feed the Southern Armies. After the war, the industry flourished when the ranchers found that cattle could be raised cheaply in Texas and sold for high prices in the North and the East. Since the railroads reached only to Omaha, Nebraska, the ranchers had to move the herds from Texas to the railroad terminals in the Midwest. This moving of the herds was called the long drive.

17.1.4. In addition to mining and cattle raising, farming also became a vital industry on the Great Plains. At first, farming in the West was not easy as cattle raising. The soil was poor and dry. But farmers invented new methods, such as scientific machinery, irrigation and crop rotation, to cultivate this land. Some farmers, most particulary those who grew wheat in North and South Dakota, became sucessful and rich. They became known as the "bonanza farmers".

17.1.5. While mining, cattle raising and farming industries were developing in the West, the textile, steel and petroleum industries were begining to flourish in the South. Before the Civil War the South was a rural area which produced tobacco, rice, cotton and indigo. The South did not have an Industrial Revolution like the North. But the Civil War destroyed almost everything in the South. So, from 1870 to 1900, many things changed. The South, rich in resources such as coal and iron ore, began to develop these resources. The poor whites and the freed blacks made up a large labor force to work in the newly constructed textile, steel and petrolium factories. Birmingham in Alabama become the second largest steel city in the United States.

17.2. THE ORGANIZATION OF INDUSTRY AND LABOR

17.2.1. American industry grew very fast after the Civil War. In 1859 industrial profits were 2 million dollars, but by 1900 industry had made about 13 billion dollars and American factories were producing more goods than factories in any other country in the world.

17.2.2. Rich natural resources, large work forces, and high tariffs helped American industries to grow. Rapid transportation was needed to transport new material and goods to and from the factories. As a result, the railroad industry became one of the most rapidly growing industries. Four transcontinental lines crossed the country. The Federal

Government gave the railroad companies public land for the tracks. Steel was badly needed to make the rails.

17.2.3. As factories were built and industries grew, many industrial leaders became very wealthy. Andrew Carnegie, the founder of the U.S. Steel Corporation, became very rich. Carnegie used the **vertical organization** method to expand his corporation. By 1900 his company was producing one-fourth of the total world steel product. Another wealthy industrialist was John D. Rockefeller, the king of the oil industry. He was the leader of the Standard Oil Company. Like Carnegie, he used the vertical organizaton method to build up his industry. The Standard Oil Company grossed over two million dollars by selling oil in 1900. The same vertical growth was found in the food industry. The expanding cattle industry helped the **meat packing** industry to grow. Chicago and Kansas City became important **meat-packing** centers.

17.2.4. These industries continued to grow and their leaders continued to become wealthier because they formed the **trusts** to protect their businesses. Industrialists like Carnergie and Rockefeller bought up all the small companies which could not compete with their bigger ones. Buying up the small companies allowed the industries to create **monopolies**. A monopoly meant that a product was controlled by just one company or group. Standard Oil Company was one of these monopolies. It controlled the prices of oil and became so powerful that it could make demands in the U.S. Congress.

17.2.5. All of these industries needed large work forces to grow. But leaders took advantage of workers and did not treat them fairly. Workers worked long hours in poor conditions for little pay. In an effort to improve their situation, workers organized **unions**. The unions helped the workers to get better working conditions, shorter working hours, and better pay. From 1866 to 1890 there were three famous unions -- the National Labor Union (NLU), the Knights of Labor, and the American Federation of Labor (AFL). All of these unions helped the workers and their families improve their lives.

17.3. THE RESPONSE TO UNIONIZATION

17.3.1. When the unions were organized, the leaders of the industries wanted to stop them. They used **lockouts**, the **blacklist**, and **yellow-dog contracts** (see glossary) to break up the unions. These methods angered union workers so much that they often fought with factory guards or policemen. This violence, which caused so much bloodshed and so many deaths, attracted the attention of the government. In 1913 Congress set up the Department of Labor, which passed many laws to help the workers and to protect children who worked in factories.

17.3.2. The federal government also passed laws to protect the **consumer**. In 1887 the Interstate Commerce Commission Act was adopted. The Commission stopped all unfair railroad practices. The U.S. Congress passed the Meat Inspection Act and Pure Food and Drug Act. These two acts controlled the quality and the purity of the food and drugs that were produced by the factories.

EXERCISES

I. Word search:

Direction: Find and circle the words in the word search puzzle below. The words will be found vertically, horizontally, and diagonally. When you find a word, write it down and then define it.

I N D U S T R I A L I Z A T I O N

R B X G O L D R U S H P M T V R A

R O X H U X X X M X R A O E E G B

I N L O N G D R I V E C N R R A C

G A X S I O X X N M M K O M T N D

A N P T O L X X I E R I P I I I E

T Z O T N D X X N A A N O N C Z F

I A R O T A T E G T F G L A A E G

O X C W O R L D W I D E Y L L X H

N X X N U T R I T I O N O S X X J

GOLDRUSH
GHOSTTOWN
LONG DRIVE
NUTRITION
MINING
WORLDWIDE
TERMINALS
IRRIGATION
VERTICAL
Industrialization

ROTATE
GOLD
FARMER
UNION
CROP
MONOPOLY
PACKING
MEAT
ORGANIZE

II. MATCHING: Match each word in column A with the explanation or definition in column B. Write the number of each answer in the space provided.

A	B
a. gold rush	1. the founder of the Standard Oil Company.
b. long drive	2. an agreement between employer and employee in which the worker states that he will not join the union.
c. bonanza farmers	3. the founder of the U.S. Steel Company.

____ d. lockout

____ e. blacklist

____ f. yellow dog contract

____ g. Andrew Carnegie

____ h. John D. Rockefeller

4. the most successful farmer on the frontier.

5. the large movement of the miners into California, Colorado, and Arizona to get rich.

6. a term used to refer to the moving of herds from Texas to the railroad terminals in the North.

7. the refusal of an employer to give jobs to workers.

8. a list of known union members which is used by anti-union businessmen.

III. Map Work

Color the map below and put the name of the South, New England, the Great Plains, and the Dakotas.



IV. True or False

_____ 1. Mining, farming, and cattle raising were in New England.

_____ 2. The Gold Rush was in the Appalachian Mountains.

_____ 3. A bonanza farmer is one who works with the long drive.

_____ 4. Wheat was the most profitable crop in the Dakotas.

_____ 5. Barbed wire helped to protect the land.

_____ 6. Birmingham is a steel city in Alabama.

_____ 7. There were 4 transcontinental lines which across the country at the end of the 19th century.

_____ 8. The workers organized unions to protect the employers.

_____ 9. The employers used the blacklist, the lockout, and the yellow-dog contract to help the workers.

ការសាន

១៧-១ របៀបជឿនលឿនថ្មីរបស់សេដ្ឋកិច្ច

១៧-១-១ ក្នុងចន្លោះឆ្នាំ ១៨៧៥ និងឆ្នាំ ១៩០០ ជារយៈពេលដែលឧស្សាហកម្មបានរីកចំរើនយ៉ាងខ្លាំង ។ ផ្នែកខាង New England និង រដ្ឋទាំងប៉ុន្មាននៃផ្នែកខាងជើង ដែលជាផ្នែកល្អលើសគេខាងឧស្សាហកម្មស្រាប់មកហើយ ក៏ចេះតែទាក់ទាញអ្នកជំនួញ និងរោងចក្រថ្មីៗបន្ថែមទៀតជាច្រើន ។ ថែមពីលើនេះនៅតាមភូមិភាគសំខាន់ៗ ដែលនៅដាច់ឆ្ងាយនៃផ្នែកខាងត្បូង និង ខាងលិច ឧស្សាហកម្មក៏បានចាប់ផ្តើមរីកចំរើនបន្តិចម្តងៗដែរ ។

១៧-១-២ ការជីករកអណ្តូងរ៉ែ ការចិញ្ចឹមសត្វ និង កសិកម្ម ដែលជារបរយ៉ាងសំខាន់នៅផ្នែកខាងលិចអស់ជិតរយៈពេលមួយរយឆ្នាំ ក៏បានចាប់រីកចំរើនយ៉ាងខ្លាំងឡើង ។ ដោយសារការរត់រកជីកមាសនៅ California នៅឆ្នាំ ១៨៤៩ កម្មកររណ្តៅរ៉ែជាច្រើននាក់ក៏បានរើកន្លែងមកនៅផ្នែកខាងលិចដែរ ។ ពួកអ្នកមានៗ ក៏បានបង្កើតជាក្រុមហ៊ុនអណ្តូងរ៉ែ ដោយបានទិញគ្រឿងសម្ភារៈ ជួលកម្មករ ជាពិសេសបានរៀបចំអោយមានភូមិតូចៗជាច្រើនផង ។ នៅពេលដែលក្រុមហ៊ុនអណ្តូងរ៉ែ ព្រមទាំងកម្មករភាគច្រើនបានរើកន្លែងទៅនៅផ្នែកខាងលិច ពួកអ្នកជំនួញក៏រើទៅតាមដែរ ។ ផ្លូវថ្នល់ និង រទេះភ្លើងជាច្រើន ក៏បានលេចឡើងនៅផ្នែកនោះ ដើម្បីសំរាប់ប្រើក្នុងការដឹកនាំរបស់របរគ្រឿងសម្ភារៈ និង វត្ថុធាតុដើម ។

១៧-១-៣ ការចិញ្ចឹមគោ ជារបរដែលចាប់រីកចំរើនតាំងពីជំនាន់មានសង្គ្រាមក្នុងស្រុកម្ល៉េះ ព្រោះសាច់គោបានដឹកនាំពី Texas ទៅសំរាប់ចិញ្ចឹមកងទ័ពនៃផ្នែកខាងត្បូងនៅពេលនោះ ។ បន្ទាប់ពីសង្គ្រាមបានចប់មក ឧស្សាហកម្មខាងគោនេះ ក៏បានរិតតែបានរីកចំរើនឡើង ពីព្រោះអ្នកចិញ្ចឹមគោត្រូវចំណាយលុយយ៉ាងតិច ក្នុងការចិញ្ចឹមនៅ Texas ដែលលក់សាច់បានយ៉ាងថ្លៃនៅផ្នែកខាងជើង និង ខាងកើត ។ ដោយសារពេលនោះ ផ្លូវរទេះភ្លើងមានទៅដល់ត្រឹមតែ Omaha នៃរដ្ឋ Nebraska ដូច្នេះពួកអ្នកចិញ្ចឹមគោទាំងនោះត្រូវធ្វើដំណើរជាមួយហ្វូងគោខ្លួនពី Texas ឆ្ពោះទៅរកស្ថានីយរថភ្លើងនៅផ្នែកកណ្តាលនៃភាគខាងលិច ។ កិច្ចការនេះមានឈ្មោះថា ការធ្វើដំណើរយ៉ាងវែងឆ្ងាយ ។

១៧-១-៤ បន្ថែមពីលើការជីករកអណ្តូងរ៉ែ និង ចិញ្ចឹមគោ កសិកម្មក៏ជាឧស្សាហកម្មយ៉ាងសំខាន់ដែរនៅខាងផ្នែក Great Plains ។ ចាប់ដំបូងឡើងរបរកសិកម្មនៃផ្នែកខាងលិច មិនមែនជាកិច្ចការស្រួលដូចការចិញ្ចឹមគោឡើយ ពីព្រោះដីគ្មានជីជាតិ និង ស្ងួតពេក ។ ដល់ពេលក្រោយមក ពួកកសិករទាំងនោះបានរិះរកឃើញនូវមធ្យោបាយថ្មីៗ ដូចជាគ្រឿងម៉ាស៊ីន តាមរបៀបវិទ្យាសាស្ត្រ ទំនប់ទឹក និង ការដាំដំណាំបង្វិលផ្លាស់គ្នា ។

ពួកអ្នកស្រែមួយភាគខ្លះ ជាពិសេស អ្នកដែលដាំស្រូវសាលី នៅភាគខាងត្បូង និង ខាងជើងនៃរដ្ឋ Dakota បានមានជោគជ័យនឹងដំណាំនេះយ៉ាងខ្លាំង ព្រមទាំងបានក្លាយទៅជាមហាសេដ្ឋីគ្រប់ៗគ្នា ។ ពួកនេះមានឈ្មោះថា អ្នកបះលើកខ្លួនល្អ "Bonanza farmers" ៕

១៧-១-៥ នៅពេលដែលឧស្សាហកម្មខាងអណ្តូងរ៉ែ ចិញ្ចឹមគោ និង កសិកម្មបានរីកចំរើនយ៉ាងខ្លាំងនៅផ្នែកខាងលិច ឧស្សាហកម្មខាងវាយនភណ្ឌ ដែកថែប និង ប្រេងកាត ក៏បានចាប់ដុះដាលឡើងដែរនៅផ្នែកខាងត្បូង ។ នៅមុនពេលដែលមានសង្គ្រាមក្នុងស្រុក ផ្នែកខាងត្បូងជាផ្នែកដែលសម្បូរណ៍ទៅដោយស្រែចំការ ហើយមុខរបររបស់ពួកកសិករអស់នោះច្រើនតែខាងដំណាំ ថ្នាំជក់ ស្រូវ កប្បាស និង ធ្លូះ ។ ផ្នែកខាងត្បូងមិនមានការផ្លាស់ប្តូរខាងឧស្សាហកម្មខ្លាំង ដូចផ្នែកខាងជើងឡើយ ។ ដោយសារហេតុនេះផ្នែកខាងត្បូងបានត្រូវខូចខាតខ្ទិចខ្ទីសឹងតែទាំងអស់ ក្នុងពេលដែលមានសង្គ្រាមក្នុងស្រុក ផ្នែកខាងនោះក៏ចាប់ផ្តើមមានការផ្លាស់ប្តូររបស់ខ្លួនដែរ ចាប់ពីឆ្នាំ ១៨៧០ ទៅដល់ឆ្នាំ ១៩០០ ។ ផ្នែកខាងត្បូងសម្បូរណ៍ខាងវត្ថុធាតុដើម ដូចជាធ្យូងថ្ម ដែក និង រ៉ែ ដែលក្រោយមកគេចាប់ចេះបង្កើតហើយមានជាផលិតផលឡើង ។ ពួកកម្មករភាគច្រើន ដែលធ្វើការនៅក្នុងរោងចក្រថ្មីៗ ដូចជារោងចក្រវាយនភណ្ឌ ដែកថែប និង ប្រេងកាត គឺច្រើនតែពួកស្បែកសក្រៗ និង ពួកស្បែកខ្មៅដែលទើបតែបានទទួលសេរីភាពថ្មីៗ ។ ពេលនោះ Birmingham នៃរដ្ឋ Alabama ក៏បានក្លាយទៅជា ក្រុងធំទីពីរខាងដែកថែបនៅក្នុងសហរដ្ឋអាមេរិក ។

១៣-២ របៀបរៀបចំខាងអង្គការឧស្សាហកម្ម និង ការងារ

១៧-២-១ បន្ទាប់ពីមានសង្គ្រាមក្នុងស្រុក ឧស្សាហកម្មអាមេរិកាំង បានត្រូវរីកដុះដាលយ៉ាងខ្លាំង ។ នៅឆ្នាំ ១៨៥៩ លុយដែលចំណេញពីឧស្សាហកម្មនោះ មានចំនួន ២ លានដុល្លារ លុះដល់ឆ្នាំ ១៩០០ លុយចំណូលមានចំនួនទៅដល់ ១៣០០០ លានដុល្លារ ។ ផលិតផលនៃរោងចក្រទាំងប៉ុន្មានក្នុងសហរដ្ឋអាមេរិក មានចំនួនច្រើនជាងផលិតផលនៃស្រុកឯទៀតៗក្នុងពិភពលោក ។

១៧-២-២ ឧស្សាហកម្មរបស់អាមេរិកាំង ដែលបានជឿនលឿនលូតលាស់ខ្លាំង គឺដោយសារស្រុកសម្បូរណ៍ទៅដោយវត្ថុធាតុដើម មនុស្សធ្វើការមានចំនួនច្រើន និង ពន្ធអាករថ្លៃ ។ គេត្រូវការវិធីដឹកនាំគ្រឿងសម្ភារៈថ្មីៗ និង របស់របរឯទៀតៗ ទៅរោងចក្រ និង ចេញមកវិញអោយបានយ៉ាងលឿន ហេតុដូច្នេះហើយបានជាផ្លូវរទេះភ្លើងបានដុះដាលឡើងយ៉ាងឆាប់រហ័ស ។ ក្រុមហ៊ុនរថភ្លើងបួនបានធ្វើដំណើរឆ្លងកាត់ប្រទេសពីចុងម្ខាងទៅចុងម្ខាង ដោយសារដីដែលរដ្ឋាភិបាលបានប្រគល់អោយគេ សំរាប់សង់ផ្លូវរទេះភ្លើង ។ នៅពេលនោះ គេត្រូវការដែកថែបយ៉ាងខ្លាំង ក្នុងការធ្វើផ្លូវរទេះភ្លើងនេះ ។

១៧-២-៣ នៅពេលដែលរោងចក្រថ្មីៗចាប់សង់ឡើង ដោយសារការរីកចំរើនខាងឧស្សាហកម្មនេះ មេពាណិជ្ជកម្មធំៗ ក៏បានក្លាយទៅជាមហាសេដ្ឋីមានៗ ដូចជាលោកAndrew Carnegie

ដែលជាអ្នករកឃើញ និង បង្កើតនូវក្រុមហ៊ុនដែកថែប នៃសហរដ្ឋអាមេរិក ។ លោក Carnegie នេះបានប្រើរបៀប vertical organization (វិធានការណ៍សំរាប់កាន់កាប់កិច្ចការដោយខ្លួនឯង) ដើម្បីសំរាប់ពង្រីកពង្រឹងក្រុមហ៊ុនរបស់ខ្លួនថែមទៀត ។ ដល់ឆ្នាំ ១៩០០ ផលិតផលដែលចេញពីក្រុមហ៊ុនលោក មានចំនួន ១ ភាគ ៤ នៃផលិតផលដែកថែបទាំងអស់នៅក្នុងពិភពលោក ។ ឧស្សាហករដ៏មានម្នាក់ទៀត គឺលោក John D.Rockefeller ដែលជាស្តេចខាងឧស្សាហកម្មប្រេងកាត ។ លោកជាមេដឹកនាំខាងក្រុមហ៊ុន Standard Oil Company ។ ដូចជាលោក Carnegie ដែរ លោក Rockefeller បានប្រើរបៀប vertical organization នេះដើម្បីសំរាប់ពង្រីកក្រុមហ៊ុនរបស់គេ ។ ក្រុមហ៊ុន Standard Oil Company បានចំណេញជាង ២ លានដុល្លារពីការលក់ប្រេងនៅឆ្នាំ ១៩០០ ។ បន្ទាប់មកឧស្សាហកម្មខាងម្ហូបអាហារ ក៏បានចាប់ប្រើរបៀប vertical នេះដែរ ។ ការពង្រីកខាងរបបចិញ្ចឹមគោ ក៏បានធ្វើអោយឧស្សាហកម្មខាងខ្ចប់សាច់ដាក់ប្រអប់ បានរីកចំរើនថែមទៀត ។ Chicago និង Kansas City ជាកន្លែងសំខាន់សំរាប់រោងចក្រខ្ចប់សាច់ដាក់ប្រអប់ ។

១៧ - ២ - ៤ ឧស្សាហកម្មទាំងអស់នោះ ក៏ចេះតែរីកដុះដាលឡើង ហើយមេដឹកនាំរបស់គេ ក៏រិតតែមានបានថែមទៀត ដោយសារគេបានរួមគ្នាបង្កើតអោយមានជា trust (សូមមើលអត្ថន័យខាងមុខ) - សំរាប់ការពារមុខជំនួញរបស់គេ ។ ឧស្សាហករដូចជាលោក Carnegie និងលោក Rockefeller បានទិញចូលនូវពួកជំនួញតូចតាច ដែលមិនអាចប្រកួតនឹងក្រុមហ៊ុនធំៗបាន ។ ការទិញនូវជំនួញតូចតាចនេះហើយ ដែលអាចអោយពួកគេបង្កើតជាការផ្តាច់មុខបាន ។ ការផ្តាច់មុខនេះ បានន័យថា ពួកក្រុមហ៊ុន ឬ ក្រុមហ៊ុនណាមួយអាចធ្វើការកាន់កាប់ត្រួតត្រាទៅលើផលិតផលអ្វីដែលសំខាន់ៗ ឧទាហរណ៍ ក្រុមហ៊ុន Standard Oil Co. ជាក្រុមហ៊ុនមួយ ដែលបង្កើតអោយមានការផ្តាច់មុខនេះ ។ គេបានកាន់កាប់តម្លៃប្រេងដោយខ្លួនឯង ពេលក្រោយមកបានក្លាយទៅជាក្រុមហ៊ុន ដែលមានអំណាចយ៉ាងខ្លាំង ហើយដែលគេអាចធ្វើការទាមទារនៅក្នុងរដ្ឋសភាបានផង ។

១៧ - ២ - ៥ ឧស្សាហកម្មទាំងប៉ុន្មាននោះត្រូវការកម្មករយ៉ាងច្រើន ដើម្បីសំរាប់ធ្វើការ និងអាចធ្វើអោយបានលុយណាស់ថែមទៀតផង ប៉ុន្តែពួកម្ចាស់ហាង បានខ្សៀតយកប្រយោជន៍ពីអ្នកធ្វើការ ដោយមិនបានយកចិត្តទុកដាក់នឹងពួកនោះឡើយ ។ ពួកកម្មករត្រូវប្រកបការងារអស់ម៉ោងពេលយ៉ាងយូរ នៅក្នុងភាពយ៉ាងលំបាកវេទនា ព្រមទាំងបានទទួលកំរៃយ៉ាងតិចផង ។ ក្នុងការខិតខំដើម្បីធ្វើអោយមានភាពធូរស្រាល អ្នកធ្វើការទាំងនោះ ក៏ចាប់បង្កើតជាសហជីពនៃកម្មករឡើង ។ សហជីពនេះបានជួយធ្វើអោយមានភាពធូរស្រួលក្នុងការងារ បញ្ចុះម៉ោងពេលសំរាប់ធ្វើការ និង អោយបានប្រាក់កំរៃច្រើនផង ។ ចាប់ពីឆ្នាំ ១៨៦៦ ទៅដល់ឆ្នាំ១៨៩០

គេឃើញមានសហជីពដ៏ល្បីៗបី គឺ : the National Labor Union(NLU),the Knights of Labor និង the American Federation of Labor(AFL) ។ ក្រុមសហជីពទាំងបីនេះ បានជួយធ្វើអោយពួកកម្មករ និងគ្រួសាររបស់គេ មានជីវភាពធូរស្រាលឡើងវិញ ។

១៧-៣ ការតបទៅនឹងក្រុមសហជីព

១៧-៣-១ នៅពេលដែលក្រុមសហជីពបានកើតឡើង ពួកមេដឹកនាំខាងឧស្សាហកម្មទាំងនោះចង់បំបាត់ក្រុមនេះចោល ដោយបានប្រើមធ្យោបាយ Lockouts,blacklist និង yellow dogs contract (- សូមមើលអត្ថន័យ) ។ មធ្យោបាយទាំងអស់នេះ បានធ្វើអោយកម្មករនៃពួកសហជីពនឹងលំបាកយ៉ាងខ្លាំង ដែលបណ្តាលអោយមានការប្រយុទ្ធគ្នាជាមួយនឹងអ្នកយាមរោងចក្រ និង ពួកប៉ូលិសផង ។ អំពើឃោរឃៅនេះ បានបង្កើតអោយមានការបង្ហូរឈាម និង ស្លាប់បាត់បង់ជីវិតអស់ជាច្រើននាក់ ដែលធ្វើអោយរដ្ឋាភិបាល មានការចាប់អារម្មណ៍យ៉ាងខ្លាំង ។ នៅឆ្នាំ ១៩១៣ រដ្ឋសភា ក៏បានបើកអោយមានក្រសួងការងារ ក្នុងការមើលការខុសត្រូវ និង បង្កើតច្បាប់ជាច្រើនទៀតសំរាប់ជួយដល់ពួកកម្មករ និងការពារដល់ក្មេងៗ ដែលធ្វើការក្នុងរោងចក្រផង ។

១៧-៣-២ រដ្ឋាភិបាលរួម ថែមទាំងបានបង្កើតច្បាប់សំរាប់ការពារដល់អ្នកប្រើប្រាស់របស់របរទៀត ។ នៅឆ្នាំ ១៨៨៧ គណៈកម្មការនៃការធ្វើជំនួញរវាងរដ្ឋ (ICC) បានបង្កើតឡើង ។ គណៈកម្មការនេះបានបញ្ឈប់មិនអោយមានការល្មើសច្បាប់នៃក្រុមហ៊ុនរថភ្លើងទាំងឡាយក្នុងស្រុក ។ នៅពេលនោះរដ្ឋសភា ក៏បានបង្កើតច្បាប់សំរាប់ត្រួតពិនិត្យមើលសាច់ និង ច្បាប់សំរាប់ម្ហូបអាហារ និងឱសថថែមទៀត ។ ច្បាប់ទាំងពីរដែលបានបង្កើតឡើងនេះ គឺក្នុងគោលបំណងសំរាប់ត្រួតពិនិត្យមើលនូវគុណភាព និង ភាពបរិសុទ្ធនៃសាច់ម្ហូបអាហារ និង ឱសថទាំងប៉ុន្មាន ដែលបានបញ្ចេញពីរោងចក្រមក ។

ការហាត់ :

១. របៀបរកពាក្យ : សូមរក និង គូសរង្វង់មូលជុំវិញនូវពាក្យទាំង១៩ នៅក្នុងរបៀបរកពាក្យខាងក្រោម ។ ពាក្យទាំងអស់នេះអាចរកឃើញ តាមរបៀបបញ្ឈរ ផ្ដេក និង បញ្ឆៀង ។ ពេលដែលរកឃើញនូវពាក្យនិមួយៗ សូមសរសេរដាក់នៅលើក្រដាស់ ព្រមទាំងអោយអត្ថន័យនៃពាក្យនោះផង ។

I N D U S T R I A L I Z A T I O N

R B X G O L D R U S H P M T V R A

R O X H U X X X M X R A O E E G B

I N L O N G D R I V E C N R R A C

G A X S I O X X N M M K O M T N D

A N P T O L X X I E R I P I I I E

T Z O T N D X X N A A N O N C Z F

I A R O T A T E G T F G L A A E G

O X C W O R L D W I D E Y L L X H

N X X N U T R I T I O N O S X X J

GOLDRUSH
GHOSTTOWN
LONG DRIVE
NUTRITION
MINING
WORLDWIDE
TERMINALS
IRRIGATION
VERTICAL
INDUSTRIALIZATION

ROTATE
GOLD
FARMER
UNION
CROP
MONOPOLY
PACKING
MEAT
ORGANIZE

២- របៀបប្រៀបផ្ទឹម : សូមប្រៀបផ្ទឹមពាក្យទាំងប៉ុន្មាន ដែលនៅខាងឆ្វេងក្រោមបន្ទាត់អក្សរ A ទៅនឹងអត្ថន័យ ឬ សេចក្តីពន្យល់ ដែលនៅខាងស្តាំ ក្រោមបន្ទាត់អក្សរ B ។ សូមសរសេរជាលេខនៅពីខាងមុខសំនួរនិមួយៗ ។

A	B
______ ក- gold rush	១- ជាអ្នករកឃើញ និង បង្កើតក្រុមហ៊ុន Standard Oil Company
	២- ជាសេចក្តីព្រមព្រៀងរវាងម្ចាស់រោងចក្រនិងកម្មករ ដែលបានចែងថា កម្មករនោះនឹងមិនចូលរួមជាមួយសហជីពទេ ។
______ - long drive	៣- ជាអ្នកបង្កើតក្រុមហ៊ុនដែកថែបនៃសហរដ្ឋអាមេរិក ។
______ - bonanza farmers	៤- ជាអ្នកស្រែចំការដែលរកស៊ីមានបាននៅតាមដំបន់ថ្មីៗ
______ - lockout	
______ - black list	៥- ជាចលនាយ៉ាងសន្ធឹកសន្ធាប់នៃពួកអណ្តូងរ៉ែឆ្ពោះទៅ California និង Colorado ដើម្បីចង់មានបាន។
______ - yellow dog contract	៦- ជាពាក្យសំរាប់ប្រើក្នុងការធ្វើដំណើរជាមួយហ្វូងគោឆ្ពោះទៅរកស្ថានីយរថភ្លើងដែលផ្ទុកទាំងដឹង
______ - Andrew Carnegie	
______ - John D.Rockefeller	៨- ជាការបដិសេធរបស់ម្ចាស់ហាងដោយមិនអោយការងារដល់ពួកកម្មករធ្វើ
	៩- ជាបញ្ជីឈ្មោះនៃពួកសមាជិកសហជីពសំរាប់ប្រើដោយម្ចាស់ហាងដែលបានជំទាស់ប្រឆាំងនឹងក្រុមសហជីព

៣. ការហាត់ទៅលើផែនទី : សូមផាត់ពណ៌ទៅលើផែនទីខាងក្រោម ព្រមទាំងដាក់ឈ្មោះ ខ្លួនរដ្ឋកទាងត្រៀង New England, Great Plains និង Dakotas ទាំងពីរភាគផង ។



៤. ពិត ឬ មិនពិត : សូមដាក់អក្សរ T ពីខាងមុខសំនួរណា ដែលយល់ថា ពិតត្រឹមត្រូវ និង អក្សរ F ពីមុខឃ្លាណា ដែលយល់ថា មិនពិត ។

________ ១. ការជីករកអណ្ដូងរ៉ែ ស្រែចំការ និង ចិញ្ចឹមសត្វ ជារបរដែលមាននៅផ្នែក New England ។

________ ២. ជួរភ្នំ Appalachians ជាកន្លែងដែលមនុស្សផ្លើសទៅរកដីកមាល ។

________ ៣. ភូមិដែលគេបានបោះបង់ចោល គឺជាភូមិដែលមានហាងជាច្រើន ហើយដែលកម្មករអណ្ដូងរ៉ែរស់នៅជាមួយគ្នា ។

________ ៤. ពួកអ្នកស្រែចំការដែលមានជោគជ័យរកស៊ីមានបាន គឺជាពួកដែលធ្វើដំណើរជាមួយហ្វូងគោ ឆ្ពោះទៅរកស្ថានីយរថភ្លើង ។

________ ៥. ស្រូវសាលីជាដំណាំ ដែលអោយកំរៃយ៉ាងខ្លាំង នៅខាងផ្នែក Dakotas ។

________ ៦. គេបានប្រើខ្សែលួសបន្លាសំរាប់ការពារគោទឹកដី ។

________ ៧. Birmingham ជាទីក្រុងខាងដែកថែបនៃរដ្ឋ Alabama ។

________ ៨. នៅចុងសតវត្សទី ១៩ ក្នុងសហរដ្ឋអាមេរិក មានក្រុមហ៊ុនរថភ្លើងបួនដែលធ្វើដំណើរឆ្លងកាត់ប្រទេសពីចុងម្ខាងទៅចុងម្ខាង ។

________ ៩. ពួកកម្មករបានបង្កើតអោយមានជាក្រុមសហជីព ដើម្បីសំរាប់ការពារដល់ពួកម្ចាស់ហាង ។

________ ១០. ពួកម្ចាស់ហាងបានប្រើរបៀប the black list,the lock out និង the yellow dog contract ដើម្បីសំរាប់ការពារដល់ពួកកម្មករ ។

Section V: THE TRANSFORMATION OF A NATION

Packet 18: THE EMERGENCE OF MODERN AMERICA

ពាក្យថ្មីៗ

competition: ការប្រកួតប្រជែង

There was increasing competition between the Republican and Democratic parties.

alliance: សម្ព័ន្ធភាព

The Republican Party was an alliance of industrialists from the Northeast and wealthy farmers from the Mid-West.

industrialist: អ្នកធ្វើជំនួញ ពាណិជ្ជករ

integrity: សេចក្តីសុចរិត

Republicans were concerned about the integrity of the Union.

exploit: ជញ្ជក់ផលប្រយោជន៍ពីអ្នកដទៃ

Poor factory workers and immigrants were often exploited by the rich.

spoils system: វិធានការលើសរាប់អ្នកចេញភ្នាក់ងាររដ្ឋការមិនមែនបក្សខ្លួន

The spoils system appeared during Grant's administration.

inefficient: ដែលគ្មានសមត្ថភាព

The spoils system caused both inefficient and irresponsible government.

irresponsible: ប្រព្រឹត្តមិនគិតមុខគិតក្រោយ

merit system: ធ្វើការជ្រើសរើសរកមន្ត្រីធ្វើការ ដោយពឹងផ្អែកទៅលើគុណសម្បត្តិ

The merit system said a civil servant should selected because of his ability, regardless of his political views.

regardless: ដោយពុំគិតអំពី គ្មានគិតដល់

The journalist and scholars became reformers and worked to replace the spoils system with a merit system.

scholar: អ្នកមានចំណេះជ្រៅជ្រះ

reformer: អ្នកកែប្រែ កែទម្រង់

monetary standard: មូលដ្ឋាននៃរូបិយវត្ថុ

The major issue of the 1890's was the battle over the monetary standard.

unemployment: ការគ្មានការធ្វើ

High tariff would help ease unemployment.

manipulate: របៀបនិយាយប្រើដឹកនាំមនុស្សយ៉ាងប៉ិនប្រសប់

Rich bankers used their money and power to manipulate Congressmen.

banker: ធនាគារិក

currency circulation: ប្រាក់កាសសំរាប់ចាយវាយនៅក្នុងស្រុក

Workers favored great currency circulation.

debtor: អ្នកជំពាក់លុយគេ

Debtors wanted cheap money to pay their debts.

gold standard: មាសជាមូលដ្ឋាន

Industrialists and businessmen favored the gold standard.

world power: មហាអំណាចក្នុងពិភពលោក

By 1900 the U.S. had become a world power.

target: ទីដៅ

The Hawaiin Islands became a target of the U.S. Navy in order to open a seaway.

seaway: ផ្លូវសមុទ្រ

the open door policy: នយោបាយបើកទ្វារចំហ

Expansionist favored an open door policy for trade with China.

expansionist: អ្នកដែលពង្រីកពង្រឹងខាងវប្បធម៌ នយោបាយ ឬ ផ្លូវយោធាទៅខាងប្រទេសក្រៅ អោយបានទូលំទូលាយ

READING

18.1. THE PERIOD OF POLITICAL COMPETITION AND CORRUPTION

18.1.1. Between the Civil War and 1900, the United States of America changed from an agricultural into an industrial nation. As the economy grew and prospered, competition increased between the two major political parties: the Republican Party and the Democratic Party.

18.1.2. The Republican Party was basically an alliance between two groups: the industrialists in the Northeast and the wealthy farmers in the Midwest. Because the Republicans were concerned about the integrity of the Union and the freedom of the slaves, they had the support of many Northerners and the freedmen in the South.

18.1.3. Like the Republican Party, the Democratic Party was an alliance of two diverse groups: the wealthy Southerners who were against the abolition of slavery and the poor factory workers and immigrants who lived in the Northeast. The large number of workers received no benefits from the Republican Party which favored the wealthy industrialists, so they looked to the Democratic Party and organized labor unions for help.

18.1.4. After the Civil War, the Republicans controlled the U.S. Congress and the presidency while the Democrats controlled the governments of many states. Under President Grant's administration, corruption spread nationwide and a spoils system appeared. Many unqualified persons who had been faithful party supporters were placed in government jobs. This resulted in a government that was quickly becoming inefficient, irresponsible, and corrupt.

18.1.5. However, there were many honest Democrats and Republicans who opposed the spoils system and wanted to replace it with a merit system. In a merit system, officials selected for government jobs must be the best qualified people, regardless of their political views or party services. Of all the people who favored the merit system, the journalists and scholars were the most outspoken. They became the reformers and used newspapers and magazines to criticize the evils of the spoils system and to obtain support from honest people. They demanded action from Congress. In 1883, Congress passed the Pendleton Act. This act set up a Civil Service Commission which organized an examination to test the fitness of applicants for public service. Under this act only 14,000 of the 100,000 government workers were given civil service positions.

18.2. THE PROGRESSIVE MOVEMENTS

18.2.1. Besides working to eliminate the spoils system, these two parties also addressed many economic issues. The most important issues were the tariff, business regulation, and the monetary standard.

18.2.2. The Democrats and the Republicans took opposite stands on the tariff issue. Most of the active Democrats lived in the South and were farmers. They favored low tariffs which would enable them to buy cheaper goods and tools from foreign countries for their farms and plantations. The Republicans, many of whom were industrialists, wanted to levy high tariffs on imported goods. A high tariff was the most effective means to stop foreign goods from flooding the country, to ease **unemployment**, and to keep the economy growing.

18.2.3. Members of both parties were becoming increasingly concerned about the issue of business regulation. The Constitution had given Congress the power to regulate commerce among states. However, it was a very difficult task to regulate many of the interstate business activities. The railroad companies, for example,were owned and run by the strongest and wealthiest groups in the country. These powerful groups were able to **manipulate** Senators and, thereby, gain support in Congress. The small businessmen became worried that trusts and monopolies would never be eliminated. They urged the reformers in Congress to pass laws to regulate commerce between the states. In 1877, Congress responded by passing the Interstate Commerce Act (ICA). This act set up an Interstate Commerce Commission (ICC) to regulate business operations, services and rates of interstate carriers. In the beginning, the commission was not very powerful and people still felt that the government was not doing enough to stop the growth of trusts and monopolies. So, in 1890, Congress passed the Sherman Antitrust Act. Although the act was designed to stop the rise of monopolies, it was so unclear that it had little effect and the monopolies continued to grow.

18.2.4. Another issue in the 1890's was the battle over the monetary standard. Every group had its own idea of what the monetary standard should be. The industrialists, bankers, and businessmen favored the gold system. They wanted to limit currency circulation and thereby protect the prices of their products and the interests of their loans. The workers favored both gold and silver as the monetary standard. They demanded that the government increase the amount of currency circulation based on silver and gold. The farmers and the other debtors wanted "cheap money" with which to pay their debts. By cheap money, they meant paper money that was not backed by gold and silver. Industrialists, bankers and businessmen used their money and power to defeat the supporters of the poor farmers and debtors in Congress and in the 1896 presidential election, William McKinley, who was regarded as the leader of those groups who favored the gold standard, was elected President, and in 1897 gold was officially adopted as the standard of currency.

18.3. THE NATION BECOMES A WORLD POWER

18.3.1. As American industry continued to grow, the United States found that it needed foreign markets in which to sell its products. Both businessmen and military leaders supported territorial expansion by seeking new markets and looking for places to build new naval bases. America quickly began to gain new lands. In 1878, the U.S. built a naval base in Pago Pago, Samoa Islands. The British and German governments protested. They sent battle ships to the area, but Great Britain soon withdrew. The United States and Germany divided the islands between them.

18.3.2. The Hawaiian Islands were another **target** of the U.S. Navy Department and American businessmen. If the U.S. Navy controlled these islands, it could easily open a new **seaway** to China and the Far East. In addition, American businessmen had invested heavily in the sugar plantations in Hawaii during 1880's. In 1890, Queen LiLiuokalani became ruler of the islands. She wanted to decrease the power of Americans in the islands. To protect their interests, American residents planned a revolution. In 1898, the Hawaiian Islands were annexed to the U.S. after a successful revolution against the Queen was carried out by American residents with the support of the U.S. minister to Hawaii.

18.3.3. The next target was China. For years, China had been forced to sign treaties with European nations to give them trading rights in China. American businessmen also wanted to have a share of the Chinese market. The U.S. government proposed the "**open door policy**". This policy provided equal trading rights in China to all nations.

18.3.4. The American **expansionists** were worried about the presence of Spain in Cuba and in the Caribbean Islands. For many years, the Cubans had been fighting against Spain for their independence. President McKinley did not want to interfere in Cuban affairs but there were many Americans living in Havana at that time and, to protect their lives, the U.S. Government sent the battleship, Maine, to Havana. The ship was blown up in the harbor and 260 American sailors were killed. President McKinley was under heavy public pressure to act. He asked Congress to declare war on Spain and Congress agreed. The war between the U.S. and Spain did not take place only in the Caribbean Sea but also in the Philippine Islands. The war lasted only a few months. Spain lost the war and had to cede Puerto Rico, Guam Island, and the Philippine Islands to the United States. Cuba became an independent nation. By 1900 the United States had become a major world power. The growth of industry and the expansion of commerce had caused the nation, which had previously favored a policy of isolation and neutrality, to seek the acquisition of overseas land and territories as markets for its manufactured products.

EXERCISES

I. Word search puzzle:

Direction: Find and circle the words in the word puzzle below. The words will be found vertically, horizontally, and diagonally. When you find a word in the puzzle, write it and then define it.

COMPETITION
CORRUPT
EXPANSIONIST
RAILROAD
SEAWAY
WORLD POWER
MERIT SYSTEM
STANDARD

JOURNALIST
MONETARY
EXPLOIT
CONGRESS
OPEN DOOR
INTEGRITY
BANKER
FACTORY

FARMER
DEMOCRATS
REFORMER
EVIL
CURRENCY
SCHOLAR
GOLD
TARGET

C O M P E T I T I O N T A R G E T W

J D O S X M O T C F A R M E R O W O

O E N T P C O R R U P T O F C P O R

U M E A A C O N G R E S S O O E R L

R O T N N F A C T O R Y N R N N O D

N C A D S E X P L O I T I M G D W P

A R R A I R O A D E V I L E R O O O

L A Y R O L S E A W A Y U R E O R W

I T O D N C U R R E N C Y O S R T E

S S N B I N T E G R I T Y R S U H R

T E O M S C H O L A R T G O L D S A

M E R I T S Y S T E M B A N K E R T

II. Matching Match each word in column A with the explanation or definition in column B. Write the number of each answer in the space provided.

	A	B
_____	a. monopoly	1. a policy first suggested by U.S. in 1889 which declared that all nations should have equal trading rights in China.
_____	b. civil service	2. the practice of giving government jobs in return for political support.
_____	c. reformer	3. having to do with improvement, moving forward.
_____	d. immigrant	4. public jobs in federal, state, and local governments awarded on the basis of merit.
_____	e. open door policy	5. a person from one country who enters another country to become a permanent resident.
_____	f. spoils system	6. one who wants to improve conditions.
_____	g. progressive	7. control of an industry or the supply of an item by one group or company.

III. True or False

Read each statement. Put a T next to each statement if it is true. Put a F in that space if it is false.

____ 1. The two main U.S. political parties are the Republican Party and the Democratic Party.

____ 2. The Democratic Party was very strong in the South and in certain areas in the Northeast.

____ 3. Under President Grant's administration, corruption did not spread.

____ 4. The reformers were the people who favored the spoils system.

____ 5. The Democrats favored high tariffs to protect their farms and plantation products.

____ 6. There was a big fight between the U.S. Navy and the British Navy in the Samoa Islands.

____ 7. In 1890, Queen LiLiuokalani became an industrialist in Hawaii.

____ 8. The open door policy limits Chinese immigration to the U.S. each year.

____ 9. Cuba was annexed to the U.S. at a meeting between the U.S. Congress and the President of Cuba.

____ 10. Puerto Rico was colony of Japan during 1889.

IV. Fill in the blanks. Complete each statement by writing the correct word or group of words in the blanks: political life, economic life, integrity, spoils system, merit system, eliminate, manipulate, monopolies, currency circulation, cheap money, the open door policy.

1. There were many changes in the ________ as well as ________ of the nation.
2. The Republicans were concerned about the ________ of the Union and the freedom of the slaves.
3. Under President Grant's administration a corrupt system expanded nationwide and a ____________ appeared.
4. Many honest Democrats and Republicans opposed the spoils system and wanted to replace it with a __________ .
5. Besides working to __________ the spoils system, these two parties also had many economic plans.
6. These groups could ________________ Senators and get

support from Congress.

7. In 1890, Congress passed the Sherman Antitrust Act to stop the rise of __________ .

8. The industrialists and the bankers wanted to limit the __________ and protect the prices of their products.

9. The farmers and the other debtors wanted ____________ with which to pay their debts.

10. The U.S. government proposed ____________ to provide equal rights to all nations to trade with China.

ការអាន

១៨.១ រយៈពេលដែលមានការប្រណាំងប្រជែងគ្នាក្នុងនយោបាយ និង អំពើពុករលួយ

១៨.១.១ ក្នុងចន្លោះពេល ដែលមានសង្គ្រាមក្នុងស្រុកនឹងឆ្នាំ ១៩០០ សហរដ្ឋអាមេរិកបានផ្លាស់ប្តូរពីប្រទេស ដែលរីកចំរើនខាងកសិកម្ម ទៅជាប្រទេស ដែលលូតលាស់ខាងឧស្សាហកម្មវិញ ។ នៅពេលដែលសេដ្ឋកិច្ចបានរីកចំរើន ដុះដាលខ្លាំងឡើង ការប្រកួតប្រជែងគ្នារវាងគណៈបក្សធំៗពីរ គឺគណៈបក្សសាធារណៈរដ្ឋ និង គណៈបក្សប្រជាធិបតេយ្យ ក៏កាន់តែមានកំរិតខ្លាំងឡើងដែរ ។

១៨.១.២ គណៈបក្សសាធារណៈរដ្ឋ គឺជាបក្សដែលមានសមាជិកភាពរវាងក្រុមពីរ : គឺពួកពាណិជ្ជករនៃប៉ែកខាងជើងឈៀងខាងកើត និង ពួកអ្នកស្រែដ៏មានធុ នៅភាគកណ្ដាលនៃប៉ែកខាងលិច ។ ដោយសារពួកសាធារណៈរដ្ឋមានការកង្វល់ទៅលើភាពសុចរិតរបស់អង្គការ សហភាពរបស់កម្មករ និងសេរីភាពរបស់ពួកខ្ញុំគេ ក្រុមនេះក៏បានទទួលការគាំទ្រយ៉ាងច្រើនពីពួកផ្នែកខាងជើង និង ពីពួកដែលមានសេរីភាពនៅប៉ែកខាងត្បូង ។

១៨.១.៣ គណៈបក្សប្រជាធិបតេយ្យ ក៏ដូចជាគណៈបក្សសាធារណៈរដ្ឋដែរ ។ បក្សនេះមានសមាជិកភាពជាមួយក្រុមពីរផ្សេងគ្នា : គឺពួកអ្នកមាននៃផ្នែកខាងត្បូង ដែលបានប្រឆាំងនឹងការលុបបំបាត់មិនអោយមានពួកខ្ញុំគេ និង ពួកកម្មករក្រីក្រ ដែលធ្វើការនៅក្នុងរោងចក្រ ព្រមទាំងពួកអន្តោប្រវេសន៍ដែលរស់នៅផ្នែកខាងជើងឈៀងខាងកើតផង ។ កម្មករភាគច្រើនមិនដែលបានទទួលប្រយោជន៍ពីគណៈបក្សសាធារណៈរដ្ឋសោះឡើយ ពីព្រោះបក្សនេះមានការលំអៀងទៅលើពួកពាណិជ្ជករដែលមានធុ ដូច្នេះពេលនោះពួកកម្មករក៏បានបែរទៅរកជំនួយពីគណៈបក្សប្រជាធិបតេយ្យវិញ ។

១៨.១.៤ បន្ទាប់ពីសង្គ្រាមក្នុងស្រុកមក គណៈបក្សសាធារណៈរដ្ឋបានធ្វើការកាន់កាប់នៅក្នុងរដ្ឋសភា ព្រមទាំងខាងប្រធានាធិបតី ។ ចំណែកគណៈបក្សប្រជាធិបតេយ្យវិញបានកាន់កាប់ខាងរដ្ឋាភិបាលនៃរដ្ឋជាច្រើន ។ នៅក្រោមដំណែងលោកប្រធានាធិបតី Grant អំពើពុករលួយបានរីកដុះដាលនៅគ្រប់ទីកន្លែងក្នុងស្រុក ។ ពេលនោះរបៀប spoil system (សូមមើលអត្ថន័យនៅខាងមុខ) ក៏បានកើតមានឡើង ។ មនុស្សដែលគ្មានសមត្ថភាព ប៉ុន្តែជាអ្នកគាំទ្រ និង ស្មោះត្រង់ចំពោះគណៈបក្ស បានត្រូវគេដាក់អោយកាន់កាប់កិច្ចការក្នុងរដ្ឋាភិបាល ។ អំពើទាំងនេះហើយ ដែលបានធ្វើអោយរដ្ឋាភិបាលចុះអន់ថយយ៉ាងឆាប់ ព្រមទាំងគ្មានសមត្ថភាព ធ្វើការខ្ជះខ្ជាយ ជាពិសេសបានបង្កើតអោយមានអំពើពុករលួយផង ។

១៨-១-៥ ទោះជាយ៉ាងណាក៏ដោយ ក៏នៅតែមានសមាជិកដ៏ស្មោះត្រង់ជាច្រើន ទាំងខាងគណៈបក្សសាធារណៈរដ្ឋ ព្រមទាំងគណៈបក្សប្រជាធិបតេយ្យ បានងើបតវ៉ាប្រឆាំងចំពោះរបៀប spoil system នេះ ដោយសុំអោយយករបៀប merit system មកជំនួសវិញ ។ នៅក្នុងរបៀប merit system នេះភ្នាក់ងាររដ្ឋការនិមួយៗ ដែលត្រូវគេជ្រើសរើសអោយទទួលការងារកាន់កាប់កិច្ចការ គឺជាមនុស្សដែលមានសមត្ថភាពគ្រប់គ្រាន់ ដោយមិនគិតពីបក្សពួក ឬ ក្រុមនយោបាយណាមួយឡើយ ។ ក្នុងចំណោមមនុស្ស ដែលមានការលំអៀងទៅលើ merit system នេះ ពួកសារព័ត៌មាន និង ពួកដែលមានចំណេះវិជ្ជាជ្រៅជ្រះ ច្រើនតែជាអ្នកនិយាយអោយលំអៀងខ្លាំងជាងគេ ហើយដែលក្រោយមក ពួកនេះបានក្លាយទៅជាអ្នកកែប្រែស្រុកទេស ។ ពួកគេបានប្រើសារព័ត៌មាន និង ទស្សនាវដ្ដីសំរាប់ធ្វើការទិទៀន និង រិះគន់ចំពោះអំពើអាក្រក់នៃរបៀប spoil system ព្រមទាំងសំរាប់ទទួលសេចក្ដីគាំទ្រពីសំណាក់អ្នកដែលមានគំនិតត្រឹមត្រូវទៀងត្រង់ផង ។ គេបានសុំអោយរដ្ឋសភាធ្វើការសំរេចក្នុងរឿងនេះទៀត ។ នៅឆ្នាំ ១៨៨៣ រដ្ឋសភាក៏បានបង្កើតច្បាប់ឈ្មោះ Pendleton Act ឡើង ។ ច្បាប់នេះសំរាប់បង្កើតអោយមាននូវគណៈ កម្មការនៃរដ្ឋាភិបាល ដែលត្រូវធ្វើការត្រួតពិនិត្យជ្រើសរើស និង ធ្វើការសាកល្បងមើលនូវអ្នកដាក់ពាក្យសុំធ្វើការក្នុងរដ្ឋការ ។ ដោយសារច្បាប់នេះ គេជ្រើសរើសរកបានតែមនុស្សចំនួន ១៤០០០ នាក់ប៉ុណ្ណោះ ក្នុងចំណោមមនុស្ស ១០ ម៉ឺននាក់ ដែលធ្វើការក្នុងរដ្ឋការនៅពេលនោះ ។

១៨-២ ចលនាឆ្ពោះទៅរកវឌ្ឍនភាព

១៨-២-១ ក្រៅពីធ្វើការ ដើម្បីបំបាត់របៀប spoil system នេះ គណៈបក្សទាំងពីរបានប្រឈមតទល់នឹងបញ្ហាសេដ្ឋកិច្ចឯទៀតជាច្រើន ។ បញ្ហាដែលសំខាន់ជាងគេ គឺរឿងពន្ធអាករ បទបញ្ញាសំរាប់ធ្វើជំនួញអោយបានត្រឹមត្រូវ ហើយនឹងមូលដ្ឋាននៃរូបិយវត្ថុ ។

១៨-២-២ ក្នុងរឿងពន្ធអាករ គណៈបក្សប្រជាធិបតេយ្យ និង គណៈបក្សសាធារណៈរដ្ឋ មាននយោបាយខុសផ្សេងពីគ្នា ។ ពួកប្រជាធិបតេយ្យ ដែលមានសកម្មភាពជាងគេច្រើនតែជាពួកកសិករ ដែលរស់នៅផ្នែកខាងត្បូង ។ ពួកនេះមានការលំអៀងទៅច្បាប់អោយបង់ពន្ធអាករថោក ដើម្បីនឹងស្រួលអោយពួកគេទិញគ្រឿងសម្ភារៈ និង របស់របរឯទៀតពុំបានយ៉ាងថោកពីបរទេស សំរាប់ប្រកបមុខរបររបស់ខ្លួន ។ ចំណែកពួកសាធារណៈរដ្ឋវិញ ដែលមានភាគច្រើន សុទ្ធតែអ្នកធ្វើជំនួញ ចង់អោយរដ្ឋាភិបាលតំឡើងពន្ធយ៉ាងខ្ពស់ទៅលើគ្រឿងរបស់ ដែលដឹកនាំចូលប្រទេស ។ គេយល់ថា ពន្ធអាករខ្ពស់ ជាមធ្យោបាយដ៏មានប្រសិទ្ធិភាពសំ

រាប់បញ្ឈប់កុំអោយមានរបស់របរពីបរទេសហូរចូលមកប្រទេសទៀត ហើយដែលអាចធ្វើអោយបានធូរស្រាល ចំពោះបញ្ហាអត់ការធ្វើ ព្រមទាំងអាចអោយសេដ្ឋកិច្ចរីកចំរើនបាន ៨៦ ។

១៨.២.៣ សមាជិករបស់គណៈបក្សទាំងពីរ កាន់តែមានការកង្វល់ចំពោះរឿងបទបញ្ញាសំរាប់ធ្វើជំនួញ ។ រដ្ឋធម្មនុញ្ញបានបើកអំណាចអោយរដ្ឋសភាបង្កើតបទបញ្ញាសំរាប់ជំនួញរវាងរដ្ឋទាំងអស់ ។ ប៉ុន្តែនេះជារឿងពិបាក ក្នុងការត្រួតត្រាមើល និង ដាក់បទបញ្ញាដល់ចលនាពាណិជ្ជកម្ម ដែលឆ្លងកាត់ពីរដ្ឋមួយទៅរដ្ឋមួយ ។ ឧទាហរណ៍ ក្រុមហ៊ុនរថភ្លើងទាំងប៉ុន្មានក្នុងស្រុក ជាក្រុមហ៊ុនរបស់ពួកមហាសេដ្ឋី ដែលមានឋាមពលខ្លាំងក្លា ។ ពួកទាំងនេះអាចដឹកនាំ និង ប្រើប្រាស់សភាបានយ៉ាងប៉ិនប្រសប់ ព្រមទាំងអាចបានទទួលការគាំទ្រពីរដ្ឋសភាផង ។ អ្នកជំនួញតូចៗ មានការព្រួយបារម្ភ និង ខ្លាចក្រែងគេមិនអាចបំបាត់ចោលបាននូវរបៀបកាន់កាប់ផ្តាច់មុខរបស់ក្រុមហ៊ុនពាណិជ្ជកម្មដល់ឧស្សាហកម្ម ឬ ផលិតផលចាំបាច់ណាមួយ ដែលគេអាចកំណត់តំលៃបាន ។ ដូច្នេះពួកគេបានសុំ ពួកអ្នកកែប្រែនៅក្នុងរដ្ឋសភាអោយបង្កើតជាច្បាប់សំរាប់ដាក់បទបញ្ញាដល់ជំនួញរវាងរដ្ឋទាំងអស់ ។ នៅឆ្នាំ ១៨៨៧ រដ្ឋសភាក៏បានបង្កើតអោយមានច្បាប់សំរាប់ជំនួញរវាងរដ្ឋនេះទៀងឈ្មោះ Interstate Commerce Commerce (ICA) ដោយបានចាត់តាំងអោយមានគណៈកម្មការនៃពាណិជ្ជកម្មរវាងរដ្ឋ Interstate Commerce Commission (ICC) សំរាប់ធ្វើការដាក់បទបញ្ញាដល់មុខជំនួញទូទៅ ព្រមទាំងមើលនូវរបៀបបំរើ និងតំលៃនៃការដឹកនាំរវាងរដ្ឋផង ។ ចាប់ផ្តើមឡើង គណៈកម្មការនេះ មិនសូវមានអំណាចអោយបានខ្លាំងក្លាទេឡើយ ប្រជាពលរដ្ឋក្នុងស្រុកយល់ថា រដ្ឋាភិបាលមិនបានធ្វើការអោយបានម៉ឺងម៉ាត់ក្នុងការបញ្ឈប់កុំអោយមានរបៀបកាន់កាប់ផ្តាច់មុខរបស់ក្រុមពាណិជ្ជកម្ម ។ ដូច្នេះនៅឆ្នាំ ១៨៩០ រដ្ឋសភាក៏បានបង្កើតច្បាប់មួយទៀតឈ្មោះ Sherman Antitrust Act ក្នុងគោលបំណងសំរាប់បំបាត់ចោលកុំអោយមានរបៀបកាន់កាប់ផ្តាច់មុខនេះទៀត ។ ក៏ប៉ុន្តែច្បាប់នេះមិនបានចែងអោយបានច្បាស់លាស់ទេ ៖ ដែលបានបណ្តាលអោយគ្មានអនុភាពអ្វីឡើយ។ ពេលនោះរបៀបកាន់កាប់ផ្តាច់មុខក៏ចេះតែរីកដុះដាលថែមទៀត ។

១៨.២.៤ នៅឆ្នាំ ១៨៩០ មានបញ្ហាមួយទៀត គឺការទាស់ទែងគ្នា ពីរឿងមូលដ្ឋាននៃរូបិយវត្ថុ ។ ក្រុមនីមួយៗ មានគំនិតផ្ទាល់ខ្លួនពីរឿងនេះ ។ ពួកឧស្សាហករ ធនាគារិក ព្រមទាំងពួកពាណិជ្ជករ បានយល់ព្រមថា ត្រូវយកមាសមកធ្វើជាមូលដ្ឋាន ។ ពួកគេចង់អោយរដ្ឋាភិបាលដាក់កំរិតនូវលុយកាក់សំរាប់ចាយវាយនៅក្នុងស្រុក ដែលសំរាប់ជាការការពារដល់តំលៃរបស់របរខ្លួន ព្រមទាំងតំលៃនៃការប្រាក់សំរាប់អោយខ្ពស់ផង ។ ពួកកម្មករបានសំរៀងទៅលើការយកមាសព្រមទាំងប្រាក់មកធ្វើជាមូលដ្ឋាន ។ ពួកគេបានតវ៉ាសុំអោយរដ្ឋាភិបាលបង្កើននូវចំនួនលុយសំរាប់ប្រើប្រាស់នៅក្នុងស្រុក ដោយយោងទៅលើមាស និង ប្រាក់ដែលមាន ។

ពួកកសិករ ព្រមទាំងអ្នក ដែលជំពាក់លុយគេ ចង់បានលុយដែលមានឈ្មោះហៅថា "លុយថោក" ទៅសងបំណុលគេ ។ "លុយថោក" បានន័យថា លុយដែលបោះពុម្ពចេញ ដោយមិនបាច់យកមាស ឬ ប្រាក់មកធ្វើជាមូលដ្ឋានទេឡើយ ។ ពួកឧស្សាហករ ពាណិជ្ជករ និង ធនាគារិក បានប្រឆាំងលុយ និង អំណាចរបស់គេ ដើម្បីនឹងធ្វើអោយបានឈ្នះទៅលើក្រុមខ្លះក្នុងរដ្ឋសភាដែលបានគាំទ្រដល់ពួកកសិករក្រីក្រ ព្រមទាំងពួកដែលជំពាក់លុយគេនោះ ។ នៅពេលបោះឆ្នោតជ្រើសប្រធានាធិបតីប្រចាំឆ្នាំ ១៨៩៦ លោក Willim Mckinkey ដែលគេចាត់ទុកជាមេដឹកនាំនៃក្រុម ដែលយល់ព្រមយកមាសមកធ្វើជាមូលដ្ឋាននោះ បានជាប់ឆ្នោតធ្វើជាប្រធានាធិបតី ហើយនៅឆ្នាំ ១៨៩៧ រដ្ឋាភិបាលរបស់លោក ក៏បានសំរេចជាផ្លូវការ គឺយកមាសមកធ្វើជាមូលដ្ឋាននៃរូបិយវត្ថុ ។

១៨-៣ ប្រទេសបានក្លាយទៅជាមហាអំណាចក្នុងពិភពលោក

១៨-៣-១ ដោយសារឧស្សាហកម្មការតែបានជឿនលឿនល្អពេកណាស់ សហរដ្ឋអាមេរិកយល់ឃើញថា គេចង់បានផ្សារនៅបរទេស ដើម្បីលក់ដូរផលិតផលរបស់ខ្លួនថែមទៀត ។ អ្នកជំនួញ ក៏ដូចជាមេកងទ័ពជើងទឹកដែរ គឺខំប្រឹងប្រែងរកផ្សារថ្មីៗ និង រកកន្លែងសំរាប់សង់មូលដ្ឋាននាវា ។ ពេលនោះសហរដ្ឋអាមេរិកក៏បានរកទឹកដីថ្មីៗបន្ថែមយ៉ាងរហ័ស ។ នៅឆ្នាំ ១៨៧៨ សហរដ្ឋអាមេរិកបានសង់មូលដ្ឋាននាវានៅ Pago Pago នៃកោះ Samoa ពេលនោះរដ្ឋាភិបាលអង់គ្លេស និង អាល្លឺម៉ង់បានធ្វើការតវ៉ាឡើង ថែមទាំងបានបញ្ជូននាវាចំបាំងទៅកន្លែងនោះផង ។ តែរយៈពេលយ៉ាងខ្លីក្រោយមក អង់គ្លេសក៏បានដកថយចេញវិញ ។ សហរដ្ឋអាមេរិក និង អាល្លឺម៉ង់ក៏បានចែកបាយទឹកដីគ្នាសំរាប់កាន់កាប់នៅលើកោះនោះទៅ ។

១៨-៣-២ កោះទាំងប៉ុន្មានរបស់ Hawaii ក៏បានក្លាយទៅជាគោលដៅមួយទៀតរបស់កងនាវាចរ ព្រមទាំងពួកពាណិជ្ជករនៃសហរដ្ឋអាមេរិក ។ បើសិនជាគេបានកាន់កាប់កោះទាំងនោះ គេនឹងអាចបង្កើតអោយមានជាផ្លូវសមុទ្រឆ្ពោះទៅកាន់ស្រុកចិន និង អាស៊ីភាគខាងកើតបានយ៉ាងស្រួល ។ បន្ថែមពីលើនេះ កាលរយៈឆ្នាំ ១៨៨០នោះ ពួកជំនួញអាមេរិកាំងជាច្រើន បានចំណាយលុយជាច្រើនក្នុងរបរដំណាំស្ករនៅលើកោះ Hawaii ទៀត ។ នៅឆ្នាំ ១៨៩០ ស្តេចស្រីឈ្មោះ Liliuokalani ក៏បានឡើងកាន់កាប់ត្រួតត្រានៅកោះ Hawaii ។ ស្តេចនេះចង់បន្ថយអំណាចពួកអាមេរិកាំងទាំងអស់នៅលើកោះ ។ ដើម្បីនឹងចង់ការពារផលប្រយោជន៍របស់ខ្លួន ជនជាតិអាមេរិកាំងទាំងនោះ ក៏បានចាត់គំរោងការសំរាប់ធ្វើបដិវត្តន៍ ។ នៅឆ្នាំ ១៨៩៤ កោះ Hawaii ក៏ត្រូវបានសហរដ្ឋអាមេរិកដាក់បញ្ចូលជាឧបសម្ព័ន្ធរបស់ខ្លួន បន្ទាប់ពីការបដិវត្តន៍របស់ពួកអាមេរិកាំងមានជោគជ័យ ដោយមានជំនួយពីមន្ត្រីអាមេរិកាំងនៅលើកោះនោះផង ។

១៨.៣.៣ គោលដៅបន្ទាប់មក គឺស្រុកចិន ។ អស់រយៈជាច្រើនឆ្នាំ ស្រុកចិនត្រូវប្រទេសអឺរ៉ុបបង្ខំអោយចុះសន្ធិសញ្ញាជាមួយគេ ដើម្បីអោយប្រទេសទាំងនោះមានច្បាប់ធ្វើជំនួញជាមួយ ។ ពួកជំនួញអាមេរិកាំងក៏ចង់បានចំណែកពីស្រុកចិននោះដែរ ដូច្នេះរដ្ឋាភិបាលសហរដ្ឋអាមេរិក ក៏បានស្នើសុំអោយមាន " នយោបាយបើកទ្វារចំហ " ។ នយោបាយនេះអាចផ្តល់សិទ្ធិស្មើគ្នាដល់ប្រទេសទូទៅ ដែលចង់ធ្វើជំនួញជាមួយស្រុកចិន ។

១៨.៣.៤ ពួកអ្នកពង្រីក និង ពង្រឹងនិយមអាមេរិកាំង មានការខ្វល់ខ្វាយយ៉ាងខ្លាំងចំពោះវត្តមាននៃពួកអេស្ប៉ាញ (Spain) នៅក្នុងស្រុក Cuba ព្រមទាំងកោះទាំងឡាយនៅ Caribbean ផង ។ អស់រយៈពេលជាច្រើនឆ្នាំមកហើយ ដែលប្រជារាស្ត្រ Cuba បានវាយតយុទ្ធជាមួយនឹងអេស្ប៉ាញ ដើម្បីនឹងចង់ដណ្តើមយកឯករាជ្យរបស់ខ្លួនមកវិញ ។ នៅពេលនោះ លោកប្រធានាធិបតី Mckinley មិនចង់ជ្រៀតជ្រែកលូកដៃចូលក្នុងរឿង Cuba នោះទេ ប៉ុន្តែដោយសារមានពលរដ្ឋអាមេរិកាំងជាច្រើនបានរស់នៅក្នុងស្រុក Cuba ហើយដើម្បីនឹងចង់ការពារជីវិតពួកទាំងនោះ លោកក៏បានបញ្ជូននាវាចំបាំងឈ្មោះ Maine ទៅ Havana ។ នាវាចំបាំងនេះបានត្រូវគេលួចបំផ្លាញផ្ទុះខ្ទេចខ្ទីអស់នៅកន្លែងដែកចាល់ ព្រមទាំងមានបាត់បង់ជីវិតពលទាហានជើងទឹកអាមេរិកាំងអស់ចំនួន ២៦០ នាក់ផង ។ លោក Mckinley ត្រូវមានការបង្ខិតបង្ខំខាងផ្លូវចិត្តយ៉ាងខ្លាំងពីមតិសាធារណៈ ដើម្បីចង់អោយលោកចាត់វិធានការអ្វី ។ លោកក៏បានសុំអោយរដ្ឋសភាបើកប្រកាសសង្គ្រាមជាមួយអេស្ប៉ាញ ហើយដែលរដ្ឋសភាសុខចិត្តតាម ។ សង្គ្រាមរវាងសហរដ្ឋអាមេរិក និង អេស្ប៉ាញមិនមែនមានតែនៅឈូងសមុទ្រ Caribbean នោះទេ គឺមាននៅលើកោះPhillpine ថែមទៀត ។ សង្គ្រាមនេះមានរយៈពេលតែប៉ុន្មានខែប៉ុណ្ណោះ អេស្ប៉ាញបានត្រូវចាញ់សង្គ្រាម ព្រមទាំងបានប្រគល់ Puerto Rico កោះGuam និង Phillipine មកអោយសហរដ្ឋអាមេរិកផង ។ បន្ទាប់ពីនោះ Cuba ក៏មានឯករាជ្យទៀងវិញ ។ ដល់ឆ្នាំ ១៩០០ សហរដ្ឋអាមេរិកបានក្លាយទៅជាមហាអំណាចធំក្នុងពិភពលោក ។ ការរីកចំរើនខាងឧស្សាហកម្ម និង ការពង្រីកខាងជំនួញ បានធ្វើអោយប្រទេសនេះ ដែលពីមុនមានការសំអៀងទៅលើនយោបាយដាច់ឆ្ងាយពីគេ និង អព្យាក្រិតភាព ងាកទិសរក ទីកដី និង តំបន់ថ្មីនៅតាមបរទេស ដើម្បីធ្វើជាផ្សារសំរាប់លក់ដូរផលិតផលរបស់ខ្លួន ។

លំហាត់

១- របៀបរកពាក្យ

សេចក្តីណែនាំ : ស្វែងរក និង គូសរង្វង់មូលជុំវិញតួពាក្យទាំង ២៤ នៅក្នុងរបៀបរកពាក្យខាងក្រោម ។ ពាក្យទាំងអស់នេះ អាចរកឃើញតាមរបៀបបញ្ឈរ ផ្តេក និង បញ្ឆៀង ។ ពេលដែលរកឃើញតួពាក្យនិមួយៗ សូមសរសេរដាក់នៅលើក្រដាស ព្រមទាំងរកអត្ថន័យនៃពាក្យទាំងនោះផង ។

COMPETITION
CORRUPT
EXPANSIONIST
RAILROAD
SEAWAY
WORLD POWER
MERIT SYSTEM
STANDARD

JOURNALIST
MONETARY
EXPLOIT
CONGRESS
OPEN DOOR
INTEGRITY
BANKER
FACTORY

FARMER
DEMOCRATS
REFORMER
EVIL
CURRENCY
SCHOLAR
GOLD
TARGET

C	O	M	P	E	T	I	T	I	O	N	T	A	R	G	E	T	W
J	D	O	S	X	M	O	T	C	F	A	R	M	E	R	O	W	O
O	E	N	T	P	C	O	R	R	U	P	T	O	F	C	P	O	R
U	M	E	A	A	C	O	N	G	R	E	S	S	O	O	E	R	L
R	O	T	N	N	F	A	C	T	O	R	Y	N	R	N	N	O	D
N	C	A	D	S	E	X	P	L	O	I	T	I	M	G	D	W	P
A	R	R	A	I	R	O	A	D	E	V	I	L	E	R	O	O	O
L	A	Y	R	O	L	S	E	A	W	A	Y	U	R	E	O	R	W
I	T	O	D	N	C	U	R	R	E	N	C	Y	O	S	R	T	E
S	S	N	B	I	N	T	E	G	R	I	T	Y	R	S	U	H	R
T	E	O	M	S	C	H	O	L	A	R	T	G	O	L	D	S	A
M	E	R	I	T	S	Y	S	T	E	M	B	A	N	K	E	R	T

២. របៀបប្រៀបផ្ទឹម : សូមធ្វើការប្រៀបផ្ទឹមនូវពាក្យនិមួយៗ ដែលនៅក្រោមបន្ទាត់អក្សរ A ទៅនឹងអត្ថន័យ ឬ ក៏សេចក្តីពន្យល់ ដែលនៅក្រោមបន្ទាត់អក្សរ B សូមសរសេរជាលេខនៅពីមុខសំនួរនិមួយៗ ។

________	ក. ការផ្តាច់មុខ	១. ជាច្បាប់លើកដំបូងដែលសហរដ្ឋអាមេរិក បានផ្តើមអោយយោបល់ក្នុងឆ្នាំ ១៨៨៩ ដោយបានប្រកាសថាប្រទេសទាំងអស់ត្រូវ មានច្បាប់ស្មើរក្នុងការធ្វើជំនួញជាមួយ ស្រុកចិន ។
________	ខ. អ្នករដ្ឋការ	២. ការអនុវត្តនឹងដោយអោយការងារក្នុងរដ្ឋាភិបាល ដល់មនុស្សណាមួយ ដើម្បីនឹងបានទទួលនូវការគាំទ្រខាងនយោបាយពីអ្នកនោះវិញ ។
________	គ. អ្នកកែប្រែ	៣. ការអ្វីដែលទាក់ទងទៅនឹងការជឿនលឿន នឹងដើរទៅមុខ ។
________	ឃ. អន្តោប្រវេសន៍	៤. ជាការងារនៅក្នុងរដ្ឋ ឬ រដ្ឋាភិបាលក្នុងស្រុក ដែលបានប្រគល់អោយអ្នកដែលមានសមត្ថភាព ។
________	ង. នយោបាយបើកទ្វារចំហរ	៥. ជាមនុស្សផ្សេងពីប្រទេសណាមួយដែលបានចូលទៅរស់នៅប្រទេសមួយទៀត ។
________	ច.	៦. ការដែលធ្វើអោយបានរីកចំរើនដើរទៅមុខ ។
________	ឆ. វឌ្ឍនភាព	៧. ការកាន់កាប់ទាំងឧស្សាហកម្ម ឬ ផលិតផលណាមួយដោយពួកមួយក្រុម ឬ ដោយក្រុមហ៊ុន

៣. ពិត ឬ មិនពិត

សូមមើលនូវឃ្លានិមួយៗ ដោយដាក់អក្សរ T នៅពីមុខ បើសិនជាយល់ថាឃ្លានោះត្រូវ ហើយនឹងដាក់អក្សរ F បើសិនជាឃ្លានោះខុស ។

______ ១. គណៈបក្សសំខាន់ពីរនៃសហរដ្ឋអាមេរិក គឺ បក្សសាធារណៈ និង បក្សប្រជាធិបតេយ្យ ។

______ ២. បក្សប្រជាធិបតេយ្យ ជាបក្សដែលមានជំហរយ៉ាងរឹងប៉ឹងនៅផ្នែកខាងត្បូង និង ភាគខ្លះនៃផ្នែកខាងជើងឆៀងខាងកើត ។

______ ៣. នៅក្រោមរដ្ឋាភិបាលរបស់លោក Grant របៀបគ្រប់គ្រងក្នុងស្រុកមានភាពដ៏ល្អប្រសើរគ្រប់ទីកន្លែង ។

______ ៤. ក្រុមអ្នកកែប្រែ គឺជាក្រុមដែលចូលចិត្តនឹងលំអៀងទៅលើរបៀប spoils system

______ ៥. ពួកប្រជាធិបតេយ្យ បានយល់ស្របចំពោះការបង់ពន្ធអាករយ៉ាងថ្លៃ ដើម្បីនឹងចង់ការពារនូវផលិតផលនៃស្រែចំការរបស់ខ្លួន ។

______ ៦. នៅកោះ Samoa មានការប្រយុទ្ធគ្នាយ៉ាងខ្លាំងរវាងកងនាវាចរនៃសហរដ្ឋអាមេរិកជាមួយកងនាវានៃស្រុកអង់គ្លេស ។

______ ៧. នៅឆ្នាំ ១៨៩០ នៅកោះ Hawaii ស្តេចស្រីឈ្មោះ Liliuokalani បានក្លាយខ្លួនទៅជាអ្នកពាណិជ្ជករ ។

______ ៨. នយោបាយបើកទ្វារចំហ គឺសំរាប់ធ្វើការកំណត់នូវប្រជាជនចិនដែលបានចូលមកសហរដ្ឋអាមេរិករាល់ឆ្នាំ ។

______ ៩. សហរដ្ឋអាមេរិកបានយកកោះ Cuba បញ្ចូលជាឧបសម្ព័ន្ធដោយគ្រាន់តែមានការប្រជុំគ្នារវាងរដ្ឋសភានៃសហរដ្ឋអាមេរិក និង ប្រធានាធិបតីនៃស្រុក Cuba

______ ១០. Puerto Rico ជាស្រុកដែលនៅក្រោមអាណានិគមរបស់ជប៉ុនក្នុងជំនាន់ឆ្នាំ ១៨៨៩ ។

៤. ការបំពេញកន្លែងទំនេររបស់ឃ្លា

សូមបំពេញឃ្លានិមួយៗ ដោយសរសេរដាក់នូវពាក្យ និង ក្រុមនៃពាក្យខ្លះអោយបានត្រឹមត្រូវនៅកន្លែងទំនេរ ។ ពាក្យទាំងនោះមាន : ព្រឹត្តិការណ៍នយោបាយ - ព្រឹត្តិការណ៍សេដ្ឋកិច្ច - សេចក្តីសុចរិត - និយាយប្រើដឹកនាំមនុស្សយ៉ាងប៉ិនប្រសប់រកមនុស្សអោយធ្វើការដោយផ្អែកទៅលើគុណសម្បត្តិ (merit system) ដាក់មនុស្សដែលគ្មានសមត្ថភាពអោយកាន់កិច្ចការ ដើម្បីនឹងបានការគាំទ្រពីអ្នកនោះ :

ចំពោះគណៈបក្សនយោបាយរបស់ខ្លួន(spoil system) បំបាត់ចេញ - ការផ្ដាច់មុខ - ប្រាក់កាសសំរាប់ចាយវាយក្នុងស្រុក - លុយថោក - នយោបាយបើកទ្វារចំហ ។

១- មានការរីកប្រែជាច្រើននូវ ____________ និង ________________ ________________ នៅក្នុងស្រុក ។

២- ពួកសាធារណៈមានកង្វល់ចំពោះ ____________ ដែលពួកសហភាពព្រមទាំងសេរីភាពដែលពួកខ្ញុំគេផង ។

៣- នៅក្រោមរដ្ឋាភិបាលរបស់លោក _____ អំពើពុករលួយបានរីកដាលពេញក្នុងស្រុក ពេលនោះរបៀប ______________________ បានចាប់កើតឡើង ។

៤- ពួកអ្នកទៀងត្រង់នៃគណៈបក្សសាធារណរដ្ឋ ព្រមទាំងប្រជាធិបតេយ្យបានធ្វើការប្រឆាំងចំពោះរបៀប ______________ នេះហើយដែលបង្កអោយមាន ----- ---------------- ជំនួសវិញ ។

៥- ក្រៅពីធ្វើការ ដើម្បី ___________ នូវរបៀប ________________ នេះ គណៈបក្សទាំងពីរមានគំរោងការណ៍ជាច្រើនទៀតសំរាប់សេដ្ឋកិច្ច ។

៦- ពួកទាំងនោះអាច __________ នូវពួកព្រឹទ្ធសភា ដើម្បីនឹងបានទទួលការគាំទ្រពីរដ្ឋសភាផង ។

៧- ក្នុងឆ្នាំ ១៨៩០ រដ្ឋសភាបានបង្កើតជាច្បាប់ឈ្មោះ ____________________ ដើម្បីនឹងបញ្ឈប់កុំអោយមានដុះដាលទៀតនូវ ____________________ ។

៨- ពួកពាណិជ្ជករ ព្រមទាំងពួកធនាគារិកបង្កអោយមានការកំរិតដល់ __________ ដើម្បីនឹងបង្ការពារដល់តម្លៃនៃផលិតផលរបស់ខ្លួន ។

៩- ពួកអ្នកធ្វើស្រែចំការ ព្រមទាំងពួកដែលជំពាក់លុយគេចង់បាន ______________ ដើម្បីសំរាប់សងបំណុលគេ ។

១០- រដ្ឋាភិបាលនៃសហរដ្ឋអាមេរិកបានស្នើសុំអោយមាន ____________________ ដើម្បីនឹងអោយប្រទេសឯទៀតៗ មានច្បាប់នឹងធ្វើជំនួញជាមួយស្រុកចិន ។

Section V: THE TRANSFORMATION OF A NATION

Packet 19: A CHANGING SOCIAL ORDER

NEW WORDS ពាក្យថ្មី

rural: ជនបទដែលដាច់ឆ្ងាយ

In 1900, 60% of all Americans lived in rural areas.

urban: នៃទីក្រុង

Between 1860-1900, urban population increased six times.

industrialization: ឧស្សាហូបនីយកម្ម

The growth of industrialization led to the growth of cities in the United States.

contrast: មានភាពផ្ទុយគ្នា ភាពខុសគ្នា

There was a contrast in the way of life for the rich people and the poor people in the cities.

mansion: វិមាន

Many rich people lived in big mansion.

slum: តំបន់ដែលមនុស្សក្រីក្ររស់នៅ

Poor immigrants lived in the slums.

resentment: ការតូចចិត្តនឹង មិនសប្បាយចិត្តនឹង

The poor people began to feel resentment against the rich,

sincere: ស្មោះ ស្មោះចំពោះ

Some politicians were sincere about wanting to improve city life.

electric-powered trolley: រថយន្តដឹកនាំមនុស្សដោយកំលាំងអគ្គិសនី

The electric-powered trolleys and elevated cars improved transportation in the cities.

elevated car: រថភ្លើងដឹកនាំមនុស្សនៅក្នុងទីក្រុង ដែលប្រើផ្លូវយ៉ាងខ្ពស់ផុត
ពីលើផ្លូវធម្មតា

waste-disposal system: របៀបកំចាត់ចោលសំរាម

Another improvement in the city life is a waste-disposal system.

settlement house: កន្លែងសំរាប់តាំងទីលំនៅ

Settlement houses provided social and recreational activities to residents in poor sections of the city.

coolie: គូលី

The Chinese unskilled workers who helped build the railroads were called coolies.

sweatshop: កន្លែងជំនាញ ឬ រោងចក្រ ដែលកម្មករត្រូវធ្វើការយ៉ាងលំបាកវេទនា
នឹងបានទទួលកំរៃយ៉ាងតិចតួច

Many immigrants worked in sweatshops doing handwork.

quota system: ជារបៀបសំរាប់ដាក់កំរិតចំនួនពួកបរទេសដែលចូលមករស់នៅក្នុងស្រុក
អាមេរិករាល់ឆ្នាំ

Aquota system was established to limit immigrants to the U.S.

reservation: ដីមួយផ្នែកដែលសំរាប់ទុកអោយពួកក្នងនៅ

Indians were forced to live on reservations.

literacy test: ការល្បង ឬ ប្រល្បងមើលខ្លួនការសរសេរនិងការនិយាយ

Southern States forced blacks to pass a literacy test to be able to vote.

advertisement: ការផ្សាយ ឃោសនា

Businessmen placed advertisements for their products in newspapers and magazines.

skyscraper: អាគារដ៏ខ្ពស់ៗ

As cities grow in size, skyscrapers and suspension bridges were built with newly created materials, like steel.

suspension bridge: ស្ពានស្រយ៉ុង

There are many suspension bridges in New York city.

READING

19.1. THE RISE OF THE CITY

19.1.1. After the Civil War, the growth of the cities was one of the most important developments in the United States. From 1860 to 1890, the urban population increased six times. In 1860 about 19% of the population lived in the cities; in 1900 about 40% Americans lived in the cities and towns. Three important developments contributed to the increase of the urban population and the growth of the cities: the increased number of new factories, the movement of rural people to the cities, and the large number of immigrants entering the United States.

19.1.2. During the Age of Industrialization, many new factories had been built in the cities. These factories provided many jobs and thousands of people came to the cities seeking work. Among those who came looking for jobs were many farmers. Life in the rural areas had become very difficult.

Farmers worked long hours for little pay. Others who came to find jobs were immigrants from the poor countries in Europe, Asia, and Latin America. They came to the cities hoping to find work and a better way of life.

19.1.3. As the cities grew in size and as the urban population increased, two new problems appeared. First, city life presented a **contrast** between the way of life for the rich and the poor. The rich lived in many beautiful **mansions** in one area while the poor workers and immigrants lived in **slums** or run-down buildings in another area. This contrast in the life style of the rich and the poor caused **resentment** and created new problems for urban dwellers.

19.1.4. Second, people new to the urban areas knew little about how to govern a city. An unorganized city could hardly cope with the problems caused by thousands of people moving into the area. In the 1870's, many cities were governed by corrupt and inefficient leaders. Many problems occurred and officials of the city government sat idle.

However, many Americans tried to solve these new problems. **Sincere** politicians, from both parties, fought against the corruption and disorganization. These leaders won the support of the people and were gradually elected to replace the inefficient city officials.

19.1.5. The new city leaders worked hard to provide services and to make the city livable. City transportation was improved by **electric-powered trolleys** and **elevated cars**. In the early 1890's, most city streets were lighted by electric lamps. There was also clean water to drink. A **waste-disposal system** was developed to keep the city clean. The police and fire departments grew in size and helped to prevent many crimes and fires in the big cities.

19.1.6. City reformers further attempted to fight crime by setting up centers called **settlement houses**. In these centers, people could find recreation facilities. A famous reformer named Jane Addams established a Settlement House in Chicago called the Hull House. The Hull House provided many social and cultural activities and served as a model for other settlements in the United States.

19.2. PATTERNS OF PREJUDICE AND DISCRIMINATION

19.2.1. Between 1877 and 1914, hundreds of thousands of immigrants came to this country seeking jobs, a better life, and a more promising future. Most of the immigrants who had arrived before the end of the 1870's had come from Western and Northern Europe. Their culture, languages, and customs related easily to American customs and these early immigrants were quickly assimilated. However, after the 1880's, most of the immigrants were coming from different areas such as Eastern, Southern, and Central Europe. These new immigrants brought cultures, religions, and social customs that were very different from those found in America. For this reason the newer immigrants experienced prejudice and discrimination in the new land.

19.2.2. Immigrants also came from other parts of the world. Thousands of Mexicans came to the U.S. to search for jobs and a better way of life. When we built the transcontinental railroads, thousands of Chinese --unskilled workers called "coolies" --were brought to the western coast states to work.

19.2.3. As well as experiencing prejudice and discrimination, immigrants faced many other problems. It was not easy for most immigrants to find jobs because they were unskilled workers. They were forced to work long hours for low wages in the **sweatshops** (the sweatshop was a small business where people did handwork. Many Americans blamed immigrants when too many people entered this country and cities became crowded. The American workers feared that the immigrants would take their jobs for lower wages. The businessmen claimed the immigrants caused violence; thus, they formed the American Protective Association. The association asked Congress to set up a **quota system** which would limit the number of immigrants allowed to enter the country each year. In 1882, the Chinese Exclusion Act was passed and this law stopped all Chinese immigration for ten years.

19.3. THE INDIANS AND THE BLACKS

19.3.1. Two other groups, the Indians and the Blacks, were also victims of prejudice and unfair treatment. After the Civil War, many Americans moved to the West. As they moved West they pushed the Indians out of their lands. The Indians wanted to stay on their lands, so they fought back for almost 30 years. In an effort to end the fighting, the government set aside land for them called **reservations** and forced the Indians to live on the reservations under military guard. Here, the Indians had to depend on the government and they gradually gave up their tribal way of life. Finally, in 1887, Congress passed the Dawes Act which began breaking up Indian reservations and tribes.

19.3.2. The black Americans were also treated as second class citizens. Although the blacks had been protected by the Thirteenth, Fourteenth, and Fifteenth Amendments, in reality, they were not regarded as equal to the whites. Several measures were adopted to prevent the blacks from voting. Some states, especially in the South, passed a Poll Tax Law where person had to pay a tax to vote. The poor and uneducated blacks had to pass a **literacy test**. The grandfather law stated that an individual could not vote unless his grandfather had voted prior to 1865. In 1865, most of the blacks had been slaves and only a few of them had the right to vote.

19.3.3. Among the black people, there were some famous leaders who fought for equal rights and equal opportunities for black citizens. One of the most famous leaders in the early times was Booker T. Washington. Washington tried to give blacks equal rights through educational opportunities. He founded Tuskegee College for blacks in Tuskegee, Alabama. In 1914, nearly 3,000 blacks earned college degrees and about one million black children were in schools.

19.4. THE CULTURE OF A DYNAMIC NATION

3. The ___________ in 1935 insured the future of the workers when they became old or unemployed.

4. The leaders of the business system set up their own policie such as _____________ , so that they could hire anyone they needed.

5. During 1920's, the influence of the ___________ decreased because of the prosperity of the industries.

6. In 1913 Congress set up the ________________ to regulate labor activities.

7. The Clayton Antitrust Act said that the government could not use an ____________ to break up the strikes.

8. Business leaders wanted to control the system; therefore they created the ___________ .

9. Female workers used to work in the tobacco, clothing, or ___________ .

10. Male workers handled all ____________ in the factories or on the farms.

ការងារ

២៨ - ១

២៨ - ១ - ១ ប្រភពមួយយ៉ាងសំខាន់របស់ឧស្សាហកម្មអាមេរិកាំង គឺកម្លាំងថាមពលនៃអ្នកធ្វើការ ។ នៅមុនឆ្នាំ ១៩០០ កម្មករភាគច្រើនដែលនៅក្នុងសហរដ្ឋអាមេរិក គឺច្រើនតែអ្នកជំនាញការល្មមៗ ឬ ក៏អ្នកដែលគ្មានជំនាញការអ្វីទាំងអស់ ។ ពួកទាំងនេះមិនបានទទួលការបង្ហាត់បង្រៀនពីសាលាខាងមុខវិជ្ជាជីវៈអ្វីឡើយ គឺគេរៀនចេះតែពីកន្លែងធ្វើការ ឬ ក៏ចេះពីការពិសោធន៍នៅក្នុងគ្រួសារតែម្តង ។ កងកម្លាំងនៃអ្នកធ្វើការចំនួន៨០ភាគរយ គឺសុទ្ធតែប្រុសៗ - ២០ ភាគរយជាស្រ្តី ឬ ក្មេងៗ ។ កម្មករប្រុសៗធ្វើការងារធ្ងន់ៗនៅក្នុងរោងចក្រ ឬ នៅស្រែចំការ ចំណែកឯពួកស្រីៗ និង ក្មេងវិញច្រើនតែធ្វើការនៅក្នុងរោងចក្រថ្នាំជក់ រោងចក្រធ្វើសម្លៀកបំពាក់ ឬ ក៏រោងចក្រវាយនភ័ណ្ឌ ។ ស្ថានភាពរបស់ពួកកម្មករអស់នេះ គឺមានភាពយ៉ាងវេទនាអស្ចារ្យ គេបានទទួលប្រាក់កម្រៃយ៉ាងតិចតួច ដោយត្រូវធ្វើការអស់ពេលយ៉ាងយូរម៉ោង ហើយជាពិសេសគ្មានការធានារ៉ាប់រង និង មិនដែលបានទទួលប្រយោជន៍បំណាច់អ្វីទាំងអស់ ។ ក្រុមសហភាពកម្មករ ដែលកើតឡើងដំបូង ត្រូវបានជួបប្រទះ និង ការទប់ទល់ប្រឆាំងយ៉ាងខ្លាំងពីម្ចាស់ហាង ឬ រោងចក្រ ហើយជាពិសេសក្រុមនេះច្រើនតែក្រុមតូចតាចដែលគ្មានប្រសិទ្ធិភាពអ្វីទាំងអស់ ក្នុងការជួយអោយមានភាពប្រសើរឡើងក្នុងការងារ និង ជួយរកប្រយោជន៍បំណាច់អោយដល់ពួកកម្មករនេះ ។

២៨ - ១ - ២ នៅពេលដែលឧស្សាហកម្មកាន់តែរីកដុះដាល និង ពង្រីកកាន់តែធំឡើង ពួកមេដឹកនាំខាងជំនួញអស់នោះ ចេះរកមធ្យោបាយ ដើម្បីនឹងធ្វើអោយខ្លួនកាន់តែមានថាមពលខ្លាំងឡើងថែមទៀត ដោយគេបង្កើតអោយមានជាការផ្តាច់មុខ និង ការកាន់កាប់មុខជំនួញ ឬ ផលិតផលណាមួយ ដែលគេអាចកំរិតតំលៃបាន ។ ពួកម្ចាស់ហាងជាអ្នកដាក់កំណត់កំរិតនៃប្រាក់កំរៃ និង ពេលម៉ោងធ្វើការអោយដល់ពួកកម្មករ ហើយពួកគេព្រមទាំងមានសមត្ថភាពនឹងបញ្ឈប់នូវឥទ្ធិពលនៃក្រុមសហភាពកម្មករពីដំបូងៗទៀតផង ដោយដេញចោលកម្មករណាដែលបះបោរប្រឆាំងនឹងគេ ។ ប៉ុន្តែដោយសារអំណាចកំលាំងនៃអ្នកកាន់កាប់កិច្ចការកាន់តែកើនច្រើនឡើង អង្គការការងារក៏រីកចំរើនកាន់តែខ្លាំងឡើងដែរ ។ ពួកកម្មករយល់ឃើញថា មានផ្លូវតែមួយគត់ដែលធ្វើអោយពួកគេអាចនឹងបានទទួលប្រាក់កំរៃច្រើនគួរសម និង ធ្វើអោយស្ថានភាពនៃការងាររបស់គេរឹងប្រសើរឡើង គឺដើបពួតដៃគ្នាប្រយុទ្ធនឹងពួកម្ចាស់ហាងទាំងនោះ ។

២៨ - ១ - ៣ ហេតុដូច្នេះហើយ បានជានៅចន្លោះឆ្នាំ ១៨៦០ និង ឆ្នាំ ១៩១៨ គេឃើញមានអង្គការការងារជាច្រើនដូចជា the National Labor Union, the Knights of Labor

និង the American Federation of Labor បានកើតមានឡើងនៅក្នុងសហរដ្ឋអាមេរិក ។ នៅពេលនោះ ក្រុមសហភាពកម្មករបានចាប់ផ្ដើមទទួលជោគជ័យខ្លះៗ ដោយសាររដ្ឋាភិបាលបានចាប់ភ្ញាក់ផ្អើល និងយកចិត្តទុកដាក់ទៅលើស្ថានភាពរបស់ពួកកម្មករទាំងនេះ ។ រដ្ឋសភាក៏ចាប់ផ្ដើមបង្កើតជាច្បាប់សំរាប់ជួយដល់អ្នកធ្វើការអោយមានស្ថានភាព និង ប្រយោជន៍បំណាច់ប្រសើរឡើង ។ នៅឆ្នាំ ១៩១៣ ក្រសួងការងារក៏បានបង្កើតឡើង ។ ដល់ឆ្នាំ ១៩១៤ ច្បាប់សំរាប់ប្រឆាំងនឹងរបបពាណិជ្ជកម្មផ្ដាច់មុខ (the Clayton Antitrust Act) ក៏បានបង្កើតឡើងទៀត ។ ច្បាប់នេះបានចែងថា រដ្ឋាភិបាល នឹងមិនប្រើអធិបញ្ញា ទៅសំរាប់បំបែកកូដកម្មបានឡើយ ។ នៅឆ្នាំ ១៩១៥ ច្បាប់មួយទៀតឈ្មោះ Folette Seaman's Act ក៏បានបង្កើតចេញបន្ថែម ដើម្បីសំរាប់ជួយដល់ពួកកម្មករនាវាជំនួញ អោយបានធ្វើការតិចពេលជាងពីមុន និងបានទទួលប្រយោជន៍បំណាច់ច្រើនលើសពីមុនផង ។ រដ្ឋាភិបាលព្រមទាំងខំប៉ុនប៉ងចង់ជួយដល់អ្នកធ្វើការក្មេងៗទៀត ដោយបានដាក់កំណត់អាយុសំរាប់អោយពួកនេះធ្វើការ ។ ទោះជាគេបានទទួលជោគជ័យទាំងប៉ុន្មានរួចមកហើយក៏ដោយ ក៏សេចក្ដីត្រូវការរបស់ពួកកម្មករនៅមិនទាន់បានពេញលេញនៅឡើយ ។ ពួកគេនៅតែចង់ទាមទារអោយតំលើងប្រាក់កំរៃ និង ចង់អោយស្ថានភាពនៃការងាររឹតតែបានប្រសើរជាងមុនទៅទៀត ហើយជាពិសេសគឺបង្កើនប្រយោជន៍បំណាច់សំរាប់ជាការទីពឹងទៅថ្ងៃមុខផង ។ ដូច្នេះពួកគេនៅតែបន្តការរៀបចំបង្កើតកូដកម្ម និង ទាមទារអោយរដ្ឋាភិបាលចាត់វិធានការណ៍ថែមទៀត ។

២៩-១-៤ កាលដំណាច់ឆ្នាំ ១៩២០ ឥទ្ធិពលរបស់អង្គការការងារត្រូវបានចុះអន់ថយដោយសារហេតុពីរយ៉ាង - ទីមួយគឺកាលដំណាច់នោះជាពេលដែលមានភាពរុងរឿងថ្កុំថ្កើង និង ការដុះដាលយ៉ាងខ្លាំងនៃឧស្សាហកម្ម ។ ពួកម្ចាស់ហាងបានបង្កើនថែមនូវប្រាក់កំរៃ និង ប្រយោជន៍បំណាច់អោយដល់ពួកកម្មករ ។ ទីពីរ គឺពួកម្ចាស់ហាងបានបង្កើតនូវច្បាប់ថ្មីៗ ដែលអាចធ្វើអោយគេជួលអ្នកធ្វើការ ដែលមិនមែនជាសមាជិករបស់សហភាពកម្មករ ។ ច្បាប់មួយក្នុងចំណោមច្បាប់ទាំងនោះមានឈ្មោះហៅថា ផ្សារបើកទ្វារចំហ (open shop) ច្បាប់នេះគឺបើកដៃអោយពួកម្ចាស់ហាងជួលនូវកម្មករធ្វើការទៅតាមសេចក្ដីត្រូវការ ដោយកម្មករនោះមិនចាំបាច់ចូលជាសមាជិកនៃសហភាពកម្មករមុនសិនឡើយ ។ វិធានការណ៍នេះបានធ្វើអោយសមាជិករបស់អង្គការសហភាពកម្មករចុះចំនួនជាខ្លាំង ។

២៩-២ ការដកថយពីសហភាពកម្មករ

២៩-២-១ កាលពីដំណាច់ឆ្នាំ ១៩៣០ ដែលជាពេលដែលមានវិបត្តិយ៉ាងធ្ងន់ធ្ងរខាងសេដ្ឋកិច្ចនោះ ឥទ្ធិពលរបស់អង្គការសហភាពការងារកាន់តែត្រូវចុះអន់ថយឡើង ។ អង្គការទាំងនោះមិនអាចជួយពួកកម្មករបានទៀតឡើយ ពីព្រោះ អ្នកដែលអត់ការធ្វើមានចំនួនច្រើនពេក ។ នៅពេលនោះ មានកម្មករចំនួនប្រហែល ៤ លាននាក់ ដែលត្រូវគេបញ្ឈប់

មិនអោយធ្វើការដោយទៀងទាត់ថ្ងៃ ។ ក្នុងពេលដែលលោកប្រធានាធិបតី Roosevelt បានឡើងកាន់កាប់អំណាច មានមនុស្សចំនួន ១៣ លាននាក់ ត្រូវដែលអត់ការធ្វើ ។ ពួកកម្មករដែលនៅសល់ទាំងប៉ុន្មាន ដែលគេចាត់ទុកថាមានសំណាង ហើយនៅមានកិច្ចការធ្វើនៅក្នុងរោងចក្រ ឬ ហាងជំនួញផ្សេងៗ រិតតែមានការភិតភ័យខ្លាំងថែមទៀតដោយខ្លាចអត់ការធ្វើ ។ ដូច្នេះពួកនេះមិនហ៊ានចូលរួមជាមួយអង្គការសហភាពទេ ព្រោះខ្លាចម្ចាស់ហាង ឬ ម្ចាស់រោងចក្រអាក់អន់ចិត្តនឹងគេ ។ ពេលនោះពួកកម្មករក៏បានបែរទៅរកជំនួយពីរដ្ឋាភិបាលម្តងវិញ ។

២៥.២.២ លោកប្រធានាធិបតី Roosevelt បានឆ្លើយតបទៅនឹងស្ថានការណ៍នេះ ដោយបង្កើតជាវិធីដោះស្រាយថ្មី ។ វិធានការណ៍ដែលលោកលើកឡើងថាមុខជានឹងជួយធ្វើអោយជំនួញ និង ឧស្សាហកម្មកើនឡើងវិញ ព្រមទាំងអាចផ្តល់ជាការងារដល់ប្រជារាស្ត្រ និងធ្វើអោយវិបត្តិសេដ្ឋកិច្ចមានភាពធូរស្រាលដូចដើមវិញផង ។ ក្នុងវិធីដោះស្រាយថ្មីលើកទីមួយ លោក Roosevelt បានជួយដល់ពួកកម្មករ តាមគ្រប់មធ្យោបាយទាំងអស់ ។ លោកមានជំនឿថា បើកាលណាកម្មករអាចរកការងារធ្វើបាន ពួកនោះនឹងមានប្រាក់ចំណូលសំរាប់ទិញនូវគ្រឿងផលិតផលទូទៅ ហើយដែលអាចធ្វើអោយពាណិជ្ជកម្មចាប់រើបរើឡើងវិញ ជាពិសេសធ្វើអោយវិបត្តិសេដ្ឋកិច្ចមានភាពធូរស្រាលបន្តិចម្តងៗ ។ រដ្ឋសភាបានដាក់សុំចូលបន្ថែមទៅលើកិច្ចការសាធារណៈ ដែលអាចបង្កើតជាការងារជាច្រើនសំរាប់ប្រជារាស្ត្រហើយថែមទាំងបានបង្កើតច្បាប់ឯទៀតសំរាប់ការពារដល់កម្មករទៀតផង ។ នៅឆ្នាំ ១៩៣៥ ច្បាប់ឈ្មោះ Wagner Act ដែលបានចែងថា the yellow dog contract និង black lists (- សូមមើលអត្ថន័យនៅ packet ទី ១៧)- ជាវិធីខុសច្បាប់ ។ ថែមពីលើនេះ ច្បាប់ Social Security Act នៃឆ្នាំ ១៩៣៥ ក៏រិតតែធ្វើអោយកម្មករមានការកក់ក្តៅអាចពឹងផ្អែកទៅលើ នៅពេលដែលគេអត់ការធ្វើ ឬ ក្នុងពេលចូលវ័យចាស់ជរា ។

២៥.៣ ការជឿនលឿនទៅមុខនៃអង្គការសហភាពនិយម

អង្គការសហភាព AFL និង CIO

២៥.៣.១ អង្គការឈ្មោះ the American Federation of Labor (AFL) បានចាប់បង្កើតឡើងនៅឆ្នាំ ១៨៨៦ ហើយសមាជិករបស់ក្រុមនេះភាគច្រើនគឺសុទ្ធតែមកពីខាងអង្គការសហភាពនៃអាជីវៈផ្សេងៗ ។ នៅឆ្នាំ ១៩៣៤ មានមនុស្សខ្លះចង់អោយដាក់អង្គការសហភាពខាងឧស្សាហកម្ម ជាផ្នែករបស់អង្គការ AFL ដែរ ។ លោក William Green ដែលជាមេប្រធានរបស់ AFL ជំនាន់ពេលនោះមិនយល់ស្របជាមួយគំនិតនេះទេ ហើយលោកព្រមទាំងបានរិះគន់ប្រឆាំងទៀតផង ។ ដូច្នេះហើយបានជាលោក John L.Lewis បានចាប់ផ្តើមបង្កើតអង្គការសំរាប់កម្មករនៃផ្នែកខាងឧស្សាហកម្មដោយខ្លួនឯង ដែលមានឈ្មោះថា the Committee for Industrial Organization (CIO) ។

អង្គការ CIO នេះជាអ្នកតំណាងពួកកម្មករ ដែលធ្វើការនៅក្នុងរោងចក្រធំៗ ឬ ក៏ខាងឧស្សាហកម្មធ្ងន់ៗ ដូចជា ផ្នែកខាងសង់កប៉ាល់ រោងចក្រឡាន និង រោងចក្រដែកថែបជាដើម ។ល។ ទស្សនៈវិជ្ជានៃពួកសហភាពនិយមនេះមានគំនិតខុសគ្នាយ៉ាងខ្លាំង ដែលបានធ្វើអោយអង្គការ AFL និង CIO មិនអាចធ្វើការរួមគ្នាបាន ។ ការបែងចែកនេះនៅតែមានរហូតមកដល់ឆ្នាំ ១៩៥៥ ហើយក្នុងពេលជាមួយគ្នានោះអង្គការទាំងពីរ ក៏ចេះតែដុះដាលខ្លាំងឡើងៗដែរ ។ លទ្ធផលដែលបានមក គឺការប្រណាំងប្រជែងគ្នារវាងក្រុមអង្គការទាំងពីរនេះ ដោយអង្គការនិមួយៗខិតខំទទួលយកចូលនូវកម្មករគ្រប់ប្រភេទ ។ ក្នុងអង្គការ AFL គឺមានសមាជិកខ្លះ ដែលមិនមែនជាអ្នកជំនាញការអ្វីទាំងអស់ និង សមាជិកខ្លះទៀត ជាអ្នកដែលមានជំនាញការខ្លះប៉ុណ្ណោះ ចំណែកខាងអង្គការ CIO វិញក៏ជាអ្នកតំណាងខាងសហភាពអាជីវៈខ្លះដែរ ។

២៩-៤ អង្គការសហភាពអាមេរិកាំងក្នុងពេលសព្វថ្ងៃនេះ

២៩-៤-១ នៅឆ្នាំ ១៩៥៥ អង្គការ AFL និង CIO បានចូលរួបរួមគ្នា ហើយដែលបានក្លាយទៅជាអង្គការការងារយ៉ាងធំបំផុតនៅក្នុងសហរដ្ឋអាមេរិក ។ សហភាពរួមគ្នានេះ បានទទួលយកនូវកម្មករគ្រប់ប្រភេទ ដែលរយៈពេលយ៉ាងខ្លីក្រោយមកសមាជិកបានកើនទៅដល់ចំនួន ២០ លាននាក់ ។ អង្គការ AFL-CIO នេះមានឥទ្ធិពលយ៉ាងខ្លាំង ក្នុងការជួយរកបំណាច់ប្រយោជន៍អោយដល់ពួកកម្មករ ព្រមទាំងបានជួយធ្វើអោយបមាណីយនៃជីវភាព (standard of living) បានប្រសើរឡើងផង ។

ការហាត់

៚៚៚

១- របៀបរកពាក្យ

សេចក្ដីណែនាំ ៖ សូមរក និង គូសរង្វង់ជុំវិញនូវពាក្យទាំង ៤៣ នៅក្នុងរបៀបរកពាក្យខាងក្រោម ។ ពាក្យទាំងនេះ អាចរកឃើញតាមរបៀប បញ្ឈរ ផ្ដេក និង បញ្ឆៀង - ពេលដែលរកឃើញនូវពាក្យនិមួយៗ សូមសរសេរដាក់នៅលើក្រដាស ព្រមទាំងអោយអត្ថន័យនៃពាក្យនោះផង ។

OPEN SHOP
FAMILY EXPERIENCE
MALE
VOCATIONAL SCHOOL
DEPARTMENT OF LABOR
LABOR UNION

AMERICAN FEDERATION

JOB
WAGE
AFL
JOIN
CIO
MORE
AUTO
FORCES

CRAFT
MONEY
LABOR
SALARY
MEMBER
OFFICE
SYSTEM
STRIKE
SPLIT

UNION
KNIGHT
BENEFIT
FACTORY
TEXTILE
TRUST
FARMER
MONOPOLY
UPSET

SAILORS
INFLUENCE
CONGRESS
TRAINING
INJUNCTION
SEMI SKILL
CRAFT UNION
OPEN SHOP
INSURANCE

A	M	E	R	I	C	A	N	F	E	D	E	R	A	T	I	O	N	O	F	L	N
M	O	N	E	Y	U	M	O	N	O	P	O	L	Y	B	I	C	H	L	O	A	O
S	A	I	L	O	R	S	A	F	L	C	O	N	G	R	E	S	S	O	R	B	I
V	O	C	A	T	I	O	N	A	L	S	C	H	O	O	L	O	A	N	C	O	N
I	P	C	O	N	O	S	E	M	I	S	K	I	L	L	A	U	T	O	E	R	U
N	E	F	O	R	C	E	S	I	T	T	R	A	I	N	I	N	G	X	N	U	R
S	N	S	T	R	I	K	E	L	S	J	O	M	F	A	R	M	E	R	I	I	O
U	S	U	P	S	E	T	O	Y	U	O	B	A	O	F	F	I	C	E	Z	C	B
R	H	M	E	M	B	E	R	E	R	B	A	L	A	B	O	U	E	C	A	T	A
A	O	C	R	A	F	T	E	X	T	I	L	E	C	A	N	A	C	T	T	O	L
N	P	P	O	H	S	N	E	P	O	S	L	W	A	G	E	E	N	H	I	R	A
C	V	S	S	O	S	P	L	I	T	A	I	K	C	I	O	L	L	N	S	S	N
E	E	A	Y	V	A	S	E	E	I	N	F	L	U	E	N	C	E	K	N	I	O
I	M	L	S	M	O	R	E	N	Z	Y	C	R	A	F	T	U	N	I	O	N	I
L	E	A	T	J	O	I	N	C	E	M	P	L	O	Y	E	R	I	A	L	L	T
O	N	R	E	X	B	E	N	E	F	I	T	I	N	J	U	N	C	T	I	O	A
R	T	Y	M	D	E	P	A	R	T	M	E	N	T	O	F	L	A	B	O	R	N

២. ពិត ឬ មិនពិត

សូមមើលឃ្លានិមួយៗ ដោយដាក់អក្សរ T នៅពីខាងមុខឃ្លា ដែលយល់ថាពិតត្រឹមត្រូវ និង អក្សរ F នៅមុខឃ្លាណាដែលយល់ថាមិនពិត ។

________ ១. ប្រភពមួយយ៉ាងសំខាន់របស់ឧស្សាហកម្មអាមេរិកាំង គឺកំលាំងថាមពលនៃអ្នកធ្វើការ ។

________ ២. នៅមុនឆ្នាំ ១៩០០ ពួកកម្មករបានត្រូវគេបង្ហាត់បង្រៀននៅក្នុងសាលាខាងមុខវិជ្ជាជីវៈ ។

________ ៣. កម្មករប្រុសៗ មានចំនួនដល់ទៅ ៨០ ភាគរយ ឯចំណែកកម្មករស្រីៗវិញ មានចំនួនប្រហែល ២០ ភាគរយប៉ុណ្ណោះ ។

________ ៤. កម្មករស្រីៗច្រើនតែធ្វើការនៅក្នុងរោងចក្រថ្នាំជក់ រោងចក្រតាងសំលៀកបំពាក់ និង រោងចក្រវាយនភ័ណ្ឌ ។

________ ៥. នៅមុនឆ្នាំ ១៩០០ ពួកកម្មករទាំងនេះមានការធានារ៉ាប់រង និងបំណាច់ប្រយោជន៍ទៀតជាច្រើនផង ។

________ ៦. ពួកមេដឹកនាំខាងដំនួញចង់ធ្វើការកាន់កាប់ទៅលើមុខរបរខ្លួនដោយបានបង្កើតជាការផ្តាច់មុខ និង របៀបគ្រប់គ្រងដែលគេអាចកំរិតថ្លៃបាន ។

________ ៧. នៅឆ្នាំ ១៩១៣ រដ្ឋសភា បានបង្កើតក្រសួងការងារឡើង ។

________ ៨. នៅឆ្នាំ ១៩១៥ ច្បាប់មួយឈ្មោះ Folette Seaman's Act ក៏បានកើតចេញឡើងទៀត សំរាប់ជួយដល់ពួកកម្មករនាវាដំនួញ អោយបានធ្វើការតិចម៉ោងជាងពីមុន និង បានទទួលបំណាច់ប្រយោជន៍ច្រើនថែមទៀត ។

________ ៩. ផ្សារបើកទ្វារចំហ (open shop) មិនអាចជួយពួកកម្មករបានទៅតាមសេចក្តីត្រូវការឡើយ ។

________ ១០. ក្នុងវិធីដោះស្រាយថ្មីលើកទីមួយ លោកប្រធានាធិបតី Roosevelt ចង់ជួយដល់ពួកកម្មករទៅតាមមធ្យោបាយទាំងអស់ ។

៣- របៀបប្រៀបផ្ទឹម

សូមប្រៀបផ្ទឹមពាក្យដែលនៅខាងឆ្វេងក្រោមបន្ទាត់អក្សរ A ទៅនឹងអត្ថន័យ ឬ សេចក្តីពន្យល់ ដែលនៅខាងស្តាំ ក្រោមបន្ទាត់អក្សរ B ដោយសរសេរដាក់ជាលេខនៅពីមុខសំនួរនិមួយៗផង ។

	A	B
______	១- កូដកម្ម	ក- ជាអង្គការសហភាពការងាររបស់កម្មករខាងជំនាញការដែលបង្កើតឡើងនៅឆ្នាំ ១៨៨៦
______	២- black list	ខ- ជាអង្គការកម្មករដែលបង្កើតឡើងក្នុងគោលបំណងនឹងចរចាជាមួយពួកម្ចាស់ហាងដើម្បីនឹងអោយមានប្រាក់កំរៃបំណាច់ប្រយោជន៍ និង ស្ថានភាពការងារកាន់តែប្រសើរឡើង
______	៣- AFL-CIO	គ- ការកាន់កាប់គ្រប់គ្រងទៅលើផលិតផល ឬ កិច្ចការដោយលះបង់ប្រណាំងប្រជែងខាងមុខជំនួញ
______	៤- ការផ្តាច់មុខ	ឃ- ការបដិសេធន៍មិនព្រមធ្វើការដែលចាត់ចែងឡើងដោយក្រុមសហភាពកម្មករ
______	៥- ការបែងចែក	ង- ជាអង្គការសហភាពយ៉ាងធំរបស់ឧស្សាហកម្មនិងអាជីវៈផ្សេងៗ ដែលបានកើតឡើងនៅឆ្នាំ ១៩៥៥
______	៦- សហភាពការងារ	ច- ជាបញ្ជាពីតុលាការ ដើម្បីអោយបញ្ឈប់កូដកម្ម
______	៧- the American Federation of Labor (AFL)	ឆ- ជាសាលាសំរាប់បង្ហាត់បង្ហាញខាងជំនាញការ
______	៨- អធិបញ្ជា	ជ- ការចែកចេញជាពីរផ្នែក
______	៩- សាលាវិជ្ជាជីវៈ	ឈ- ជាកិច្ចព្រមព្រៀងរវាងកម្មករនិងម្ចាស់ហាង ដែលពួកកម្មករសន្យាថា គេនឹងមិនចូលរួមជាមួយនឹងសហភាពកម្មករទេ

_______ ១០- yellow dog contract

ញ- ជាបញ្ជីឈ្មោះពួកសមាជិកអង្គការសហភាព ដែលសំរាប់យកមកប្រើដោយពួកម្ចាស់ហាងដែលប្រឆាំងនឹងអង្គការនេះ ដោយបដិសេធអ្នកដែលមានឈ្មោះមិនអោយចូលធ្វើការទេ

៤- ការបំពេញក្នុងកន្លែងទំនេរ

សូមបំពេញឃ្លានីមួយៗ ដោយដាក់បញ្ចូលនូវពាក្យ ឬ ក្រុមពាក្យដែលយល់ថាត្រឹមត្រូវសំរាប់ឃ្លានោះ ។ ពាក្យទាំងនោះមាន ៖ អង្គការការងារ - ក្រសួងការងារ - អធិបញ្ញា - កិច្ចការធ្លន់ពុ - រោងចក្រវាយនភណ្ឌ - ការផ្តាច់មុខ ឬ ការកាត់កាប់ទៅលើមុខជំនួញណាដែលគេកំរិតតម្លៃបាន - បណ្តាផ្សារបើកទ្វារចំហ - ច្បាប់ Social Security Act - អង្គការសហភាពទាំងអាជីវៈផ្សេងៗ - បមាណីយនៃជីវភាព ។

១- អ្នកចូលជាសមាជិកនៃអង្គការ AFL-CIO មានចំនួន ២០ លាននាក់ ហើយអង្គការនេះដែលអោយបានបំណាច់ប្រយោជន៍ច្រើនថែមទៀត ព្រមទាំងបានធ្វើអោយ __________ ប្រសើរឡើងផង ។

២- អង្គការ AFL បានកើតឡើងនៅឆ្នាំ ១៨៨៦ ហើយសមាជិករបស់អង្គការនេះភាគច្រើនសុទ្ធតែមកពីខាង ________________________________ ។

៣- ច្បាប់ __________________________ នៃឆ្នាំ ១៩៣៥ បានធ្វើអោយពួកកម្មករមានការកក់ក្តៅអាចពឹងផ្អែកទៅលើបាននៅក្នុងពេលអនាគត នៅពេលដែលគេឈប់ការធ្វើ និងមានវ័យចាស់ជរា ។

៤- ពួកមេដឹកនាំខាងជំនួញទាំងនោះបានបង្កើតអោយមានច្បាប់ខ្លួនឯងជាច្រើនដូចជាច្បាប់ __________________________ ដែលអាចបើកដៃអោយពួកគេជួលនូវកម្មករទៅតាមសេចក្តីត្រូវការ ។

៥- កាលពីរយៈពេលនៃឆ្នាំ ១៩២០ ឥទ្ធិពលនៃ __________________________ បានត្រូវបុះអន់ថយ ដោយសារភាពចំរើនរុងរឿងនៃឧស្សាហកម្ម ។

៦- នៅឆ្នាំ ១៩១៣ រដ្ឋសភាបានបង្កើត __________________________ ក្នុងការដាក់កំរិតបញ្ហាដល់ចលនាជំនួញខូរទៅក្នុងស្រុក ។

៧- ច្បាប់ the Clayton Antitrust Act បានចែងថា រដ្ឋាភិបាលមិនអាចប្រើ ______________________ ទៅសំរាប់បំបែកកូដកម្មបានឡើយ ។

៨- មេដឹកនាំខាងពាណិជ្ជកម្មទាំងនោះ ចង់ធ្វើការកាន់កាប់គ្រប់គ្រងទៅលើរបៀបធ្វើជំនួញ ដូច្នេះគេក៏រៀបបង្កើតជា________________________ ។

៩- កម្មករស្រីៗ ច្រើនតែធ្វើការនៅក្នុងរោងចក្រថ្នាំជក់ រោងចក្រធ្វើសំលៀកបំពាក់ និង____________________ ។ ✓

១០- កម្មករប្រុសៗប្រកប__________________ នៅក្នុងរោងចក្រ ឬ នៅក្នុងស្រែចំការ ។

Section VIII
World Leadership In The Nuclear Age

Section VIII: WORLD LEADERSHIP IN THE NUCLEAR AGE

Packet 30: THE CHALLENGE OF WORLD LEADERSHIP

NEW WORDS & USAGES: ពាក្យថ្មីៗ

cold war: សង្គ្រាមត្រជាក់

A cold war occured when the Communist Bloc and the Capitalist Free World tried to expand their influence and control over the rest of the world.

ideology: មនោគមវិជ្ជា

The difference between the communist and capitalist-democratic ideologies became greater and greater.

obtain: ដែលទទួល ឬ បានទទួល

In 1949 both the Soviet Union and the U.S.A. obtained the atomic bomb.

communism: លទ្ធិកុម្មុនិស្ត

Eastern Europe: អឺរ៉ុបប៉ែកខាងកើត

The U.S. policy was to try to limit the expansion of Communism outside the nations of Eastern Europe.

sphere of influence: ដែនដីដែលមានឥទ្ធិពលទៅលើ

Many small countries in Eastern Europe belonged within the sphere of influence of the Soviet Union.

rebel: ឧទ្ទាម

The Soviets helped rebel groups in Asia, Africa, and Latin America to revolt and to overthrow their governments.

guerilla: ទ័ពព្រៃ

The government forces were attacked by the guerillas near by the forest.

legitimate government: រដ្ឋាភិបាលដែលត្រឹមត្រូវតាមច្បាប់

Until 1972, the U.S. recognized Chiang Kai-Shek's Republic of China as the legitimate government of China.

subversion: វិទ្ធង្សនា

The U.S. helped South Vietnam fight against communist subversion.

multinational forces: កងទ័ពចំរុះដែលមកពីប្រទេសផ្សេងគ្នា

In the Dominican Republic, multinational forces replaced the American Army and helped to arrange a national election.

READING

30.1. THE ROOTS OF THE COLD WAR:

30.1.1. After the Second World War, the world was divided into two blocs: the Communist Bloc and the Capitalist Free World. Both blocs tried to expand their influence and control over the rest of the world. Increasingly, the difference between the communist and capitalist-democratic ideologies became greater and greater. In 1949 both the Soviet Union and the U.S.A. obtained the atomic bomb. The entire world feared the possibility that the cold war would lead to an atomic war between the communist and capitalist-democratic **ideologies** became greater and greater. In 1949, both the Soviet Union and the U.S.A. **obtained** the atomic bomb. The entire world feared the possibility that the **cold war** would lead to an atomic war between these two countries.

30.1.2. At the end of World War II many of the small countries of **Eastern Europe** aligned themselves with the Soviet Union. The Soviet **sphere of influence** extended over Poland, Rumania, Hungary, Czechoslovakia, Yugoslavia and Eastern Germany. There were many attempts to overthrow the Communist regimes in both Poland and Hungary, but all of these revolts were crushed by Russian forces. After 1945, American foreign policy was directed toward confining the expansion of Communism to Eastern Europe.

30.1.3. Despite the American efforts to limit the spread of Communism, the Soviet Union and her allies began helping **rebel** groups in Asia, Africa, and Latin America to revolt and to overthrow their governments. If the revolutions were successful, the new rebel governments would ally themselves with Russia. To curb further Communist expansion, the United States had many plans for helping these poor and underdeveloped countries. Along with economic aid, the U.S. government gave these vulnerable countries weapons to be used against the communist guerillas.

30.2. THE AREAS OF CONFROTATION

30.2.1. During the period known as the cold war, there were several areas throughout the world where the United States found itself in direct conflict with the Soviet Union. The first confrontation occurred in Eastern Germany. In 1945, when the Allies agreed on a plan to control a defeated Germany, the Soviet Union got control over the eastern part of Germany and one-fourth of the city of Berlin. The Allies were given control of West Germany and the rest of Berlin. Because Berlin was located inside the land which was under communist control, the Russians were able to cause many problems for West-Berliners. One of the most serious problems occurred in 1948 when the Russians and the East Germans blockaded all land transportation to West Berlin from West Germany. Soon the West Berliners found themselves facing a food shortages and starvation. The U.S. and its allies had to transport all supplies to Berlin by airplane for 321 days. At last, in 1949, the Communists backed off from their attempts to control West Berlin. After the Berlin Crisis, the Communists continued to create problems in other parts of the world.

30.2.2. The biggest victory of the Communist bloc occurred in China. In 1949 Communist forces under the leadership of Mao Tse-Tung defeated nationalist forces under the leadership of Chiang Kai-Shek. Chiang Kai-Shek and his followers,were forced to flee the Chinese Mainland. They withdrew to Taiwan where Chiang continued to head the government of the Republic of China. The American government refused to recognize the

Communist' government on mainland China. Because it recognized the Republic of China of Chiang Kai-Shek as the legitimate government of China, it let Taiwan maintain its membership in the Security Council of the United Nations.

30.2.3. Korea and Vietnam were other areas of confrontation between the Communist bloc and the Free World. In 1950 North Korean Armies invaded South Korea. American and United Nations forces stopped the invasion after three years of bloody fighting. In 1953, at the Pan Mun-Jong Conference, all countries agreed to maintain the division of the Korea Peninsula. The North belonged to the Communist Bloc and the South to the Free World. To protect this young nation, the U.S. kept a number of its armies in South Korea.

30.2.4. Vietnam was the stage for yet another confrontation. In 1945, when France wanted to reassert its control over Vietnam, it was opposed by Vietnam patriots who united themselves behind a coalition government led by Ho Chi Minh. Soon, conflict broke out between the Communists and the anti-communists within the coalition government; many anti-communists broke away from the Communist-dominated government and organized their own pro-western government that sided with France and the U.S. Ho Chi Minh and the Vietnamese Communists received economic aid, weapons and supplies from the Soviet Union and China. In 1954, Ho Chi Minh's forces defeated the French at Dien Bien Phu. At that time, both sides met at the Geneva Conference and agreed to stop the war. The outcome of that meeting was a divided Vietnam where the northern area, known as North Vietnam, sided with Soviet Union and Communist China, and the southern area, known as South Vietnam, allied itself with the Free World. The U.S. helped South Vietnam by many means, both economic and military, in an effort to protect South Vietnam against subversion and invasion from the North. In 1959, the communists started a guerilla war in South Vietnam. The war escalated in 1965 with the participation of American and North Vietnamese forces. In 1973, both sides signed a cease-fire agreement and the U.S. withdrew its forces from South Vietnam. In 1975, the North Vietnamese, with the help of massive aid from Russia and China, mounted a major offensive in South Vietnam and took control of the whole country.

30.2.5. In addition to Europe, Africa, and Asia, the Communists also wanted to extend their influence to the Caribbean Island. In 1959, Fidel Castro overthrew the regime of Fulgencio Batista in Cuba and established a pro-communist government. In 1960, hundreds of thousands of Cubans fled Cuba and came to live in the U.S. These people hoped to return to Cuba and fight for their freedom, but the plan failed at the Bay of Pigs in 1961. After this, the Cubans sided even more closely with the Russians. Elsewhere in the

Caribbean, the dictatorship of Trujillo in the Dominican Republic was overthrown by a revolution in 1961. In 1962, the Dominicans regained their right to vote after 38 years. They elected the leader of a left wing party, Juan Bosch, as their president. Juan Bosch established a socialist government. This socialist government lasted only 7 months and was overthrown by a group of military officers. Juan Bosch tried to regain his position by leading a mass uprising on April 24, 1965. A Civil War broke out in the Dominican Republic which threatened the lives and properties of the American citizens living in that country. The U.S. sent in marines to protect Americans as well as to stop the expansions of communist influences in this hemisphere. The American and Dominican forces were eventually replaced by a **multinational force** made up of troops from various Latin American countries. The mission of this multinational force was to keep peace and to arrange with the leaders of both sides to create a provisional government. This government held a national election on June 1, 1966, and Joaquin Balaguer become President.

EXERCISES

I. Word Search Puzzle:

EXERCISES

I. World Search Puzzle:

Direction: Find and circle the words in the word puzzle below. The words will be found vertically, horizontally, and diagonally. When you find a word in the puzzle, write it and then define it.

BOMB
FREE
WORLD
WAR
PART
REBEL
CUBA
VETO
ROOTS

ALLIES
SOVIET
CONTROL
OBTAIN
EXPAND
WEAPON
REPLACE
KOREA
CREATE

IDEOLOGY
DEFEAT
MILITARY
GUERILLA
ECONOMIC
RUSSIA
POLAND
LEADERS

OVERTHROW
LEGITIMATE
DOMINICAN
COMMUNIST
SUBVERSION
DIVISION
SOCIALIST
INFLUENCE

MULTINATIONAL FORCES
COLD WAR
CONFRONTATION
EASTERN EUROPE
ATOMIC BOMB
SOUTH VIETNAM
SECURITY COUNCIL
MAO TSE TUNG
WEST BERLIN

H	C	S	E	C	U	R	I	T	Y	C	O	U	N	C	I	L	V	E	T	O
E	H	C	O	N	F	R	O	N	T	A	T	I	O	N	K	O	R	E	A	M
M	I	O	O	C	O	I	O	U	E	R	T	H	R	O	W	E	O	C	W	A
I	N	N	C	O	L	D	W	A	R	O	U	R	R	S	C	C	R	R	E	O
S	E	T	G	M	A	E	A	S	T	E	R	N	E	U	R	O	P	E	S	T
P	S	R	U	M	L	O	B	T	A	I	N	R	B	B	W	N	O	A	T	S
H	E	O	E	U	L	L	O	F	R	E	E	S	E	V	E	O	L	T	B	E
E	M	L	R	N	I	O	M	W	O	R	L	D	L	E	A	M	A	E	E	T
R	A	P	I	I	E	G	B	R	O	O	T	S	O	R	D	I	N	N	R	U
E	I	A	L	S	S	Y	E	X	P	A	N	D	O	S	O	C	D	O	L	N
L	N	R	L	T	Y	E	C	N	E	U	L	F	N	I	N	M	O	L	I	G
E	L	T	A	T	O	M	I	C	B	O	M	B	S	O	V	I	E	T	N	C
A	A	L	E	G	I	T	I	M	A	T	E	N	O	N	R	U	S	S	I	A
D	N	M	U	L	T	I	N	A	T	I	O	N	A	L	F	O	R	C	E	S
E	D	I	V	I	S	I	O	N	D	O	M	I	N	A	T	E	W	A	R	O
R	S	O	U	T	H	V	I	E	T	N	A	M	D	E	F	E	A	T	S	E
S	M	I	L	I	T	A	R	Y	D	O	M	I	N	I	C	A	N	O	A	O
O	S	O	C	I	A	L	I	S	T	R	E	P	L	A	C	E	C	U	B	A

II. Matching: Match each word in column A with the explanation or definition in column B. Write the number of each answer in the space provided.

	A	B
____	1. cold war	a. an enlargement of the territory.
____	2. ideology	b. the struggle between the United States and the Soviet Union which followed the end of World War II.
____	3. sphere of influence	c. an area within a nation or territory in which another more powerful nation has more control over business or government.
____	4. rebel	d. one who lives in Berlin, Germany.
____	5. cease-fire	e. the body of ideas reflecting the social needs and aspirations of a group or culture.
____	6. legitimate	f. an uprising against an authority, a revolt.
____	7. crush	g. to stop fighting.
____	8. guerilla	h. in compliance with the law, lawful.
____	9. expansion	i. to suppress by force.
____	10. Berliner	j. warfare carried on by bands of people not part of a regular army; a fighter in such a band of people.

III. True or False:

Read each statement. Put a T next to each statement if it is true. Put a F in that space if it is false.

____ 1. To stop the Communist expansion, the United States had many plans for helping poor and underdeveloped countries.

____ 2. After World War II, the Soviet Union controlled all parts of Germany.

____ 3. The U.S. and Great Britain had to carry all supplies to West Berlin by airplane for 321 days when the Communists forbade all land transportation from West Germany to West Berlin.

____ 4. Mao Tse Tung was the leader of the Chinese Communist.

____ 5. South Korea belonged to the Free World and the U.S. kept a number of its forces in this area.

____ 6. In 1975, North Vietnam, with massive aid from Russia and China, mounted a major offensive in South Vietnam and took control of the whole country.

____ 7. In 1959, Fidel Castro overthrew the regime of Fugencio Batista in Cuba and established a pro-communist government.

____ 8. The Cubans wanted to come back and fight for their freedom, but the plan failed at the Bay of Pigs in 1961

____ 9. The U.S. did not send their marines to protect the Americans nor to stop the expansion of communist influence in Dominican Republic.

____10. The American and Dominican forces were replaced by a multinational force made up of troops from various Latin American countries.

IV. Fill in the blanks: Complete each statement by writing the correct word or group of words in the blanks: the Communist Bloc and the Free World, atomic bombs, ideologies, sphere of influence, land blockade, starvation, rebel, confrontation, invaded, subversion.

1. The U.S. helped South Vietnam with many plans, both economic and military, in an effort to protect South Vietnam against _________ and invasion from the North.
2. In 1950 North Korean Armies ___________ South Korea.
3. Korea and Vietnam were other areas of ___________ between the Communists and the Free World.
4. The West Beliners were in a difficult situation and faced _________.
5. The Soviet Union and East Germany _________ all overland transportation to West Berlin from West Germany.
6. The Soviet Union and her allies helped the __________ groups in Asia, Africa, and Latin America to revolt and to overthrow their governments.
7. After the Second World War, the world was divided into two blocs: _____________ .
8. The small countries in Eastern Europe belonged to the ________________ of Russia.
9. In 1949, both the Soviet Union and the U.S.A. obtained the ___________.
10. The difference between the communist and capitalist democratic ____________ became greater and greater.

ការអាន

៣០-១ ឫសគល់នៃសង្គ្រាមត្រជាក់

៣០-១-១ បន្ទាប់ពីសង្គ្រាមលោកទីពីរបានចប់មក ពិភពលោក បានត្រូវចែកចេញជាពីរប្លុក គឺ ប្លុកខាងកុម្មុយនិស្ត និង ប្លុកខាងមូលធននិយម ឬ លោកសេរី ។ ប្លុកទាំងពីរនេះបានខិតខំពង្រីកនូវឥទ្ធិពលរបស់ខ្លួន ព្រមទាំងចង់កាន់កាប់ត្រួតត្រាទៅលើផ្នែកឯទៀតក្នុងពិភពលោកទៀតផង ។ ភាពទីទៃពីគ្នា និង ការទាស់គំនិតគ្នាពីមនោគមវិជ្ជាកាន់តែមានខ្លាំងឡើង រវាងប្លុកកុម្មុយនិស្ត និង ប្លុកមូលធននិយមប្រជាធិបតេយ្យ ។ នៅឆ្នាំ ១៩៤៩ ប្រទេសរុស្ស៊ី និង សហរដ្ឋអាមេរិក បានរកឃើញគ្រាប់បែកបរមាណូ ។ ពិភពលោកទាំងមូលមានការភ័យព្រួយថា សង្គ្រាមត្រជាក់អាចនឹងមានលទ្ធភាពធ្វើអោយមានសង្គ្រាមបរមាណូរវាងប្រទេសទាំងពីរនេះ ។

៣០-១-២ នៅពេលដែលសង្គ្រាមលោកលើកទីពីរបានចប់មក ប្រទេសតូចតូចនៃអឺរ៉ុបខាងកើត ក៏បានដាក់ខ្លួនចូលជាមួយប្រទេសរុស្ស៊ី ។ ដែនដីរុស្ស៊ីមានឥទ្ធិពលទៅលើមាន : Poland, Rumania, Hungary, Czechosslovakia, Yugoslavia, East Germany ។ នៅជំនាន់ពេលនោះមានការប៉ុនប៉ងចង់ទម្លាក់របបកុម្មុយនិស្តជាច្រើនដងនៅ Poland និង Hungary ក៏ប៉ុន្តែការបះបោរនេះបានត្រូវកងទ័ពរុស្ស៊ីវាយបំបែកកំទេចចោលរាល់ដង ។ បន្ទាប់ពីឆ្នាំ ១៩៤៥ មក នយោបាយក្រៅប្រទេសរបស់អាមេរិកាំងបានដាក់បំបែរឆ្ពោះទៅរករបៀបខាឃាំងចង់ដាក់អោយការពង្រីកពីឥទ្ធិពលរបស់កុម្មុយនិស្តនេះមាននៅតែអឺរ៉ុបផ្នែកខាងកើតប៉ុណ្ណោះ ។

៣០-១-៣ ថ្វីបើមានការខំប្រឹងប្រែងពីអាមេរិកាំង ដើម្បីនឹងចង់ដាក់កំរិតដល់ការរីកដុះដាលនៃលទ្ធិកុម្មុយនិស្តនេះក៏ដោយ ក៏ប្រទេសរុស្ស៊ី ព្រមទាំងបក្សសម្ព័ន្ធខ្លួនបានចាប់ផ្ដើមជួយពួកឧទ្ទាម នៅអាស៊ី អាហ្វ្រិក និង អាមេរិកឡាទីន ក្នុងគោលបំណងចង់អោយមានការបះបោរទំលាក់រដ្ឋាភិបាលរបស់ក្នុងស្រុក ។ បើសិនណាជាការបដិវត្តិនេះមានជោគជ័យ រដ្ឋាភិបាលនៃពួកបះបោរទាំងនោះនឹងចូលរួបរួមជាមួយរុស្ស៊ីមិនខាន ។ ដើម្បីនឹងចង់ទប់ទល់ពីការពង្រីកនូវលទ្ធិកុម្មុយនិស្តថែមទៀត សហរដ្ឋអាមេរិកបានចាត់តាំងគំរោងការឡើងជាច្រើន ក្នុងការជួយដល់ស្រុកក្រពុំមិនទាន់លូតលាស់ទាំងនោះ ។ ជាមួយនឹងជំនួយខាងសេដ្ឋកិច្ច សហរដ្ឋអាមេរិក បានផ្ដល់អោយប្រទេសដ៏ទន់ខ្សោយងាយស្រួលនឹងគេធ្វើបាបទាំងនោះនូវគ្រឿងសាស្ត្រាវុធថែមទៀត ដើម្បីសំរាប់តតាំងជាមួយទ័ពព្រៃរបស់កុម្មុយនិស្ត ។

៣០-២ ទីកន្លែងដែលមានការប្រណាំងប្រជែងគ្នា

៣០-២-១ កាលពីសម័យ ដែលមានសង្គ្រាមត្រជាក់នោះ គេឃើញសហរដ្ឋអាមេរិកមានការប៉ះទង្គិចផ្ទាល់ជាមួយរុស្ស៊ី នៅតាមផ្នែកជាច្រើន ក្នុងពិភពលោកតែម្ដង ។ កន្លែងទីមួយដែលកើត

ទៀតគឺ នៅអាល្លឺម៉ង់ខាងកើត ។ ក្នុងឆ្នាំ ១៩៥៣ នៅពេលដែលបក្សសម្ព័ន្ធខាងលិច(- អាមេរិកាំង អង់គ្លេស - បារាំង)- បានយល់ស្របគ្នា ក្នុងការកាន់កាប់ត្រួតត្រាប្រទេសអាល្លឺម៉ង់ ដែលចាញ់សង្គ្រាម រុស្ស៊ីក៏បានចូលកាន់កាប់ផ្នែកខាងកើតនៃប្រទេសអាល្លឺម៉ង់ ព្រមទាំងមួយភាគបួននៃទីក្រុង Berlin ផង ។ ពេលនោះ បក្សសម្ព័ន្ធខាងលិច ត្រូវបានគេសំរេចអោយកាន់កាប់អាល្លឺម៉ង់ផ្នែកខាងលិច និង ទីក្រុង Berlin ដែលនៅសល់ទាំងបីភាគ ។ ដោយសារ Berlin ឋិតនៅក្នុងដែនដីរបស់កុម្មុនិស្ត រុស្ស៊ីក៏បានបង្កើតអោយមានបញ្ហាជាច្រើនដល់រាស្ត្រអាល្លឺម៉ង់ខាងលិច ។ បញ្ហាដ៏ធ្ងន់មួយបានកើតឡើងនៅឆ្នាំ ១៩៤៨ ពេលនោះ ពួករុស្ស៊ី និង ពួកអាល្លឺម៉ង់ខាងកើតបានបិទផ្លូវដឹកនាំតាមដីគោកទាំងប៉ុន្មានពីអាល្លឺម៉ង់ខាងលិចឆ្ពោះទៅរកទីក្រុង Berlin ខាងលិច ។ ពេលនោះពលរដ្ឋនៃក្រុង Berlin ខាងលិចបានជួបប្រទះនឹងការខ្វះខាតម្ហូបអាហារ និង ការអត់ឃ្លាន ។ សហរដ្ឋអាមេរិក និង បក្សសម្ព័ន្ធខ្លួនបានចាប់ផ្តើមដឹកនាំគ្រឿងសម្ភារៈទៅទីក្រុង Berlin ដោយប្រើយន្តហោះអស់រយៈ ៣២១ ថ្ងៃ ។ នៅទីបញ្ចប់ គឺឆ្នាំ ១៩៤៩ ពួកកុម្មុនិស្តក៏បានដកខ្លួនចេញពីការប៉ុនប៉ងការកាន់កាប់ទីក្រុង Berlin ខាងលិចនេះ ។ បន្ទាប់ពីមានវិបត្តិនៃក្រុង Berlin នេះមក ពួកកុម្មុនិស្តនៅតែបន្តកិច្ចការខ្លួនក្នុងការបង្កើតអោយមានបញ្ហានៅតាមផ្នែកជាច្រើនទៀត ក្នុងពិភពលោកដដែល ។

៣០-២-២ ជោគជ័យដ៏ធំមួយរបស់ពួកកុម្មុនិស្តបានកើតមានឡើងនៅស្រុកចិន ។ នៅឆ្នាំ ១៩៤៩ កងទ័ពកុម្មុនិស្ត ដែលនៅក្រោមការដឹកនាំរបស់លោកម៉ៅ សេ ទុង បានវាយឈ្នះកងទ័ពអ្នកជាតិនិយមនៃលោក ឆាង កាយ ឆេក ។ ពួកអ្នកជាតិនិយមត្រូវគេបង្ខំអោយចាកចេញពីស្រុក ដោយដកថយទៅកោះតាយវ៉ាន់ ។ នៅទីនោះ លោក ឆាង កាយ ឆេក នៅតែបន្តការដឹកនាំរបស់លោក ក្នុងរដ្ឋាភិបាលសាធារណៈរដ្ឋចិនជាតិនិយមដដែល ។ សហរដ្ឋអាមេរិកមិនព្រមទទួលស្គាល់រដ្ឋាភិបាលកុម្មុនិស្តចិនឡើយ ព្រោះគេទទួលស្គាល់រដ្ឋាភិបាលសាធារណៈរដ្ឋរបស់លោក ឆាង កាយ ឆេក ថាជារដ្ឋាភិបាលត្រឹមត្រូវតាមច្បាប់ ។ ហើយថែមទាំងអនុញ្ញាតិអោយតាយវ៉ាន់រក្សាទុកនូវភាពជាសមាជិកនៃក្រុមប្រឹក្សាសន្តិសុខ នៅក្នុងអង្គការសហប្រជាជាតិផង ។

៣០-២-៣ កូរ៉េ ហើយ និងវៀតណាម ជាកន្លែងប៉ះទង្គិចគ្នាមួយទៀតរវាងពួកកុម្មុនិស្ត និង លោកសេរី ។ នៅឆ្នាំ ១៩៥០ កូរ៉េខាងជើង បានចូលលុកលុយផ្នែកខាងត្បូង ។ កងទ័ពអាមេរិកាំង និង កងទ័ពអង្គការសហប្រជាជាតិបានវាយបញ្ច្រាប់ការចូលរាតត្បាតនៃពួកខាងជើងនេះ បន្ទាប់ពីបានប្រយុទ្ធគ្នាយ៉ាងសាហាវអស់រយៈពេលបីឆ្នាំមក ។ នៅឆ្នាំ ១៩៥៣ បន្ទាប់ពីមានសន្និបាតនៅ Pan Mun-Jong មក ប្រទេសទាំងអស់បានយល់ព្រមដាក់កងទ័ពខ្លួនម្នាក់ៗមួយកងពលធំនៅក្នុងស្រុកកូរ៉េនោះ ។ កូរ៉េត្រូវបែងចែកជាពីរផ្នែក ផ្នែកខាងជើងជាបក្សខាងពួកកុម្មុនិស្ត ឯផ្នែកខាងត្បូងជាប្រទេសខាងលោកសេរី ។ ដើម្បីនឹងបង្ការការពារ

ដល់ប្រទេសថ្មីនេះ សហរដ្ឋអាមេរិក បានដាក់កងទ័ពរបស់ខ្លួនមួយចំនួននៅកូរ៉េខាងត្បូង ។

៣០.២.៤ វៀតណាម ជាថ្នាក់បន្ទាប់ក្នុងការប៉ះទង្គិចគ្នានេះ ។ នៅឆ្នាំ ១៩៤៥ នៅពេលដែលប្រទេសបារាំងបានពោលអះអាងជាថ្មីម្តងទៀត ពីការចង់កាន់កាប់គ្រប់គ្រងទៅលើវៀតណាមនោះ ពួកអ្នកស្នេហាជាតិវៀតណាម ដែលបានរួបរួមគ្នានៅក្រោមរដ្ឋាភិបាលបង្រួបបង្រួមរបស់លោក ហូ ជី មិញ ក៏បានងើបប្រឆាំងឡើង ។ ពេលនោះការប្រយុទ្ធគ្នាក៏ចាប់កើតមានឡើង រវាងពួកកុម្មុយនិស្ត និង អ្នកប្រឆាំងកុម្មុយនិស្ត ដែលនៅក្នុងរដ្ឋាភិបាលបង្រួបបង្រួមជាមួយគ្នា ។ អ្នកប្រឆាំងនឹងកុម្មុយនិស្តជាច្រើនរូប ក៏បានបែកចេញពីរដ្ឋាភិបាលកុម្មុយនិស្តលោក ហូ ជី មិញ ដើម្បីនឹងរៀបចំបង្កើតរដ្ឋាភិបាលខ្លួនឯងមួយ ដែលមានការលំអៀងទៅលើពួកខាងលិច គឺបក្សសម្ព័ន្ធខាងអាមេរិកាំង និង បារាំង ។ វៀតណាមកុម្មុយនិស្ត បានទទួលជំនួយខាងសេដ្ឋកិច្ច គ្រឿងសម្ភារៈ និង អាវុធពីរុស្ស៊ី និង ចិន ។ នៅឆ្នាំ ១៩៥៤ កងទ័ព ហូ ជី មិញបានវាយឈ្នះបារាំងនៅ ឌៀន បៀន ភូ ។ ពេលនោះស្រុកទាំងពីរបានជួបគ្នាធ្វើសន្និសីទនៅក្រុង Geneva ហើយក៏បានយល់ព្រមបញ្ឈប់សង្គ្រាម ។ លទ្ធផលដែលបានមកពីសន្និសីទនោះ គឺការបែងចែក វៀតណាម ដោយដាក់ វៀតណាមផ្នែកខាងជើង ជាបក្សខាងរុស្ស៊ី និង ចិន ឯផ្នែកខាងត្បូងវិញ ជាបក្សខាងលោកសេរី ។ សហរដ្ឋអាមេរិក បានជួយវៀតណាមខាងត្បូងស្ទើរតែគ្រប់ផ្លូវទាំងអស់ គឺ ខាងផ្នែកសេដ្ឋកិច្ច និង យោធា ដើម្បីជួយប្រទេសនេះប្រយុទ្ធតទល់នឹងអំពើវិទ្ធង្សនា ឬ ក៏ ការចូលលុកលុយពីផ្នែកខាងជើង ។ នៅឆ្នាំ ១៩៥៩ ពួកកុម្មុយនិស្តក៏បានចាប់ផ្តើមសង្គ្រាមទ័ពព្រៃនៅវៀតណាមខាងត្បូង ។ ដល់ឆ្នាំ ១៩៦៥ សង្គ្រាមនេះក៏រឹតតែបានផ្ទុះដាលឡើង ដោយមានទ័ពអាមេរិកាំង និង វៀតណាមខាងជើងចូលរួមផង ។ នៅឆ្នាំ ១៩៧៣ ផ្នែកទាំងសងខាង ក៏បានយល់ព្រមចុះហត្ថលេខា ដើម្បីនឹងផ្អាកសង្គ្រាម ។ ប៉ុន្តែដល់ឆ្នាំ ១៩៧៥ វៀតណាមខាងជើង ដែលបានទទួលជំនួយយ៉ាងសន្ធឹកសន្ធាប់ពីរុស្ស៊ី និង ចិន ក៏បានចាប់ផ្តើមធ្វើការវាយលុកមួយយ៉ាងធំនៅផ្នែកខាងត្បូង ហើយព្រមទាំងបានឈ្នះឡើងកាន់កាប់អំណាចក្នុងប្រទេសទាំងមូលទៀតផង ។

៣០.២.៥ បន្ថែមពីលើផ្នែកខាងអឺរ៉ុប អាហ្វ្រិក និង អាស៊ី ពួកកុម្មុយនិស្ត ក៏ចង់ធ្វើការពង្រីកនូវឥទ្ធិពលខ្លួនមកខាងកោះ Caribbean ទៀត ។ នៅឆ្នាំ ១៩៥៩ Fidel Castro បានរំលំរបបរបស់លោក Fulgencio Batista នៅ Cuba ហើយដែលបានបង្កើតរដ្ឋាភិបាល ដែលលំអៀងទៅលើកុម្មុយនិស្តផង ។ នៅឆ្នាំ ១៩៦០ ប្រជារាស្ត្រ Cuba រាប់រយពាន់នាក់បានរត់ចេញពីស្រុក ដើម្បីនឹងចូលមកនៅក្នុងសហរដ្ឋអាមេរិក ។ មនុស្សទាំងអស់នេះសង្ឃឹមថា នឹងវិលត្រឡប់ទៅ Cuba ក្នុងថ្ងៃណាមួយ ដើម្បីនឹងប្រយុទ្ធទាមទារឯករាជ្យរបស់ខ្លួនមកវិញ ។ ប៉ុន្តែវិធានការរបស់គេមិនមានជោគជ័យ ដោយត្រូវប្រយុទ្ធចាញ់គេនៅBay of Pigs នៅឆ្នាំ ១៩៦១ ។ បន្ទាប់ពីនោះមក Cuba រឹតតែជិតដិតថែមទៀតទៅខាងរុស្ស៊ី ។ នៅផ្នែកឯទៀតៗនៃកោះ Caribbean នោះ អំណាចផ្តាច់ការរបស់លោក Trujillo

ដែនស្រុក Dominicans Republic បានត្រូវពួកបដិវត្តិរំលំចោលនៅឆ្នាំ ១៩៦១ ។ ដល់ឆ្នាំ ១៩៦២ ប្រជារាស្ត្រ Dominicans នេះទើបមានអំណាចបោះឆ្នោតបានឡើងវិញ បន្ទាប់ពីរយៈពេល ៣៨ ឆ្នាំ ដែលគេបានបំបិទសិទ្ធិនោះមក ។ ពួកគេបានជ្រើសរើសអ្នកដឹកនាំបក្សខាងឆ្វេងម្នាក់ឈ្មោះ Juan Bosch អោយធ្វើជាប្រធានាធិបតី ។ Juan Bosch ក៏បានបង្កើតរដ្ឋាភិបាលសង្គមនិយមដែលកាន់កាប់កិច្ចការបានតែប្រាំពីរខែប៉ុណ្ណោះ ពីព្រោះពេលនោះ រដ្ឋាភិបាលត្រូវបានពួកនាយទាហានវាយទំលាក់អំណាច ។ Juan Bosch ចង់ដណ្តើមយកអំណាចខ្លួនមកវិញដោយបង្កបង្កើតអោយមានការបះបោរយ៉ាងខ្លាំងនៅឆ្នាំ ១៩៦៥ ។ ពេលនោះ សង្គ្រាមក្នុងស្រុកក៏បានកើតមានឡើងនៅ Dominicans Republic ដែលធ្វើអោយមានការកំហែងគំរាមដល់អាយុជីវិត និង ទ្រព្យសម្បត្តិរបស់ប្រជារាស្ត្រអាមេរិកាំងរស់នៅក្នុងស្រុកនោះ ។ សហរដ្ឋអាមេរិកក៏បានបញ្ជូនទាហានម៉ារីនទៅ ដើម្បីសំរាប់ការពារដល់ប្រជារាស្ត្រខ្លួនផង និង ធ្វើការទប់ទល់បញ្ឈប់នូវការរីកដុះដាលនៃកុម្មុនិស្តនៅផ្នែកនោះផង ។ កងទ័ពអាមេរិកាំង និង កងទ័ព Dominicans Republic ក្រោយមកក៏ត្រូវដកចេញ ដោយដាក់កងទ័ពចំរុះពីប្រទេសអាមេរិកឡាទីនទៀតជំនួសវិញ ។ បេសកកម្មរបស់កងទ័ពចំរុះនេះ គឺដើម្បីចង់ធ្វើអោយមានសន្តិភាពឡើងវិញ ហើយព្រមទាំងចង់អោយមេដឹកនាំទាំងពីរបក្សដែលឈ្លោះគ្នានោះ រួមគ្នាបង្កើតជារដ្ឋាភិបាលបណ្តោះអាសន្នមួយផង ។ រដ្ឋាភិបាលនេះបានចាត់ចែងធ្វើការបោះឆ្នោតក្នុងប្រទេសនៅថ្ងៃទី ១ ខែមិថុនា ឆ្នាំ ១៩៦៦ ហើយពេលនោះ លោក Joaquin Balaguer ក៏បានជាប់ឆ្នោតធ្វើជាប្រធានាធិបតីទៀត ។

ការហាត់

១- របៀបរកពាក្យ

សេចក្ដីណែនាំ : សូមរក និង គូសរង្វង់នៅជុំវិញពាក្យទាំង ៤៣ នៅក្នុងរបៀបរកពាក្យខាងក្រោម ។ ពាក្យទាំងអស់នេះអាចរកឃើញតាមរបៀប បញ្ឈរ ផ្ដេក និងបញ្ឆៀង ។ ពេលដែលរកឃើញនូវពាក្យនិមួយៗ សូមសរសេរដាក់នៅលើក្រដាស ព្រមទាំងអោយអត្ថន័យនៃពាក្យនោះផង ។

BOMB
FREE
WORLD
WAR
PART
REBEL
CUBA
VETO
ROOTS

ALLIES
SOVIET
CONTROL
OBTAIN
EXPAND
WEAPON
REPLACE
KOREA
CREATE

IDEOLOGY
DEFEAT
MILITARY
GUERILLA
ECONOMIC
RUSSIA
POLAND
LEADERS

OVERTHROW
LEGITIMATE
DOMINICAN
COMMUNIST
SUBVERSION
DIVISION
SOCIALIST
INFLUENCE

MULTINATIONAL FORCES
COLD WAR
CONFRONTATION
EASTERN EUROPE
ATOMIC BOMB
SOUTH VIETNAM
SECURITY COUNCIL
MAO TSE TUNG
WEST BERLIN

```
H C S E C U R I T Y C O U N C I L V E T O
E H C O N F R O N T A T I O N K O R E A M
M I O O C O I O U E R T H R O W E O C W A
I N N C O L D W A R O U R R S C C R R E O
S E T G M A E A S T E R N E U R O P E S T
P S R U M L O B T A I N R B B W N O A T S
H E O E U L L O F R E E S E V E O L T B E
E M L R N I O M W O R L D L E A M A E E T
R A P I I E G B R O O T S O R D I N N R U
E I A L S S Y E X P A N D O S O C D O L N
L N R L T Y E C N E U L F N I N M O L I G
E L T A T O M I C B O M B S O V I E T N C
A A L E G I T I M A T E N O N R U S S I A
D N M U L T I N A T I O N A L F O R C E S
E D I V I S I O N D O M I N A T E W A R O
R S O U T H V I E T N A M D E F E A T S E
S M I L I T A R Y D O M I N I C A N O A O
O S O C I A L I S T R E P L A C E C U B A
```

២. របៀបប្រៀបធៀប

សូមប្រៀបធៀបពាក្យ ដែលនៅខាងឆ្វេងក្រោមបន្ទាត់អក្សរ A ទៅនឹងអត្ថន័យ ឬ សេចក្ដីពន្យល់ ដែលនៅខាងស្ដាំក្រោមបន្ទាត់អក្សរ B ហើយសូមដាក់ជាលេខនៅពីខាងមុខលំនូរនិមួយៗផង ។

	A	B
______	១. សង្គ្រាមត្រជាក់	ក. ការពង្រីកទឹកដី
______	២. មនោគមវិជ្ជា	ខ. ការប្រឆាំងនិងឈ្លោះប្រកែកគ្នារវាងសហរដ្ឋអាមេរិក និង រុស្ស៊ីបន្ទាប់ពីសង្គ្រាមលោកលើកទីពីរបញ្ចប់មក
______	៣. ដែនដីដែលមានឥទ្ធិពលទៅលើ	គ. ជាផ្នែក ឬ តំបន់ នៃប្រទេសណាមួយដែលត្រូវប្រទេសមួយទៀត ដែលមានកំលាំងខ្លាំងជាងកាត់កាប់ពីរពីជំនួញ ឬពីរលើរដ្ឋាភិបាលរបស់ខ្លួន
______	៤. ឧទ្ទាម	ឃ. ជាអ្នករស់នៅក្នុងក្រុង Berlin នៃប្រទេសអាល្លឺម៉ង់
______	៥. បញ្ឈប់សង្គ្រាម	ង. ជាពួអង្គនៃគំនិត ដែលបង្ហាញអោយឃើញពីសេចក្ដីត្រូវការក្នុងសង្គម និង ពីសេចក្ដីប្រាថ្នានៃក្រុមណាមួយ ឬ ពីខាងវប្បធម៌
______	៦. ត្រឹមត្រូវតាមច្បាប់	ច. ការរើបបះបោរប្រឆាំងនឹងអ្នកកាន់អំណាច
______	៧. សង្កត់កំទេច	ឆ. ការឈប់ច្បាំងគ្នា
______	៨. ទ័ពព្រៃ	ជ. ដែលត្រូវនឹងច្បាប់ទំលាប់
______	៩. ពង្រីក	ឈ. ជាចលនាយ៉ាងខ្លាំងរបស់ហ្វូងមនុស្ស ឬ គឺគៀបសង្កត់គ្នា
______	១០. ប្រជាជន Berlin	ញ. ជាសង្គ្រាមដែលធ្វើឡើងដោយក្រុមមនុស្សមួយពួក ដែលមិនមែនជាផ្នែករបស់កងទ័ព

៣. ពិត ឬ មិនពិត

សូមមើលឃ្លានីមួយៗ ដោយដាក់អក្សរ T នៅពីខាងមុខឃ្លាណាដែលយល់ថា ពិតត្រឹមត្រូវ និង អក្សរ F បើយល់ថាឃ្លានោះមិនពិតទេ ។

_______១. ដើម្បីនឹងចង់បញ្ឈប់ពីការពង្រីកពង្រឹងរបស់កុម្មុយនិស្ត សហរដ្ឋអាមេរិកបានចាត់វិធានការយោធាច្រើនទៀត ដើម្បីសំរាប់ជួយដល់ប្រទេសដែលក្រពុំមិនទាន់លូតលាស់ ។

_______២. បន្ទាប់ពីសង្គ្រាមលោកលើកទីពីរបានចប់មក រុស្ស៊ីបានធ្វើការកាន់កាប់នៅគ្រប់ផ្នែកនៃប្រទេសអាល្លឺម៉ង់ ។

_______៣. នៅពេលដែលពួកកុម្មុយនិស្តបិទផ្លូវមិនអោយធ្វើការដឹកនាំចេញចូលពីអាល្លឺម៉ង់ខាងលិចទៅទីក្រុង Berlin ខាងលិច សហរដ្ឋអាមេរិក និង អង់គ្លេសក៏បានប្រើយន្តហោះក្នុងការដឹកនាំគ្រឿងសម្ភារៈទៅអោយប្រជារាស្ត្រនៅទីក្រុង Berlin ខាងលិចអស់រយៈពេល ៣២១ ថ្ងៃ ។

_______៤. ម៉ៅ សេ ទុង ជាមេដឹកនាំចិនកុម្មុយនិស្ត ។

_______៥. កូរ៉េខាងត្បូងជាបក្សខាងលោកសេរី ហើយសហរដ្ឋអាមេរិក បានដាក់ទ័ពខ្លួនមួយផ្នែកធំនៅក្នុងប្រទេសនោះផង ។

_______៦. នៅឆ្នាំ ១៩៧៥ វៀតណាមខាងជើងដែលបានទទួលជំនួយយ៉ាងសន្ធឹកសន្ធាប់ពីរុស្ស៊ី និង ចិន ក៏វាយប្រហារយ៉ាងខ្លាំងទៅ វៀតណាមខាងត្បូង ហើយព្រមទាំងបានទទួលការកាន់កាប់ត្រួតត្រាស្រុកផង ។

_______៧. នៅឆ្នាំ ១៩៥៩ Fidel Castro បានរំលំរបបលោកFugencio Batista នៅ Cuba ព្រមទាំងបានបង្កើតរដ្ឋាភិបាលដែលលំអៀងទៅខាងកុម្មុយនិស្ត ។

_______៨. រាស្ត្រ Cuba ជាច្រើនចង់វិលចូលមកស្រុក ដើម្បីនឹងចង់ប្រយុទ្ធដណ្តើមយកសេរីភាពខ្លួនមកវិញ ។ ក៏ប៉ុន្តែវិធានការយោធានេះមិនបានសំរេច ដោយប្រយុទ្ធចាញ់គេនៅ Bay-of Pigs នៅឆ្នាំ ១៩៦១ ។

_______៩. សហរដ្ឋអាមេរិកមិនបានបញ្ជូនទ័ពម៉ារីនទៅ Dominicans Republic ដើម្បីនឹងធ្វើការការពារដល់ពលរដ្ឋអាមេរិកាំង និង ចង់បញ្ឈប់ពីការពង្រីកឥទ្ធិពលរបស់កុម្មុយនិស្តទេ ។

______១០. កងទ័ពអាមេរិកាំង និង កងទ័ព Dominicans Republic បានត្រូវគេដកចេញ ដោយដាក់កងទ័ពចំរុះពីប្រទេសអាមេរិកឡាទីនជំនួសវិញ ។

៤- ការបំពេញឃ្លាក្នុងកន្លែងទំនេរ

សូមបំពេញឃ្លានីមួយៗ ដោយរើសយកពាក្យ ឬ ក្រុមពាក្យអោយបានត្រឹមត្រូវសំរាប់ដាក់បញ្ចូលក្នុងកន្លែងទំនេរ ។ ពាក្យទាំងនោះមាន : ប្លុកកុម្មុនិស្ត និង លោកសេរី - គ្រាប់បែកបរមាណូ - មនោគមវិជ្ជា - មានឥទ្ធិពលទៅលើ - បិទផ្លូវដឹកនាំដីគោក - ការអត់ឃ្លាន - ក្រុមឧទ្ទាម - ការប៉ះទង្គិចគ្នា - ចូលលុកលុយរាតត្បាតពាក់ - ធ្វើវិទ្ធង្សនា ។

១- សហរដ្ឋអាមេរិកបានជួយវៀតណាមខាងត្បូងនៅគ្រប់ផ្លូវទាំងអស់ គឺសេដ្ឋកិច្ច និង យោធា ក្នុងការទប់ប្រឆាំងការពារប្រទេសនោះពីការ ________________ និង ការចូលរាតត្បាតពីវៀតណាមខាងជើង ។

២- នៅឆ្នាំ ១៩៥០ កងទ័ពកូរ៉េខាងជើងបាន ____________________ នៅក្នុងកូរ៉េខាងត្បូង ។

៣- កូរ៉េហើយនិងវៀតណាមជាកន្លែងដែលកើតឡើងក្នុង ________________ រវាងកុម្មុនិស្ត និង លោកសេរី ។

៤- ប្រជារាស្ត្រដែលនៅក្នុងទីក្រុង Berlin ខាងលិចត្រូវបានជួបប្រទះនឹងស្ថានការណ៍ដ៏តឹងតែង ហើយព្រមទាំងបានជួបប្រទះនឹងការ ______________ ទៀតផង ។

៥- រុស្ស៊ីហើយនិងអាល្លឺម៉ង់ខាងកើតបាន ___________________________ ពីអាល្លឺម៉ង់ខាងលិច ដែលឆ្ពោះទៅទីក្រុង Berlin ខាងលិច ។

៦- រុស្ស៊ីព្រមទាំងបក្សសម្ព័ន្ធរបស់គេបានជួយ ____________________ នៅអាស៊ី អាហ្វ្រិក ហើយនិងអាមេរិកឡាទីន ដើម្បីនឹងបង្កអោយពួកនោះបះបោរទំលំរដ្ឋាភិបាលក្នុងស្រុក ។

៧- បន្ទាប់ពីសង្គ្រាមលោកលើកទីពីរបានចប់មក ពិភពលោកត្រូវបែងចែកជាពីរគឺ :

____ ។

៨- ប្រទេសតូចៗនៃអឺរ៉ុបផ្នែកខាងកើតជាដែនដីដែលរុស្ស៊ី _____________ ។

៩- នៅឆ្នាំ ១៩៤៩ សហរដ្ឋអាមេរិក និង រុស្ស៊ីបានរកឃើញ ___________ ។

១០- ភាពខុសគ្នានៃ ______________ របស់កុម្មុនិស្តនិងពួកមូលធននិយមប្រជាធិបតេយ្យ មានកំរិតកាន់តែខ្លាំងឡើងៗ ។

Section VIII: WORLD LEADERSHIP IN THE NUCLEAR AGE

Packet 31: THE QUEST FOR A PEACEFUL WORLD

NEW WORDS: ពាក្យថ្មីៗ

post-war era: សម័យក្រោយសង្គ្រាម

European countries were rebuilt in the post-war era.

confrontation: ប្រឈមមុខតទល់គ្នា

There was a big confrontation between Egypt and Israel in the Middle East.

superpower: មហាអំណាច

The United States and the Soviet Union are two superpowers in the world.

struggle: ការប្រយុទ្ធ ខំប្រឹងពុះពារ

During depression time people struggle with starvation and employment.

anti-communist government: រដ្ឋាភិបាល ដែលប្រឆាំងនឹងកុម្មុនិស្ត

Before 1975, there was an anti-communist government in South Vietnam.

Komecon: ជាសមាជិករួមរវាង ប្រទេសតូចៗនៃអឺរ៉ុបខាងកើត និង សូវៀត

The members of Komecon Plan are small countries in Eastern Europe and Russia.

Warsaw Pact: សម្ព័ន្ធយោធា រួមរវាង ប្លុកកុម្មុនិស្តនៅអឺរ៉ុប

The Warsaw Pact is a military alliance between the communist countries in Europe.

missile: គ្រាប់បែក ឬ កាំជ្រួចដែលបាញ់ទៅមុខ

The Russians installed many missiles in Europe.

outer space: មេឃ ឬ អវកាស

The spaceship moves around the earth in the outer space.

limitation: ការកំណត់ ឬ កំរិតបង្រួម

The people in the world wanted the limitation of nuclear weapons.

friendship: មិត្តភាព

President Nixon made a friendship trip to China in 1972.

insurgent: អ្នកបះបោរ កុបករ

The government troops crushed the insurgents in the mountains areas.

infiltration: លបចូល

The U.S. helped the anti-government of El Salvador to stop the infiltration of guerillas from Nicaragua.

READING

31.1. THE WORLD IN THE POST-WAR ERA:

31.1.1. After the Second World War, in addition to an ideological **confrontation**, there was also an arms race between the two great **superpowers** - the Soviet Union and the United States. Both of these countries possessed many nuclear bombs and continued to produce them in large quantities. Other countries such as France, Great Britain, and China also wanted

590

to produce their own bombs. The world was full of nuclear weapons and the fear of a nuclear war led to a worldwide demand to limit or slow down the production of nuclear weapons.

31.1.2. Although the superpowers produced and stored nuclear weapons, they did not want to use them. Both the U.S. and the Soviet Union have tried to avoid a nuclear war and have been involved only in regional and limited wars. In these wars, only conventional weapons were used. The Russians continued to export their communist ideology to the poor countries in Asia, Africa, and Latin America. In an effort to stop the expansion of communism, the U.S. helped these countries to establish **anti-communist governments.**

31.1.3. In the 1960's and the 1970's, many crises such as those in Berlin, Greece, Indochina and the Carribbean Sea occurred. Both the U.S. and the Soviet Union provided their allies with economic aid and a protection against attack. By means of the Marshall Plan, the U.S. provided economic aid to help Western Europe recover from the devastation of the Second World War. Through NATO, Western Europe was insured against any attack by the Soviet Union. In response, the Communists created the **Komecon** and the **Warsaw Pact.** The Komecon helped communist countries to develop their economies, and the Warsaw Pact protected these countries against armed attack from the West.

31.1.4. In 1962, the Soviet Union precipitated a major crisis by installing offensive **missiles** in Cuba. President

Kennedy ordered a naval blockade of the island and demanded that the Russians remove these missiles. Finally, the Soviet Union agreed to withdraw their missiles from Cuba and war with the U.S. was avoided.

31.2. THE WORLD IN THE DETENTE ERA

31.2.1. After the Cuban crisis, people throughout the world put pressure on the superpowers to slow down the arms race. In 1963, the U.S., Great Britain, and the Soviet Union signed the Nuclear Test Ban Treaty. These three countries agreed not to test nuclear weapons in the air, in outer space, and under water. In 1968, many nations signed the Nuclear Nonproliferation Treaty. According to this treaty the nuclear powers pledged not to supply other countries with nuclear weapons or the knowledge of how to make the bomb.

In 1969, the U.S. and the Soviet Union began to discuss the limitation of strategic weapons. These discussions were called Strategic Arms Limitation Talks (SALT). These talks led to major agreements during Nixon's and Carter's administrations.

31.2.2. In addition to these arms control treaties, the United States also explored new ways to preserve world peace. President Nixon made many trips in friendship to Asia and Europe. He visited China in 1972, and in 1973 the U.S. and China exchanged ambassadors. President Nixon also visited Russia and Eastern Europe. Together, Nixon and the Soviet leaders reached many agreements on space research and pollution control. In 1975 a team of American and Russian astronauts completed the first joint U.S.- Soviet spaceflight.

